សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណាបញ្ចប់ការសិក្សា**

# ឥទ្ធិពលនៃគ្រឿងស្រវឹងក្នុងសង្គមខ្មែរ នាពេលបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី៣០ ខែមេសា ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ខឹម ចំរ៉ុង**
**ធិន ឌីម៉ង់**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ
ជំនាន់ទី ៨

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# អារម្ភកថា

អស់រយៈពេល ៤ ឆ្នាំកន្លងទៅនេះ គឺជាពេលវេលាមួយ ដែលមានតម្លៃបំផុតសំរាប់ពួកយើងខ្ញុំទាំងពីរនាក់ មុននឹងឈានមកដល់ជំហានមួយក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ យើងខ្ញុំបានបន្សល់ទុកនូវស្នាដៃមួយ ដែលជាការសិក្សាស្រាវជ្រាវប្រកបដោយការយកចិត្តទុកដាក់បំផុតក្រោមកម្មវត្ថុស្តីអំពី ឥទ្ធិពលនៃគ្រឿងស្រវឹងក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ។

ស្របពេលនៃសេដ្ឋកិច្ចជាតិកំពុងតែមានការរីកចម្រើន ការជះឥទ្ធិពលនៃគ្រឿងស្រវឹងមកលើសង្គមខ្មែរនាពេលបច្ចុប្បន្ន ពិតជាមានលក្ខណៈគួរឲ្យព្រួយបារម្ភ។ ហើយដែលបញ្ហានេះបានបង្កើតឡើងជាផលវិបាកសំរាប់សង្គមជាតិទាំងមូល ធ្វើការដោះស្រាយ ក៏ដូចជាស្វែករកនូវយន្តការផ្សេងៗពីសំណាក់រាជរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងការចូលរួមពីប្រជាជនក្នុងការរួមចំណែកដើម្បីធ្វើឲ្យបញ្ហាខាងលើនេះមានភាពកាន់តែល្អប្រសើរឡើងដោយពុំមានការរីករាលដាល ឬការផ្សព្វផ្សាយមានលក្ខណៈគគ្រឹកគគ្រេង ដែលយើងមើលទៅហាក់បីដូចជាឥតសណ្តាប់ធ្នាប់ ហើយអ្វីដែលពិសេសនោះសង្គមជាតិរបស់យើងពោរពេញដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងយ៉ាងច្រើន។

ដូច្នេះហើយទើបគោលបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតទៅលើលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល អង្គការជាដៃគូរ ក៏ដូចជាប្រជាពលរដ្ឋតាម រយៈការបង្កើតឡើងជាវេទិកា ឬសិក្ខាសាលាជជែកពិភាក្សាគ្នាអំពីដំណោះស្រាយជារួមក្នុងការកាត់ បន្ថយនូវអត្រានៃអ្នកប្រើប្រាស់គ្រឿងស្រវឹង ព្រមជាមួយនឹងការផ្សព្វផ្សាយដែលមានលក្ខណៈជាការពង្វក់ ឬជាការ បំភ័ន្តដល់ភ្នែកប្រជាពលរដ្ឋអោយឃើញពីចំណុចល្អនៅក្នុងការជាវគ្រឿងស្រវឹងយកទៅទទួលទាន ឬប្រសិនបើគ្មានការចូលរួមពីគ្រឿងស្រវឹងទេ ភាពសប្បាយរីករាយក៏ពុំអាចកើតឡើងទៅបានដែរ។ ប៉ុន្តែយើងសង្ឃឹមថាបញ្ហាខាងលើនេះ អាចកាត់បន្ថយទៅបានតាមរយៈការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធ ក្នុងការពិភាក្សាស្វែងរកចំណុចរួមមួយដែលអាចទទួលយកបានទាំងអស់គ្នា ពោលគឺទាំងក្រុមហ៊ុនធ្វើអាជីវកម្មលើគ្រឿងស្រវឹង រាជរដ្ឋាភិបាលតាមរយៈការបង្កើតជាច្បាប់ គោលនយោបាយសេចក្តីណែនាំផ្សេងៗជាវិធានការទប់ស្កាត់មួយដែលមានប្រសិទ្ធភាព ហើយចាំបាច់បំផុតនោះគឺការចូលរួមពីអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋអនុវត្តទៅតាមអ្វីដែលជាច្បាប់បានកំណត់ទុក។

ចំពោះការរៀបចំឯកសារនេះឡើង ជឿជាក់ថានៅមានចំណុចដែលខ្វះខាត និងកំហុសឆ្គងមួយចំនួន ដែលកើតមានដោយអចេតនា ទាំងអក្ខរាវិរុទ្ធ ទាំងពាក្យពេចន៍ អត្ថន័យ និងទស្សនៈមួយចំនួនជាក់ជាមិនខាន។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះ និងជួយសម្រួលក៏ដូចជាចូលរួមចំណែកក្នុងការសិក្សាទោះបីមានទំហំតិច ឬច្រើនក៏ដោយ។ ហើយយើងខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគន់ពីគ្រប់មជ្ឈដ្ឋានអ្នកសិក្សាទាំអស់ក្នុងន័យស្ថាបនា ព្រមទាំងការកែលម្អរបំពេញបន្ថែមក្នុងការធ្វើឲ្យឯកសារមួយនេះមានលក្ខណៈកាន់តែល្អប្រសើរឡើងមួយកម្រិតថែមទៀត។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ខឹម ចំរ៉ុង និង ធិន ឌីម៉ង់ ជានិស្សិតបរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី ៤ ជំនាន់ទី៨ ក្រុម $P_4C_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសំដែងនូវការគោរពដ៏ជ្រាលជ្រៅ និងដឹងគុណជាទីបំផុតចំពោះៈ

– **អ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅខ្ញុំបាទតាំងពីតូចមកម្លេះ ព្រមទាំងបរិច្ចាកនូវថវិកា និងកម្លាំងកាយ កម្លាំងចិត្តឲ្យយើងខ្ញុំបានសិក្សាតាំងពីបឋមសិក្សា រហូតដល់ បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកពុំដែលគិតពីការនឿយហត់អ្វីឡើយ ដើម្បីផ្តល់ឱកាសយើងខ្ញុំបានទទួលចំណេះដឹងដ៏ថ្លៃថ្លា ព្រមទាំងបទពិសោធន៍ដ៏មានតម្លៃ។ មិនត្រឹមតែអ្នកមានគុណទាំងពីរជាបង្អែកប៉ុណ្ណោះ គឺថែមទាំងក្រុមគ្រួសារទាំងមូល ក៏ជាអ្នកលើកទឹកចិត្ត និងជួយជំរុញឲ្យយើងខ្ញុំបានទទួលនូវជោគជ័យនៅថ្ងៃនេះ។

– **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ហើយជាពិសេសនោះគឺលោកសាស្រ្តាចារ្យបណ្ឌិត **ឈុន ណារ៉េត** ដែលបានខិតខំយកអស់ពីកម្លាំងកាយចិត្ត ដើម្បីពន្យល់ណែនាំក្រុមយើងខ្ញុំរហូតបានចងក្រងសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

– **លោកគ្រូ អ្នកគ្រូ** ទាំងអស់ដែលជាសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងលោកគ្រូ អ្នកគ្រូ តាំងពីបឋមសិក្សា វិទ្យាល័យ ដែលបានអប់រំ បង្ហាត់បង្រៀន ដល់រូបយើងខ្ញុំក្នុងការទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើន។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមបួងសួងជូនពរ ដល់អ្នកមានគុណទាំងគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យ ដែលបម្រើការគ្រប់ជំនាញ បុគ្គលិកទាំងអស់ មិត្តរួមថ្នាក់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្ត សេដ្ឋកិច្ច សូមជួបប្រទះតែពុទ្ធពរទាំង **បួន** ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លាងឃ្លៀតឡើយ ហើយសូមប្រកបដោយសេក្តីសុខ សុភមង្គល និងជោគជ័យគ្រប់ភារកិច្ច ការងារទាំងអស់។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** .......... ១
ក. លំនាំបញ្ហា .......... ១
ខ. ចំណោទបញ្ហា .......... ២
គ. គោលបំណងនៃការស្រាវជ្រាវ .......... ២
ឃ. ដែនកំណត់ និងវិសាលភាព .......... ៣
ង. សារៈសំខាន់នៃការស្រាវជ្រាវ .......... ៣
ច. វិធីសាស្ត្រស្រាវជ្រាវ .......... ៤
ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៥

**ជំពូកទី១**

**រំលឹកទ្រឹស្តីលើការប្រើប្រាស់គ្រឿងស្រវឹង**

១.១. និយមន័យ .......... ៦
១.២. សញ្ញាណនៃគ្រឿងស្រវឹង .......... ៦
១.៣. លក្ខណៈទូទៅនៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមខ្មែរ .......... ៧
១.៤. អត្រានៃអ្នកប្រើប្រាស់គ្រឿងស្រវឹង .......... ៧
១.៥. ទិដ្ឋភាពផ្លូវច្បាប់ .......... ៨
សរុប .......... ១៥

**ជំពូកទី២**

**មូលហេតុ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមខ្មែរ**

២.១. មូលហេតុដែលនាំឲ្យមានការប្រើប្រាស់គ្រឿងស្រវឹង .......... ១៦
២.១.១.តម្លៃផលិតផលគ្រឿងស្រវឹងទាប .......... ១៦
២.១.២. ប្រព័ន្ធផ្សព្វផ្សាយ និងការលើកទឹកចិត្ត .......... ១៧
២.១.៣. កំណើននៃចំនួនក្លឹបកំសាន្ត និងកន្លែងផឹកស៊ី .......... ១៩
២.១.៤. កង្វះកន្លែងលំហែកាយ និងណាត់ជួប .......... ២១
២.១.៥. បុគ្គលខ្លួនឯង .......... ២២
២.២. ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង និងករណីសិក្សា .......... ២៣
២.២.១. សុខភាព .......... ២៣
២.២.២. គ្រោះថ្នាក់ចរាចរណ៍ .......... ២៦
២.២.៣. អំពើហិង្សាក្នុងគ្រួសារ និងសង្គម .......... ២៩
២.២.៤. ការប៉ះពាល់ដល់សីលធម៌ និងប្រពៃណីជាតិ .......... ៣២

២.២.៤.១. ប៉ះពាល់ដល់សីលធម៌ក្នុងសង្គម ........................................................ ៣២
២.២.៤.២. ប៉ះពាល់ដល់ប្រពៃណី ........................................................ ៣៤
២.២.៥. សេដ្ឋកិច្ច ........................................................ ៣៥
សរុប ........................................................ ៣៦

## ជំពូកទី៣

## ដំណោះស្រាយ និង ទិសដៅអនាគត

៣.១. វិធានការទប់ស្កាត់ និងដំណោះស្រាយ ........................................................ ៣៧
៣.១.១. កត្តាគោលនយោបាយសាធារណ: ........................................................ ៣៧
៣.១.២. កត្តាច្បាប់ ........................................................ ៣៨
៣.១.៣. កត្តារាជរដ្ឋាភិបាល ........................................................ ៤០
៣.១.៤. ការចូលរួមពីសង្គមស៊ីវិល ........................................................ ៤១
៣.១.៥ កត្តាប្រជាជន ........................................................ ៤២
៣.២. ទិសដៅអនាគត ........................................................ ៤៣
សរុប ........................................................ ៤៥
**សេចក្តីសន្និដ្ឋាន** ........................................................ ៤៦
**អនុសាសន៍** ........................................................ ៤៩
**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# សេចក្តីផ្តើម

## ក. លំនាំបញ្ហា

បច្ចុប្បន្ននេះនៅក្នុងសង្គមខ្មែរ ក៏ដូចជាសង្គមនៃប្រជាជាតិដទៃទៀតនៅលើពិភពលោកទាំងមូល បាននិងកំពុងតែទទួលរងនូវឥទ្ធិពលនៃគ្រឿងស្រវឹងដូចជា សុរា ស្រាជាដើមដែលបានធ្វើឲ្យសង្គមជាតិ និងប្រជាជនខ្លួនឯងរងនូវផលប៉ះពាល់ ទាំងសេដ្ឋកិច្ចគ្រួសារ និងសង្គម ព្រមទាំងប៉ះពាល់ដល់សុខភាពខ្លួន និងបង្ករឲ្យមានភាពស្មុគស្មាញយ៉ាងច្រើន ដល់ប្រទេសជាតិទាំងមូល។

គ្រោះថ្នាក់ចរាចរណ៍ ការបាត់បង់ស្មារតី ភាពក្រីក្រលំបាក អំពើហិង្សា បញ្ហាសុខភាព អំពើចោរកម្ម ។ល។ គឺសុទ្ធសឹងតែផ្នែកមួយកើតចេញពីការសេពនូវគ្រឿងស្រវឹងទាំងនេះ។ ការសេពគ្រឿងស្រវឹង គឺកើតឡើងពី ការចង់សាក ឬចង់ដឹងនៃមនុស្ស ការអូសទាញពីអ្នកដទៃ និងការផ្សព្វផ្សាយពីឈ្មួញរកស៊ីជាដើម។ កត្តាទាំងប៉ុន្មានដែលបានរៀបរាប់ខាងលើនេះ គឺជាកត្តាដែលជំរុញឲ្យមនុស្សមានអារម្មណ៍ចង់សេពគ្រឿងស្រវឹងនេះ។ ការសេពគ្រឿងស្រវឹងលើសពីការកំណត់បានធ្វើឲ្យអ្នកសេពផ្ទាល់ បាត់បង់ស្មារតី មិនអាចគ្រប់គ្រងខ្លួនឯងបាន ហើយធ្វើឲ្យខ្លួនហ៊ានប្រព្រឹត្តនូវអំពើអសីលធម៌ផ្សេងៗ ទៅលើបុគ្គលដទៃទៀត ដែលបានបណ្តាលឲ្យប៉ះពាល់ដល់អាយុជីវិតសណ្តាប់ធ្នាប់សង្គមព្រមទាំងធ្វើឲ្យខូចនូវទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិថែមទៀត។

ប្រទេសជាតិ ដែលអាចអភិវឌ្ឍរីកចម្រើនទៅបាន លុះត្រាតែធនធានមនុស្សរបស់ខ្លួនមានសមត្ថភាព និងសុខភាពល្អបរិបូរ តែប្រសិនបើធនធានមនុស្សទាំងនោះធ្លាក់ចូលទៅក្នុងការប្រើប្រាស់គ្រឿងស្រវឹង និងអំពើអបាយមុខទាំងអស់នោះហើយ ប្រទេសជាតិក៏មិនអាចរីកចម្រើនទៅមុខបានឡើយ។ ដូច្នេះដើម្បីធ្វើឲ្យសង្គមខ្មែរ ក៏ដូចជាយុវជននាសម័យទំនើបនេះ ជៀសឆ្ងាយផុតពីការសេពគ្រឿងស្រវឹង រាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ជាដៃគូរ និងប្រជាជនខ្លួនឯងផ្ទាល់ ត្រូវនាំគ្នាចូលរួមផ្សព្វផ្សាយ និងពន្យល់ពីភាពផលប៉ះពាល់ដែលបណ្តាលមកពីការសេពគ្រឿងស្រវឹងនេះ ទៅដល់ក្រុមគ្រួសារ មិត្តភក្តិខ្លួនឲ្យបានដឹងយល់ច្បាស់គ្រប់ៗគ្នា និងស្វែងរកដំណោះស្រាយល្អៗ ដើម្បីធ្វើឲ្យពួកយល់ហើយចៀសផុតពីការសេព ក៏ដូចជាប្រើប្រាស់នូវគ្រឿងស្រវឹងគ្រប់ប្រភេទ និងគ្រប់រូបភាព។

## ខ. ចំណោទបញ្ហា

ប្រសិនបើយើងក្រលេកមើលទៅលើឥទ្ធិពលនៃគ្រឿងស្រវឹងនាពេលបច្ចុប្បន្ននេះ ពិតជាមានលក្ខណៈស្មុគស្មាញ និងពុំមានភាពងាយស្រួលនៅក្នុងការដោះស្រាយឡើយ។ កិច្ចការនេះប្រាកដណាស់ គឺវាតម្រូវឲ្យមានការចូលរួមសហការពីភាគីដែលពាក់ព័ន្ធធ្វើការរួមគ្នា ហើយស្វែងរកនូវជម្រើស ឬគន្លឹះល្អមួយចំនួនសំរាប់ជាត្រីវិស័យឆ្ពោះទៅរកការគ្រប់គ្រងទៅលើការកើនឡើងនៃការប្រើប្រាស់គ្រឿងស្រវឹង អោយមានលក្ខណៈកាន់ល្អប្រសើរឡើង។ ដោយហេតុនេះហើយទើបឥទ្ធិពលនៃការប្រើប្រាស់គ្រឿងស្រវឹងនាពេលបច្ចុប្បន្ននេះ បានក្លាយជាបញ្ហាចោទមួយសំរាប់សង្គមខ្មែរ និងពិភពលោកធ្វើការដោះស្រាយជុំវិញបញ្ហានេះ។ មកទល់នឹងពេលនេះមានមតិ ព្រមទាំងសំណួរមួយចំនួនដែលបានលើកឡើងយ៉ាងដូច្នេះថា៖

- តើគ្រឿងស្រវឹងមានអត្ថន័យយ៉ាងដូចម្តេច? ហើយប្រភេទនៃគ្រឿងស្រវឹង និងអត្រានៃចំនួនអ្នកប្រើប្រាស់គ្រឿងស្រវឹងមានយ៉ាងដូចម្តេចខ្លះ? ហើយតើយើងគួរគ្រប់គ្រងវាតាមវិធីណា?
- តើមូលហេតុអ្វីខ្លះ ដែលនាំឲ្យមានផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង?
- ចំពោះដំណោះស្រាយ និងទិសដៅអនាគតថាតើយើងគួរមានវិធានការបែបណាខ្លះក្នុងការគ្រប់គ្រងទៅលើឥទ្ធិពលនៃការប្រើប្រាស់គ្រឿងស្រវឹងខាងលើនេះ?

ដើម្បីឆ្លើយតបទៅនឹងសំណួរទាំង ៣ ដែលបានចោទសួរឡើងនេះ យើងខ្ញុំសូមធ្វើការសិក្សា និងបកស្រាយនូវអត្ថន័យនៃគ្រឿងស្រវឹង សញ្ញាណ លក្ខណៈទូទៅ ក៏ដូចជាអត្រានៃចំនួនអ្នកប្រើប្រាស់គ្រឿងស្រវឹង (ជំពូកទី១) ព្រមទាំងបង្ហាញពីមូលហេតុ និងផលប៉ះពាល់ (ជំពូកទី២) និងវិធានការដោះស្រាយ ក៏ដូចជាទិសដៅអណាគតមានលក្ខណៈយ៉ាងណាខ្លះ (ជំពូកទី៣) ដែលជាជំពូកចុងក្រោយសំរាប់ធ្វើការសិក្សា និងបកស្រាយ។

## គ. គោលបំណងនៃការស្រាវជ្រាវ

ដូចដែលយើងបានដឹងហើយថា **ឥទ្ធិពលនៃគ្រឿងស្រវឹង** កំពុងតែបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិរបស់យើង ក៏ដូចជាក្នុងពិភពលោកទោះជាក្នុងរូបភាពបែបណាក៏ដោយ។ ហើយវាបានបង្កឲ្យមានការបាត់បង់ទ្រព្យសម្បត្តិ ពេលវេលា សីលធម៌សង្គម ហើយឈានទៅដល់ការបាត់បង់អាយុជីវិតថែមទៀត។ ប៉ុន្តែទោះបីជាសង្គមរបស់យើងកំពុងឋិតក្នុងស្ថានភាពដូចពេលបច្ចុប្បន្នដែលសំបូរទៅដោយការប្រើប្រាស់គ្រឿងស្រវឹងយ៉ាងច្រើន ពីគ្រប់ស្រទាប់វណ្ណៈក្តី ក៏យើងអាចកាត់បន្ថយបាននូវគ្រោះថ្នាក់ និងការបាត់បង់ផ្សេងៗ ដែលកើតចេញពីឥទ្ធិពលនៃគ្រឿងស្រវឹង

នេះបានតាមរយៈការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងឡាយដូចជា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ជាពិសេសការផ្សព្វផ្សាយអោយបានទូលាយនូវផលវិបាក នៃការសេពគ្រឿងស្រវឹងទៅដល់ប្រជាពលរដ្ឋ ក្នុងគោលដៅដើម្បីធ្វើឲ្យសង្គមជាតិរបស់យើងចៀសឆ្ងាយផុតពីអគ្រានៃការបាត់បង់អាយុជីវិត ការខាតបង់ទ្រព្យសម្បិត្តផ្សេងៗ ពិសេសការអភិវឌ្ឍន៍ប្រទេសដែលត្រូវការជាចាំបាច់នូវធនធានមនុស្សដែលមាននូវសុខភាព និងសមត្ថភាពល្អគ្រប់គ្រាន់។

## ឃ. វិសាលភាព និងដែនកំណត់

ការសិក្សាស្រាវជ្រាវប្រធានបទស្ដីអំពី "**ឥទ្ធិពលនៃគ្រឿងស្រវឹងក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន**" នេះមានដែនកំណត់ និងវិសាលភាពត្រឹមតែការសិក្សាស្វែងយល់ពីឥទ្ធិពលរបស់គ្រឿងស្រវឹង ព្រមជាមួយនឹងផលប៉ះពាល់របស់វាមកលើសង្គមរបស់យើងនាពេលបច្ចុប្បន្ននេះក៏ដូចជាបញ្ហាប្រឈមដែលកំពុងតែកើតមានឡើង ជាពិសេសការចូលរួមស្វែងរកដំណោះស្រាយល្អៗសំរាប់សង្គមតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ការសិក្សាជុំវិញប្រធានបទនេះពុំមានបំណងធ្វើការរិះគន់ ឬក៏បៀតបៀនទៅលើក្រុមហ៊ុនផលិតស្រាបៀរ និងអាជីវកម្មសុរាណាមួយដែលកំពុងធ្វើសកម្មភាព និងកំពុងចរាចរផលិតផលរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ។ ប៉ុន្តែយើងខ្ញុំគ្រាន់តែចង់បង្ហាញពីរបៀបនៃការទាក់ទាញ ក៏ដូចជាការផ្សព្វផ្សាយនានារបស់ក្រុមហ៊ុនស្រាបៀរក្នុងគោលដៅធ្វើឲ្យមានការចាប់អារម្មណ៍ពីសំណាក់អ្នកដែលជាវផលិតផលរបស់គេយកទៅទទួលទាន។ ម្យ៉ាងវិញទៀតប្រធានបទនេះក៏ពុំមានបំណងបង្ខិតបង្ខំដល់បុគ្គលណាមួយឡើយ គឺអាស្រ័យទៅលើឆន្ទៈបុគ្គលខ្លួនឯងផ្ទាល់ជាអ្នកគិតពិចារណា។

## ង. សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវចំពោះឥទ្ធិពលនៃគ្រឿងស្រវឹងក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ យើងខ្ញុំបានខិតខំសម្រិតសម្រាំងយ៉ាងម៉ត់ចត់ជាទីបំផុតជូនលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ក៏ដូចជាទៅដល់មិត្តៗនិស្សិតឲ្យបានជ្រាបថា តើឥទ្ធិពលនៃគ្រឿងស្រវឹងបានបង្កផលវិបាក និងផលប៉ះពាល់យ៉ាងណាខ្លះដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋខ្មែរ ព្រមទាំងមានឥទ្ធិពលយ៉ាងដូចម្ដេចមកលើសង្គមរបស់យើង។ ជាពិសេសការចូលរួមក្នុងសកម្មភាពទប់ស្កាត់ និងបង្ការតើយើងគ្រប់គ្នាគួរចូលរួមយ៉ាងណាខ្លះដើម្បីរួមចំណែកក្នុងការកាត់បន្ថយ និងគ្រោះថ្នាក់ផ្សេងៗដែលបណ្ដាលមកពីការប្រើប្រាស់ និងសេពគ្រឿងស្រវឹងនៅពេលអនាគតខាងមុខ។

## ច. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសម្រេចបាននូវកិច្ចការស្រាវជ្រាវមួយនេះឲ្យបានលេចចេញជារូបរាងឡើង ពួកយើងខ្ញុំបានខិតខំប្រមូលនូវរាល់ឯកសារ ការសែត ទស្សនាវត្តី ពីគ្រប់សារពត៌មាន ក៏ដូចជាគេហទំព័រដែលទាក់ទងនឹងប្រធានបទមួយនេះ ព្រមជាមួយការអធិប្បាយវែកញែក ដោយផ្អែកទៅលើឯកសារច្បាប់ បទដ្ឋានគតិយុត្តដែលមានការពាក់ព័ន្ធ ជាមូលដ្ឋានគ្រឹះដើម្បីធ្វើជាអំណះអំណាងលើប្រធានបទនេះ សំរាប់ធ្វើការបង្ហាញជូនដល់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ រួមទាំងមិត្តនិស្សិតទាំងអស់គ្នាឲ្យបានជ្រាបកាន់តែច្បាស់។

វិធីសាស្ត្រប្រមូលឯកសារស្រាវជ្រាវរបស់ក្រុមយើងខ្ញុំដែលបានប្រើរួមមានដូចជាៈ

- ចូលទៅបណ្ណាល័យច្បាប់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ព្រមទាំងស្នាដៃនានា ដែលពាក់ព័ន្ធជុំវិញប្រធានបទរបស់យើងខ្ញុំដែលមានតម្កល់ទុកនៅទីនោះ។
- ចូលទៅក្នុងគេហទំព័រមួយចំនួន ដែលទាក់ទងទៅនឹងឥទ្ធិពលនៃគ្រឿងស្រវឹងនាពេលបច្ចុប្បន្ន ព្រមជាមួយផលប៉ះពាល់របស់វាមកលើសង្គមខ្មែរ។

ព្រមទាំងសកម្មភាពមួយចំនួនទៀតដូចដែលមានរៀបរាប់នៅតារាងខាងក្រោមៈ

| ឈ្មោះ | ស្វែងរកឯកសារ និងការរៀបចំ | ទីកន្លែង | ថ្ងៃទទួល |
|---|---|---|---|
| ខឹម ចំរ៉ុង | រចនាគម្របមុខ | រោងពុម្ព | ៣០ មេសា ២០១៥ |
| | ឯកសារនានាពាក់ព័ន្ធនឹងប្រធានបទ | អ៊ីនធឺណែតនៅផ្ទះ | ០៤ ឧសភា ២០១៥ |
| | រៀបចំមាតិកា | ស.ភ.ន.វ.ស RULE | ១២ ឧសភា ២០១៥ |
| | រៀបចំសេចក្តីផ្តើម | នៅផ្ទះ | ១៩ ឧសភា ២០១៥ |
| | រៀបចំជំពូកទី១ | បណ្ណាល័យច្បាប់ RULE និងបណ្ណាល័យ សម្តេច ហ៊ុន សែន RUPP | ២៧ ឧសភា ២០១៥ |
| ធិន ឌីម៉ង់ | រៀបចំជំពូកទី២ | ស.ភ.ន.វ.ស RULE | ០២ មិថុនា ២០១៥ |
| | រៀបចំជំពូកទី៣ | នៅផ្ទះ | ១០ មិថុនា ២០១៥ |
| | សេចក្តីសន្និដ្ឋាន និងអនុសាសន៍ | ស.ភ.ន.វ.ស RULE | ២២ មិថុនា ២០១៥ |
| | ត្រួតពិនិត្យលើកិច្ចការរួម | ស.ភ.ន.វ.ស RULE | ២៩ មិថុនា ២០១៥ |

| | | | |
|---|---|---|---|
| រួមគ្នា | រៀបចំឯកសារជូនសាស្ត្រាចារ្យណែនាំធ្វើការពិនិត្យ និងកែតម្រូវ | ស.ភ.ន.វ.ស RULE | ០៦ កក្កដា ២០១៥ |
| **សកម្មភាពនៃការជួបប្រជុំ** | | | |
| **ចំនួននៃការប្រជុំ** | **ទីកន្លែងនៃការប្រជុំ** | **រយៈពេលនៃការប្រជុំ** | **ថ្ងៃនៃការប្រជុំ** |
| ៥ លើក | បណ្ណាល័យច្បាប់ (RULE) | ៣ ម៉ោង | ០២ ឧសភា ២០១៥ |
| | បណ្ណាល័យសម្តេច ហ៊ុន សែន (RUPP) | ៤ ម៉ោង | ១៥ ឧសភា ២០១៥ |
| | មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន (CJCC) ភ្នំពេញ | ២.៥ ម៉ោង | ៣០ ឧសភា ២០១៥ |
| | ស.ភ.ន.វ.ស (RULE) | ៤ ម៉ោង | ១៨ មិថុនា ២០១៥ |
| | បណ្ណាល័យច្បាប់ (RULE) | ៣ ម៉ោង | ០១ កក្កដា ២០១៥ |

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃប្រធានបទស្តីអំពី "**ឥទ្ធិពលនៃគ្រឿងស្រវឹងក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន**" ចែកចេញជា ៣ជំពូក គឺជំពូកទី១ ទី២ និងទី៣ ដែលក្នុងនោះរួមមាន៖ ជំពូកទី១ និយាយអំពីនិយមន័យ សញ្ញាណនៃគ្រឿងស្រវឹង លក្ខណៈទូទៅនៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមខ្មែរ អត្រានៃចំនួនអ្នកប្រើប្រាស់គ្រឿងស្រវឹងនៅប្រទេសកម្ពុជា ព្រមទាំងទិដ្ឋភាពផ្លូវច្បាប់។ ជំពូកទី២ លើកឡើងពីមូលហេតុដែលនាំឲ្យមានការប្រើប្រាស់គ្រឿងស្រវឹង និងផលប៉ះពាល់នៃការប្រើប្រាស់អមដោយមានករណីសិក្សាភ្ជាប់ជាមួយផងដែរ។ ហើយជំពូកទី៣ គឺបង្ហាញអំពីដំណោះស្រាយ និងទិសដៅអនាគត វិធានការទប់ស្កាត់ ការចូលរួមពីសង្គមស៊ីវិល និងទិសដៅអនាគត។

# ជំពូកទី១
# រំលឹកទ្រឹស្តីនៃការសិក្សាលើគ្រឿងស្រវឹងក្នុងសង្គមខ្មែរ

## ១.១ និយមន័យ

**គ្រឿងស្រវឹង** គឺជាសាធាតុរាវ ឬទឹកម្យ៉ាង ដែលមនុស្សអាចក្រេប ឬផឹក ហើយអាចធ្វើឲ្យមនុស្ស មានអារម្មណ៍ប្លែកខុសពីធម្មតា។ ពាក្យ "ស្រវឹង" បើតាមវចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត បានឲ្យនិយមន័យថា ប្រែស្មារតី ឬងោង ភ័ន្តច្រលំ វង្វេងស្មារតី ខុសពីប្រក្រតី ដោយសេពសុរាជាដើម[1]។ រីឯពាក្យ **សង្គម** វិញមានន័យថា ការជួបជុំគ្នា ការប្រជុំគ្នា ការរាប់រកគ្នា ការប្រមូលរួបរួមផ្តុំមនុស្ស ឬសត្វ[2]។

បន្ទាប់ពីធ្វើការបកស្រាយនូវពាក្យគន្លឹះខាងលើរួច យើងអាចយល់បានថា គ្រឿងស្រវឹង គឺជាទឹកម្យ៉ាង ដែលពេលដែលមនុស្សក្រេប ឬផឹកទៅច្រើន អាចធ្វើឲ្យមនុស្សវង្វេងស្មារតី ខុសប្រក្រតី បាត់បង់ម្ចាស់ការជាដើម។ រីឯពាក្យ សង្គម វិញគឺសំដៅលើ ក្រុមមនុស្សមួយក្រុម ដែលរស់នៅជួបជុំគ្នាច្រើន ដែលបង្កើតជាសង្គមមួយ។

## ១.២ សញ្ញាណនៃគ្រឿងស្រវឹង

គ្រឿងស្រវឹង គឺមានលក្ខណៈជាសាកល ដូចជាស្រាបៀរ ស្រាស ឬស្រាវីស្គីជាដើម រីឯគ្រឿងស្រវឹងខ្លះទៀតគឺមានលក្ខណៈប្លែកៗពីគ្នាទៅតាមវប្បធម៌នីមួយៗ ដូចជាសម្រាប់វប្បធម៌ខ្មែរ គឺមានទឹកត្នោតជូរ និងស្រាអាញ់ជាដើម[3]។ នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន គ្រឿងស្រវឹងមានច្រើនប្រភេទ និងមានសមត្ថភាពឥទ្ធិពលខុសៗគ្នា។ ហើយគ្រឿងស្រវឹងទាំងនោះរួមមាន ស្រាបិត ស្រាស ស្រាថ្នាំ ស្រាត្រាំ(ផ្លែឈើ) ស្រាបៀរ ស្រាវីស្គី ។ល។ គ្រឿងស្រវឹងទាំងអស់នេះ ត្រូវបានប្រើប្រាស់គ្រប់ទីកន្លែង និងគ្រប់កម្មវិធីមិនថាធំឬតូចឡើយ។ អ្នកដែលប្រើប្រាស់គ្រឿងស្រវឹងនេះច្រើនជាងគេគឺ យុវជន(ប្រុស) ចាប់ពីអាយុ ១៥ឆ្នាំឡើង មនុស្សចាស់។ គួរកត់សម្គាល់ផងដែរថានាសម័យថ្មីនេះ មិនមែនមានតែមនុស្សប្រុសទេដែលអាចទទួលទានគ្រឿងស្រវឹងនេះ ស្ត្រីវ័យជំទង់ ឬវ័យកណ្តាលមួយចំនួនក៏ចេះក្រេបគ្រឿងស្រវឹងនេះផងដែរ។

---

[1] ពុទ្ធសាសនបណ្ឌិត្យ, "*វចនានុក្រមខ្មែរ*" (ភ្នំពេញ៖ ឆ្នាំ១៩៦៧) ទំព័រ១៥៧។

[2] ពុទ្ធសាសនបណ្ឌិត្យ, "*វចនានុក្រមខ្មែរ*" (ភ្នំពេញ៖ ឆ្នាំ១៩៦៧) ទំព័រ១២៣៨។

[3] ទស្សនាវដ្តីសុខភាពយើង, *អ្នកទទួលទានគ្រឿងស្រវឹងហួសហេតុ* (ភ្នំពេញ៖ ទស្សនាវដ្តីសុខភាពយើង លេខ០៦៨ កញ្ញា ២០១១) អាចរកបាននៅ http://www.healthcambodia.com/p15821/។

## ១.៣ លក្ខណៈទូទៅនៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមខ្មែរ

បច្ចុប្បន្នការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសង្គមខ្មែរ ត្រូវបានគេមើលឃើញថាកំពុងតែទទួលបាននូវប្រជាប្រិយភាពយ៉ាងខ្លាំងសំរាប់កម្មវិធីតូចធំ និងកម្មវិធីជួបជុំផ្សេងៗ សូម្បីតែកម្មវិធីបុណ្យសាសនាមួយចំនួន ក៏ឃើញមានការប្រើប្រាស់នូវគ្រឿងស្រវឹងនេះផងដែរ។ ដោយឡែកពិធីសាសនាមួយចំនួនគេក៏បានយកគ្រឿងស្រវឹងនេះមកសែនផងដែរ តួយ៉ាងដូចជា ពិធីសែនព្រេនអ្នកតា ពិធីបុណ្យដាភូមិ ឬពិធីបញ្ចុះអារក្សជាដើម[4]។ លើសពីនេះទៅទៀត ពិធីបុណ្យជាតិផ្លូវការមួយចំនួន ក៏បានយកគ្រឿងស្រវឹងនេះយកមកប្រារព្ធពិធីផងដែរ ជាក់ស្តែងព្រះរាជពិធីច្រត់ព្រះនង្គ័ល[5] ក៏យើងសង្កេតឃើញមានការដាក់ស្រាមួយមុខផងដែរ ក្នុងចំណោមអាហារផ្សេងទៀតសម្រាប់ឲ្យគោឧសភរាជបរិភោគក្នុងគោលបំណងទស្សន៍ទាយនូវប្រផ្នូលសំរាប់ប្រទេសជាតិ ថាតើវានឹងមានកើតឡើងនូវហេតុភេទយ៉ាងណាខ្លះក្នុងបណ្តាឆ្នាំនីមួយៗនៃពិធីបុណ្យខាងលើនេះ។

និយាយជារួម ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងកម្មវិធីតូចធំ កម្មវធីជួបជុំ ពិធីសាសនា ជាពិសេសពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ ពិធីបុណ្យភ្ជុំបិណ្ឌ ក៏ក្លាយជាទម្លាប់ទៅហើយសំរាប់ប្រជាពលរដ្ឋខ្មែរ ដែលពួកគេយល់ឃើញមួយបែបស្រដៀងគ្នាទៅលើគ្រឿងស្រវឹង ដែលនឹងអាចជួយនៅក្នុងពិធីទាំងអស់នោះប្រព្រឹត្តទៅមានលក្ខណៈកាន់តែល្អប្រសើរ និងមានភាពសប្បាយរីករាយ។ ដូច្នេះផងដែរ បើទោះបីជាគ្មានកម្មវិធីបុណ្យ ឬជប់លៀងផ្សេងៗ ក៏យើងឃើញថាប្រជាពលរដ្ឋសព្វថ្ងៃ ជាពិសេសបុរសៗមួយចំនួនតែងតែបបួលគ្នាបន្ទាប់ធ្វើការងាររួចឬថ្ងៃបើកប្រាក់ខែទៅទទួលទានគ្រឿងស្រវឹងដូចជាស្រាបៀរ ឬស្រាថ្នាំ នៅតាមទីកន្លែងផ្សេងៗដើម្បីជួបជុំគ្នាសប្បាយផ្សេងៗ។

## ១.៤ អត្រានៃអ្នកប្រើប្រាស់គ្រឿងស្រវឹង

បើតាមការធ្វើការស្រាវជ្រាវ និងស្ទង់មតិរបស់ក្រុមនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្រោមការគាំទ្ររបស់អង្គការសុខភាពពិភពលោក(WHO) អង្គការចលនាដើម្បីសុខភាពកម្ពុជា និងដៃគូសុវត្ថិភាពកាលពីឆ្នាំ២០១៤បានឲ្យដឹងថា ប្រជាពលរដ្ឋពេញវ័យកម្ពុជាលើសពី ៥០ភាគរយធ្លាប់ទទួលគ្រឿងស្រវឹងក្នុងអំឡុងពេល១២ខែចុងក្រោយ(ឆ្នាំ២០១៤) បើបែងចែកតាមភេទគឺមានបុរស៧៣ភាគរយ និងស្ត្រី២៣ភាគរយ ជាអ្នកទទួលទានគ្រឿងស្រវឹងនេះ[6]។ បើតាមការស្ទង់មតិនេះ ក៏បានឲ្យដឹងថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើនចាប់ផ្តើមប្រើប្រាស់គ្រឿងស្រវឹងក្នុងវ័យជំទង់(យុវ

[4] មៀច ប៉ុណ្ណ, *កម្រងឯកសារស្តីពីប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ភាគ២* (ភ្នំពេញ៖ ឆ្នាំ២០០៨), ទំព័រ២២។

[5] លោក ឆឹង ឆាន់សុផុន, *សៀវភៅបុណ្យទំនៀមខ្មែរ ក្រាំងបុណ្យទាំង១២ខែ* (ភ្នំពេញ៖ PUC ឆ្នាំ២០០០), ទំព័រ២៥៥។

[6] អង្គការចលនាដើម្បីសុខភាពកម្ពុជា, *លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង* (ភ្នំពេញ៖ CMH ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

វ័យ) និងកុមារ មានជាង៩១ភាគរយ។ អត្រានៃការប្រើប្រាស់គ្រឿងស្រវឹងនេះ មានកំនើនកើនជាលំដាប់ ដែលបានឆ្លុះបញ្ចាំងបានថា នៅក្នុងសង្គមកម្ពុជាគ្រឿងស្រវឹងគ្រប់ប្រភេទ កំពុងតែបានទទួលការគាំទ្រជាខ្លាំងពីសំណាក់ប្រជាពលរដ្ឋកម្ពុជាទាំងប្រុសទាំងស្រី។ ផលិតផលគ្រឿងស្រវឹងនេះត្រូវបានដាក់លក់គ្រប់ទីកន្លែងនៅកម្ពុជា។

## ១.៥ ទិដ្ឋភាពផ្លូវច្បាប់

បើយើងសង្កេតមើលទៅលើទិដ្ឋភាពផ្លូវច្បាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹងក្នុងសង្គមរបស់យើងវិញគឺការគ្រប់គ្រងសំរាប់ការចរាចរគ្រឿងស្រវឹងក្នុងទីផ្សារ សេចក្តីណែនាំមួយចំនួន ក៏ដូចជាគោលនយោបាយស្តីពីការផ្សព្វផ្សាយ ការធ្វើអាជីវកម្ម និងប្រើប្រាស់គ្រឿងស្រវឹង ត្រូវបានធ្វើឡើងស្របទៅតាមបរិបទនៃកំណើនផលិតផល និងការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមរបស់យើងនាពេលបច្ចុប្បន្ននេះ។

ជាក់ស្តែងបច្ចុប្បន្ននេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពុំទាន់បង្កើតឲ្យមានច្បាប់ស្តីពីការគ្រប់គ្រងទៅលើគ្រឿងស្រវឹង ក៏ដូចជាត្រួតពិនិត្យនៅឡើយទេ។ ប៉ុន្តែយើងសង្កេតឃើញថាកម្ពុជាបានចូលរួមនៅក្នុងសន្និសីទស្តីពីគោលនយោបាយគ្រឿងស្រវឹងសកលលោក ក្រោមពាក្យស្លោក "ផ្តើមចេញពីសកម្មភាពមូលដ្ឋាន និងថ្នាក់ជាតិ ឈានទៅការផ្លាស់ប្តូរទូទាំងសកលលោក" ដែលបានប្រារព្ធឡើងនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ថ្ងៃទី៧-៩ តុលា ឆ្នាំ ២០១៣។ ដែលមានគោលបំណងជារួមគឺ " *ការបង្កើតបរិស្ថានលើកកម្ពស់សុខភាព គោលដៅស្ម័គ្រចិត្តកម្រិតសកល ក្នុងការសម្រេចឲ្យបាននូវការកាត់បន្ថយប្រហែលជា១០% ក្នុងការប្រើប្រាស់គ្រឿងស្រវឹងដែលមានលក្ខណ: នៅក្នុងបរិបទជាតិ និងការអនុម័តឲ្យមានសូចនាករនៃការប្រើប្រាស់សរុបក្នុងម្នាក់ (ដែលបានកត់ត្រា និងមិនបានកត់ត្រា) ការប្រើប្រាស់ (របស់ក្រុមមនុស្សវ័យ ១៥ ឆ្នាំឡើង) ក្នុងមួយឆ្នាំ គិតជាលីត្រនៃគ្រឿងស្រវឹងសុទ្ធ កម្រិតស្តង់ដារអាយុនៃការសេពគ្រឿងស្រវឹងច្រើនម្តងម្កាលក្នុងចំណោមយុវជន និងមនុស្សពេញវ័យ និងការរិះគន់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង និងបញ្ហាសីលធម៌ក្នុងចំណោមយុវជន និងមនុស្សពេញវ័យទាំងអស់ស្របតាមបរិបទជាតិ។"*[7]

ម្យ៉ាងវិញទៀត ច្បាប់ គោលនយោបាយ សារាចរ ក៏ដូចជាសេចក្តីណែនាំផ្សេងៗដែលពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយ ការទទួលទាន បទល្មើសបណ្តាលមកពីការសេព និងប្រើប្រាស់គ្រឿងស្រវឹងត្រូវបានដាក់ចេញឲ្យអនុវត្តទាំងនៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅដល់របៀបរៀបរយ

[7] សេចក្តីថ្លែងការណ៍ទីក្រុងសេអ៊ូល, *ស្តីពីគោលនយោបាយគ្រឿងស្រវឹងសកលលោក* (ទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ថ្ងៃទី ៧-៩ ខែតុលា ឆ្នាំ២០១៣) (សូមមើលឧបសម្ព័ន្ធ២)។

សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងកាត់បន្ថយគ្រោះថ្នាក់ដែលបង្ករឡើងដោយសារគ្រឿងស្រវឹង។

- **ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី នៃព្រះរាជាណាចក្រកម្ពុជា**

ច្បាប់ចរាចរផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី១ មាត្រា១ - មានគោលបំណងធានាសុវត្ថិភាព សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងធានាការពារសុខភាព និងអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន[8]។

មាត្រា ២- ច្បាប់នេះមានគោលដៅដូចតទៅ៖

- ផ្តល់ការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- គ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក
- ទប់ស្កាត់ការប្រព្រឹត្តបទល្មើសដែលបណ្តាលមកពីការប្រើប្រាស់ផ្លូវថ្នល់ [9]

លើសពីនេះទៅទៀត ច្បាប់នេះក៏មានកំណត់ទោសផងដែរទាក់ទិនទៅនឹងការបើកបរក្នុងស្ថានភាពស្រវឹង ជាពិសេសអ្នកដែលប្រព្រឹត្តល្មើសនូវច្បាប់ខាងលើនេះ។ តួយ៉ាងនៅក្នុងជំពូកទី១០ អំពីទោសប្បញ្ញត្តិ ត្រង់មាត្រា ៧៦ បានចែងថា - ជនណាបើកបរយានយន្តមិនព្រមបញ្ឈប់យានយន្តតាមការបញ្ជារបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកដើម្បីធ្វើតេស្តពិនិត្យជាតិអាល់កុល ឬសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ៨០០ ០០០ (ប្រាំបីសែន) រៀល។[10] និងមាត្រា ៧៧ - ជនណាបើកបរយានយន្តនៅពេលដែលខ្លួនស្ថិតនៅក្នុងភាពស្រវឹង ដោយមានជាតិអាល់កុលចាប់ពី ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៨០០ ០០០ (ប្រាំបីសែន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល។[11]
ដោយឡែក មាត្រា៨៣នៃច្បាប់នេះបានចែងថា: ជនណាបើកបរដោយធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យមានរបួសដល់អ្នកដទៃ ហើយបណ្តាលឲ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើ ឬលើសពី

[8] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, *ជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា ១* (ភ្នំពេញ៖ ៣០ ធ្នូ ២០១៤) (សូមមើលឧបសម្ព័ន្ធ១)។
[9] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, *ជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា ២* (ភ្នំពេញ៖ ៣០ ធ្នូ ២០១៤)។
[10] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, *ជំពូកទី១០ អំពីទោសប្បញ្ញត្តិ មាត្រា ៧៦* (ភ្នំពេញ៖ ៣០ ធ្នូ ២០១៤)។
[11] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, *ជំពូកទី១០ អំពីទោសប្បញ្ញត្តិ មាត្រា ៧៧* (ភ្នំពេញ៖ ៣០ ធ្នូ ២០១៤)។

៨ (ប្រាំបី) ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។ អំពើល្មើសខាងលើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល កាលបើអំពើនេះបានប្រព្រឹត្ត ក្នុងករណីណាមួយ ដូចខាងក្រោម៖

ក- បើកបរដោយគ្មានបណ្ណបើកបរ ឬមានបណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ខ- ស្ថិតក្នុងស្ថានភាពស្រវឹងដោយមានអត្រាជាតិអាល់កុលចាប់ពី ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

គ- បណ្តាលឲ្យមានរបួសមនុស្សច្រើននាក់។

ឃ- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះទោសបន្ថែម ដូចតទៅនេះអាចត្រូវបានប្រកាស៖

១- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

២- ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣- ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារពត៌មាន។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។[12]

មាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដដែលបានកំណត់ផងដែរថា: ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឲ្យស្លាប់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលានរៀល) ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល និង

[12] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, *ជំពូកទី១០ អំពីទោសប្បញ្ញត្តិ មាត្រា ៨៣* (ភ្នំពេញ៖ ៣០ ធ្នូ ២០១៤) (សូមមើលឧបសម្ព័ន្ធ ១)។

អាចត្រូវផ្តន្ទាទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។ អំពើល្មើសខាងលើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល កាលបើអំពើនេះបានប្រព្រឹត្តក្នុងករណីណាមួយ ដូចខាងក្រោម៖

ក- បើកបរដោយគ្មានបណ្ណបើកបរ ឬមានបណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ខ- ស្ថិតក្នុងស្ថានភាពស្រវឹងដោយមានអត្រាជាតិអាល់កុលចាប់ពី ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

គ- បណ្តាលឲ្យមានរបួសមនុស្សច្រើននាក់។

ឃ- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះទោសបន្ថែម ដូចតទៅនេះអាចត្រូវបានប្រកាស៖

១- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

២- ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣- ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសក្នុងសារពត៌មាន។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។[13]

- **គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព**

គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពត្រូវបានបង្កើតឡើងក្នុងគោលបំណងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់នៅក្នុងភូមិ ឃុំ/សង្កាត់ នូវទូទាំងផ្ទៃប្រទេស ហើយនឹងកំពុងត្រូវបានជំរុញ និងអនុវត្តយ៉ាងមមាញឹកជាទីបំផុត។ នៅក្នុងសន្ទរកថារបស់ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯម សំអាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក្នុងឱកាសបើកសិក្ខាសិលា ស្តីពី ***"គ្រឿងស្រវឹងនិងសុវត្ថិភាពភូមិ/ឃុំ"*** បានថ្លែងថា "បញ្ហានៃគ្រឿងស្រវឹង គឺជាប់ពាក់ព័ន្ធយ៉ាងសំខាន់នឹងបញ្ហាសន្តិសុខរបស់សហគមន៍។

[13] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, *ជំពូកទី១០ អំពីទោសប្បញ្ញត្តិ មាត្រា ៨៥* (ភ្នំពេញ៖ ៣០ ធ្នូ ២០១៤) (សូមមើលឧបសម្ព័ន្ធ ១)។

ព្រោះថាអ្នកស្រវឹង ឬអ្នកធ្វើជាស្រវឹងបានបង្ករការភ័យខ្លាចដល់ប្រជាពលរដ្ឋក្នុងភូមិដែល ពួកគេរស់នៅ" ពិតណាស់បញ្ហានៃការប្រើប្រាស់គ្រឿងស្រវឹងបានផ្សារភ្ជាប់នឹងបញ្ហាជាច្រើនដូចជា ការប្រើនូវអំពើហិង្សាក្នុងគ្រួសារ គ្រោះថ្នាក់ចរាចរណ៍ ការប្រើប្រាស់គ្រឿងញៀន ក៏ដូចជាការចាប់រំលោភសេពសន្ថវៈទៅលើស្ត្រី និងកុមារព្រមទាំងបង្កភាពចលាចលជាច្រើនទៀតក្នុងសហគមន៍។[14]

ជាក់ស្តែងសាលារាជធានីភ្នំពេញ បានប្តេជ្ញារួមគ្នាអនុវត្តន៍ គោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព ទូទាំងរាជធានីភ្នំពេញ អោយសម្រេចបាន ចេរៈភាពនូវលក្ខណៈសម្បត្តិ ៥យ៉ាង៖

១. គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ

២. គ្មានការផលិត ចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣. គ្មានអំពើអាណាចារ្យ ជួញដូរស្ត្រី កុមារ និង អំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង និងចាស់ទំនើង

៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ[15]។

ដូចនេះគោលនយោបាយនេះ ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្លា ក្នុងការធានាសន្តិសុខសុវត្ថិភាពក្នុងសហគមន៍ ជាពិសេស ភូមិ ឃុំ ដែលប្រជាពលរដ្ឋរស់នៅ។ ហើយបានបង្ករលក្ខណៈងាយស្រួលដល់ការចូលរួម និងអនុវត្តដោយផ្ទាល់ពីប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

- **សេចក្តីណែនាំ ស្តីអំពី ការហាមប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិវេនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន របស់ក្រសួងអប់រំ យុវជន និងកីឡា**

មានគោលបំណងក្នុងការពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងដែលបានផ្សព្វផ្សាយ និងកាត់បន្ថយបាតុភាពអសកម្មនានា ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងក្នុងគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅសាធារណៈ។

សេក្តីណែនាំអនុវត្តស្តីពី ការហាមប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិវេនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដូចខាងក្រោម៖

[14] សន្ទរកថារបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ឯម សំអាន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក្នុងឪកាសបើសិក្ខាសាលាស្តីពីគ្រឿងស្រវឹង និង សុវត្ថិភាពភូមិ/ឃុំ ថ្ងៃទីព្រហស្បត្តិ៍ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២ (សូមមើលឧបសម្ព័ន្ធ១)។

[15] សាលារាជធានីភ្នំពេញ, *លក្ខណៈសម្បត្តិ ៥យ៉ាង នៃគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព* (សូមមើលឧបសម្ព័ន្ធ១)

១. ហាមយកចូល និងប្រើប្រាស់គ្រឿងស្រវឹងគ្រប់ពេល ទោះក្នុងពិធីអ្វីក៏ដោយ ជាក់ស្តែង ដូចជា បុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិ ចូលឆ្នាំសកល បុណ្យឆ្លងសមិទ្ធិផល និងពិធីផ្សេងៗទៀត។

២. ហាមតាំងលក់ និងផ្សព្វផ្សាយពាណិជ្ជកម្មអំពីផលិផលគ្រឿងស្រវឹងគ្រប់ប្រភេទ នៅក្នុង បរិវេនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។

៣. លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ត្រូវបង្កើនស្មារតីយកចិត្តទុកដាក់ពង្រឹងការ អនុវត្តវិន័យ និងសីលធម៌របស់សិស្សត្រង់ប្រការ៩ ចំណុច "ខ" (សម្រាប់បឋមសិក្សា) ប្រការ៨ ចំណុច "ខ" (សម្រាប់មធ្យមសិក្សា) នៃបទបញ្ជាផ្ទៃក្នុងឲ្យបានជាប្រចាំ។

៤. លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវសហការជាមួយ ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ធ្វើការណែនាំ អប់រំ និងផ្សព្វផ្សាយសេចក្តី ណែនាំដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងគ្រប់គ្រឹះស្ថានសិក្សា សាធារណៈ និងឯកជនឲ្យបានទូលំទូលាយ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត។[16]

- **សារាចរ ស្តីពី ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង**

ដោយសារកំណើននៃការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង ដែលក្នុងពេលបច្ចុប្បន្ននេះ មាននៅតាមប៉ាណូផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង តាមវិទ្យុ និងទូរទស្សន៍។ ដែលបញ្ហាទាំងអស់ នេះមានផលប៉ះពាល់អវិជ្ជមានជាច្រើន ដែលទាក់ទងដល់បញ្ហាសុខភាព បញ្ហាការបង្ករបួសស្នាម គ្រោះថ្នាក់ចរាចរ អំពើហិង្សាក្នុងគ្រួសារ ភាពក្រីក្រ។ល។ ដូច្នេះហើយ ក្រសួងពត៌មានពិនិត្យឃើញ ថាការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនៅតាមប្រព័ន្ធផ្សព្វផ្សាយនានាក្នុងប្រទេសរួមមាន អាហ្វីស ប៉ាណូ កាសែត ទស្សនាវត្តី វិទ្យុ និងទូរទស្សន៍ នៅតែឃោសនាអូសទាញប្រជាពលរដ្ឋឲ្យសេព គ្រឿងស្រវឹងដើម្បីផ្សងយករង្វាន់ ឬសេពគ្រឿងស្រវឹងនាំមកនូវក្តីសប្បាយរីករាយ អារម្មណ៍ស្រស់ ថ្លា ឬតាមរូបភាពផ្សេងៗទៀតធ្វើឲ្យមានការភ័ន្តច្រឡំអំពីការសេពគ្រឿស្រវឹង។

ដូចនេះ ក្រសួងពត៌មាន បានចេញនូវបទបញ្ជាសម្រាប់ការផ្សាយគ្រឿងស្រវឹង ជាពិសេស ការផ្សាយតាមស្ថានីយ៍ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប និងវិទ្យុ FM ទាំងអស់ដូចខាងក្រោម៖

១. ចាប់ពីថ្ងៃចេញសារាចរនេះតទៅរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ នៅរៀងរាល់ម៉ោង ១៨:០០ នាទី ដល់ម៉ោង ២០:០០ នាទី រាល់ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង គឺតម្រូវឲ្យផ្សាយតែ

[16] ក្រសួងអប់រំ យុវជន និងកីឡា, *សេចក្តីជូនដំណឹងលេខ១៨ សណន ស្តីពីការហាមប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិវេន គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន*(ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១) (សូមមើលឧបសម្ព័ន្ធ១)។

Logo ផលិតផល និងអក្សរជាឈ្មោះផលិតផលតែប៉ុណ្ណោះ ឬ អានឈ្មោះផលិតផល ហើយស្ពត ពាណិជ្ជកម្មត្រូវបានហាមឃាត់។

២. ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ តទៅរៀងរាល់វេលាម៉ោង១៨:០០នាទី ដល់ម៉ោង ២០:០០ នាទី គឺពុំអនុញ្ញាតជាដាច់ខាតឲ្យផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងទេ ទោះជាការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនោះភ្ជាប់មកជាមួយកម្មវិធីពត៌មាន ការប្រគុំតន្ត្រី ការប្រកួតកីឡា ការកំសាន្ត បទចម្រៀង KARAOKE ដែលឧបត្ថម្ភដោយក្រុមហ៊ុនផលិត ឬ ចែកចាយគ្រឿងស្រវឹងក៏ដោយ។

៣. បណ្តាក្រុមហ៊ុនផលិតផល ឬ ចែកចាយគ្រឿងស្រវឹងទាំងអស់ចាប់ពីពេលនេះតទៅក្នុងការផលិតស្ពតពាណិជ្ជកម្មត្រូវតែយកចិត្តទុកដាក់ខ្ពស់លើកខ្លឹមសារ និង រូបភាពដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានទាំងឡាយដូចខាងលើ គិតគូរដល់សុវត្ថិភាពសង្គម និង ប្រយោជន៍ដល់ប្រជាពលរដ្ឋ។

៤. គ្រប់ប្រព័ន្ធឃោសនាទាំងអស់ចាប់ពីពេលនេះតទៅត្រូវបន្តអនុវត្តដោយម៉ឺងម៉ាត់សេចក្តីណែនាំរបស់ក្រសួងពត៌មានលេខ១៣៨ព.ម ចុះថ្ងៃទី០២/កុម្ភៈ/២០១០ សេចក្តីណែនាំលេខ ១៧៦០ ព.ម ចុះថ្ងៃទី០៩/ធ្នូ/២០១១ និងសេចក្តីណែនាំលេខ១៥២៧ ព.ម ចុះថ្ងៃទី០៨/តុលា/២០១២ ស្តីពីការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។

ក្រសួងពត៌មាន នឹងធ្វើការត្រួតពិនិត្យមើលការអនុវត្តសារាចរនេះ ករណីរឹងរូសមិនអនុវត្ត ក្រសួងពត៌មាននឹងធ្វើការដកហូតអាជ្ញាប័ណ្ណ ផ្អាកការធ្វើអាជីវកម្មប្រព័ន្ធផ្សព្វផ្សាយ ហើយក្រុមហ៊ុនផលិត ឬ ចែកចាយគ្រឿងស្រវឹងនោះ នឹងត្រូវហាមឃាត់មិនឲ្យធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មបន្តទៅទៀតតាមប្រព័ន្ធឃោសនាឡើយ។[17]

- **សេចក្តីជូនដំណឹង បន្ថែមពីលើសារាចរលេខ ៥៩២ ព.ម.សរចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ស្តីពីការ "ផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង" ដដែលរបស់ក្រសួងពត៌មាន ជាអាទិ៍:**

ដោយក្រសួង បានធ្វើការក្រែនរំលឹកដល់ស្ថានីយវិទ្យុ និងទូរទស្សន៍ទាំងអស់ជាថ្មីម្តងទៀត ចំពោះការអនុវត្តអោយបានមឹងម៉ាត់ តាមចំនុចដូចដែលមានចែងក្នុងសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់បំផុត។ ប្រសិនបើស្ថានីយវិទ្យុ និងទូរទស្សន៍ណាមួយ នៅតែបន្តផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង ល្មើសនឹងខ្លឹមសារក្នុងសារាចរនេះជាបន្តទៀត ក្រសួងពត៌មាន នឹងផ្អាកការផ្សាយ

[17] ក្រសួងពត៌មាន, *សារាចរ ស្តីពីការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង លេខ៥៩២ ពម.សរ* ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ (សូមមើលឧបសម្ព័ន្ធ១)។

របស់ស្ថានីយ៍នោះជាបណ្តោះអាសន្នចាប់ពី២សប្តាហ៍ រហូតដល់១ខែ ហើយឈានដល់ការដកហូតអាជ្ញាប័ណ្ណទាំងស្រុងពីស្ថានីយនោះ ប្រសិនបើនៅតែពុំរាងចាល[18]។

សរុបមកយើងសង្កេតឃើញថា គ្រឿងស្រវឹងបាននឹងកំពុងមានវត្តមាន និងត្រូវបានប្រើប្រាស់នៅក្នុងសង្គមខ្មែរតាំងពីសម័យបុរាណ រហូតដល់សម័យបច្ចុប្បន្ននេះ។ ការប្រើប្រាស់គ្រឿងស្រវឹងនេះបានវិវត្តទៅតាមជីវភាពរស់នៅ និងសម័យកាលរបស់មនុស្ស។ គ្រឿងស្រវឹងនេះមានច្រើនប្រភេទ និងច្រើនរសជាតិ ហើយអ្នកទទួលទានមានចំណង់ចំណូលចិត្ត និងប្រើប្រាស់គ្រឿងស្រវឹងនេះទៅតាមស្ថានភាព និងពេលវេលា។ ប្រសិនបើយើងមើលអំពីទិដ្ឋភាពច្បាប់នៅកម្ពុជាវិញ គឺពុំទាន់មានច្បាប់ណាមួយដែលស្តីអំពីការគ្រប់គ្រង និងត្រួតពិនិត្យគ្រឿងស្រវឹងនេះនៅឡើយទេ ប៉ុន្តែច្បាប់ សារាចរ សេចក្តីជូនដំណឹង សេចក្តីណែនាំ និងគោលនយោបាយសាធារណៈមួយចំនួនក៏បាននិយាយទាក់ទងនឹងគ្រឿងស្រវឹងនេះ និងផ្តន្ទាទោសដល់ជនណាដែលប្រព្រឹត្តបទល្មើសក្នុងស្ថានភាពស្រវឹងផងដែរ។ បើក្រលេកមើលពីចំនួនអ្នកប្រើប្រាស់វិញ យើងឃើញថាចំនួនអ្នកប្រើប្រាស់គ្រឿងស្រវឹងនេះ កំពុងតែមានការកើនឡើនគួរឲ្យកត់សម្គាល់ផងដែរនៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ ជាពិសេសក្នុងស្រទាប់យុវវ័យ ដែលជាទំពាំងស្នងឫស្សីសំរាប់ប្រទេសជាតិ។ ហើយកំនើននៃអ្នកប្រើប្រាស់គ្រឿងស្រវឹងនេះ បានក្លាយជាក្តីបារម្ភមួយសំរាប់រាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ។

[18] ក្រសួងព័ត៌មាន, *សេចក្តីជូនដំណឹង លេខ០០៣០ ព.ម* ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៥ (សូមមើលឧបសម្ព័ន្ធ១)

# ជំពូកទី២

# មូលហេតុ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គម

ជាក់ស្តែងគ្រឿងស្រវឹងនេះ គឺជាដើមចមដែលបង្កឲ្យមានអ្នកស្លាប់ក្នុងពិភពលោកប្រមាណ ២.៥ លាននាក់ក្នុងមួយឆ្នាំៗ និងបង្ករឲ្យមានជម្ងឺជាច្រើនមុខផងដែរ តួយ៉ាងដូចជាជម្ងឺមហារីកបំពង់អាហារ រលាកថ្លើម ជម្ងឺលើសសំពាធឈាម ក្រិនថ្លើម ព្រមទាំងជម្ងឺជាច្រើនផ្សេងៗទៀត។ ក្រៅពីនេះទៀត គ្រឿងស្រវឹងគឺជាដើមហេតុដែលបង្កើតឲ្យមាននូវគ្រោះថ្នាក់ចរាចរណ៍ ការបាត់បង់សណ្តាប់ធ្នាប់សង្គម អំពើហិង្សាក្នុងគ្រួសារ ព្រមទាំងបញ្ហាផ្សេងៗជាច្រើនទៀត ដែលកើតឡើងនៅក្នុងសង្គម និងពិភពលោកទាំងមូល[19]។ ដើម្បីជ្រាប់ឲ្យកាន់តែច្បាស់អំពីមូលហេតុ ក៏ដូចផលប៉ះពាល់ដែលបណ្តាលមកពីការទទួលទានគ្រឿងស្រវឹងនេះ យើងខ្ញុំសូមលើកនូវចំនុចគោលៗមួយចំនួនយកមកធ្វើការបកស្រាយដូចតទៅៈ

## ២.១ មូលហេតុដែលនាំឲ្យមានការប្រើប្រាស់គ្រឿងស្រវឹង

### ២.១.១ តម្លៃផលិតផលគ្រឿងស្រវឹងទាប

នៅប្រទេសកម្ពុជា ផលិតផលគ្រឿងស្រវឹងដូចជាស្រាបៀរ ស្រាថ្នាំ ស្រាបិត ស្រាក្រឡុក ស្រាវីស្គី។ល។ គឺជាមានតម្លៃទាបជាងគេបន្ទាប់ពីបន្ទាប់ពីប្រទេសឡាវនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ បើប្រៀបធៀបតម្លៃនៃផលិតផលគ្រឿងស្រវឹងនៅប្រទេសកម្ពុជា គឺមានតម្លៃថោកជាងបណ្តាប្រទេសជិតខាងមួយចំនួនរហូតដល់ទីបីឬបួនដងឯនោះ។ ដោយសារតែតម្លៃទាបបែបនេះហើយដែលបានទាក់ទាញឲ្យមានអ្នកប្រើប្រាស់កាន់តែច្រើនឡើង និងទទួលបានការគាំទ្រលើសលុប។ ផលិតផលស្រាបៀរ ស្រាវីសស្គីជាច្រើនប្រភេទ ត្រូវបានដាក់ឲ្យចរាចរណ៍នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ហើយផលិតផលស្រាបៀរទាំងនោះមានតម្លៃទាប[20] និងអាចធ្វើឲ្យពលរដ្ឋគ្រប់វ័យ គ្រប់វណ្ណៈ អាចជាវយកមកទទួលទានបាន។ បើតាមប្រសាសន៍របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានឲ្យដឹងថា "អ្នកផឹកមួយដប ឬមួយកំប៉ុង ត្រូវបង់ចូល

---

[19] បាល់ សុង, *បញ្ហាគ្រឿងស្រវឹងបានក្លាយជាប្រធានបទសំខាន់នៅក្នុងកិច្ចប្រជុំពិភាក្សាតុមូល ស្តីពីសុវត្ថិភាពចរាចរណ៍ក្នុងប្រទេសកម្ពុជា* (ភ្នំពេញៈ AKP ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤) (សូមមើលឧបសម្ព័ន្ធ២)។

[20] ភិរុណ ឧត្តម, ហេតុអ្វីបុរសខ្មែរចូលចិត្តគ្រឿងស្រវឹង? (ភ្នំពេញៈ គេហទំព័រសារព័ត៌មានថ្មីៗ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥)។

រដ្ឋ៣០ភាគរយលើការពន្ធអាករបន្ថែមដោយសារតែយើងអនុវត្តនូវតម្លៃបន្ថែមនិងអាករពិសេស[21]។ បើយើងក្រលេកមើលពន្ធនៃការលក់ស្រានៅប្រទេសម៉ាឡេស៊ីវិញ យើងឃើញថាមានតម្លៃថ្លៃជាងតម្លៃស្រាបៀនៅប្រទេសកម្ពុជា។ ស្រាបៀរនៅប្រទេសកម្ពុជា មួយកំប៉ុងធម្មតាមានតម្លៃ ២០០០រៀល ខណៈស្រាបៀរនៅប្រទេសម៉ាឡេស៊ីមានតម្លៃ ៨ដុល្លារ[22] ឬ១៦០០០រៀល ក្នុងមួយកំប៉ុង។ មិនត្រឹមតែប៉ុណ្ណោះ ពេលខ្លះក្រុមហ៊ុនស្រាបៀរមួយចំនួនតែងលក់បញ្ចុះតម្លៃផលិតផលខ្លួន ឬថែមជូនស្រាបៀរ ឬរង្វាន់ផ្សេងៗទៀត។ ឧទាហរណ៍ ក្នុងកម្មវិធីពិសេសរបស់ក្រុមហ៊ុន អតិថិជនជាវស្រាបៀរពីរកេស ថែមជូនមួយកេសជាដើមក៏មានដែរ។

## ២.១.២ ប្រព័ន្ធផ្សព្វផ្សាយ និងការលើកទឹកចិត្ត

ដូចយើងឃើញស្រាប់ហើយ រៀងរាល់ថ្ងៃនេះ នៅលើកញ្ចក់ទូរទស្សន៍ ក៏ដូចជាតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ពាណិជ្ជកម្មគ្រឿងស្រវឹងមានផ្សាយស្ទើរគ្រប់ពេលវេលា និងជារៀងរាល់ថ្ងៃ។ មិនត្រឹមតែប៉ុណ្ណោះ ពាណិជ្ជកម្មគ្រឿងស្រវឹងខ្លះ មានលក្ខណៈញុះញង់[23] និងលើកទឹកចិត្តឲ្យអ្នកទស្សនាមានអារម្មណ៍ចង់សាក ចង់ក្រេប និងចង់ពិសារជាដើម។ ពាណិជ្ជកម្មទាំងអស់នេះបាន និងកំពុងតែជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ប្រជាពលរដ្ឋ មិនថាក្មេងចាស់ប្រុសស្រី និងគ្រប់ទីកន្លែង។ ពាណិជ្ជកម្ម ស្រាបៀរ និងគ្រឿងស្រវឹងមួយចំនួនទៀត បានយកតារាសម្តែងក្មេងៗ និងល្បីៗ យកមកផ្សព្វផ្សាយផលិតផលរបស់ខ្លួន បែបអារម្មណ៍ស្រស់ថ្លា សប្បាយរីករាយ និងមានមោទនៈភាពជាតិនៅពេលដែលបានទទួលទានផលិតផលខ្លួន។ កត្តាទាំងអស់នេះហើយដែលជំរុញ និងលើកទឹកចិត្តយុវវ័យក្មេងៗកម្ពុជាមួយចំនួនធំឲ្យមានអារម្មណ៍ចង់សាក និងធ្វើតាមតារាក្មេងៗក្នុងពាណិជ្ជកម្មនោះ។ តាមរយៈពាណិជ្ជកម្មមួយចំនួនបានផ្សព្វផ្សាយជាលក្ខណៈលើកទឹកចិត្តឲ្យអ្នកទទួលទានមានអារម្មណ៍អស្ចារ្យ ក្លាហាន និងជំរុញលើកទឹកចិត្តឲ្យហ៊ានធ្វើអ្វីគ្រប់បែបយ៉ាង។ ឧទាហរណ៍ជាក់ស្តែង ពាណិជ្ជកម្មស្រាបៀរមួយ បានយកបុរសម្នាក់រាងសង្ហា ដើរតួអ្នកជំនួញវ័យក្មេង និងជាមនុស្សជោគជ័យម្នាក់[24]។ នៅពេលធ្វើដំណើរ បុរសម្នាក់នេះដើរដោយមានភាពក្លាហាន ជឿជាក់ និងមោះមត់ អមដោយរូបភាព ដែលមានកាន់កែវស្រាបៀរនៅក្នុងដៃ ដែលបង្ហាញពីភាពអស្ចារ្យរបស់ខ្លួនជាមួយស្រាបៀរនោះ។ ដូច្នេះពាណិជ្ជកម្មមួយនេះ បានសបញ្ជាក់ថា អ្នកដែលទទួលទាន

---

[21] សុខ គគ្គី, *នាយករដ្ឋមន្ត្រី ជំរុញឲ្យក្រុមហ៊ុនផលិតស្រាបៀរក្នុងស្រុក បង្កើនការនាំចេញទៅបរទេស*(ភ្នំពេញៈCEN ១៤ ឧសភា ២០១២) (សូមមើលឧបសម្ព័ន្ធ២)។

[22] http://www.tripadvisor.com/ShowTopic-g298570-i7008-k4823552-Why_is_the_beer_so_expensive-Kuala_Lumpur_Wilayah_Persekutuan.html (ចូលទស្សនាថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥)។

[23] គី សុខលីម, *ហេតុអ្វីបានជាយុវជនរួមភេទ និងសេពគ្រឿងស្រវឹងនៅវ័យក្មេង?*, (ភ្នំពេញៈ វិទ្យុបារាំងRFI ថ្ងៃ០៣ ខែកញ្ញា ឆ្នាំ២០១២) (សូមមើលឧបសម្ព័ន្ធ២)។

[24] ពាណិជ្ជកម្មផលិតផលស្រាបៀរមួយ វេលាម៉ោង០៨ព្រឹក, (ភ្នំពេញៈ ប៉ុស្តិ៍បាយ័ន្ត ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥)។

ប្រភេទនៃស្រាបៀរមួយនេះ ពិតជាធ្វើឲ្យមានអារម្មណ៍ដូចទៅនឹងពាណិជ្ជកម្មដែលបានផ្សព្វផ្សាយនេះមែន។ ម៉្យាងវិញទៀត បទចម្រៀងខ្លះដែលអ្នកនិពន្ធមួយចំនួននាសព្វថ្ងៃនេះបានតាក់តែងនិពន្ធឡើងសំរាប់ច្រៀង ដែលមានលក្ខណៈជំរុញ ឬលើកទឹកចិត្តឲ្យយុវវ័យសម័យនេះ ចាប់យកគ្រឿងស្រវឹងជាការកំសាន្ត ឬការបំបាត់ទុក្ខជាដើម។ ជាក់ស្តែងបទចម្រៀងដែលមានចំណងជើងថា **"មកផ្ញើអី បើមកមិនផឹក!"**[25] ដែលមានលក្ខណៈជំរុញ ឲ្យយុវជននៅតាមទីជនបទ នាំគ្នាចាប់យកស្រាថ្នាំ ឬស្រាបៀរផ្សេងៗ យកមកផឹកពេលជួបជុំគ្នា ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរនាឆ្នាំ២០១៣កន្លងទៅនេះ។ មិនមែនមានតែបទចម្រៀងមួយបទនេះទេ ដែលមានអត្ថន័យច្រៀងឲ្យអ្នកស្តាប់ទទួលទានគ្រឿងស្រវឹងនោះទេ បទចម្រៀងមួយចំនួនជាច្រើនផ្សេងទៀត ក៏បានថតនូវទស្សនីយ៍ភាពតារាសម្តែងវ័យក្មេង ទាំងប្រុស ទាំងស្រី នាំគ្នាគៀកកើយគ្នា ផឹកស្រាជល់កែវគ្នា រាំឱបគ្នា ក្នុងក្លឹបជាដើម។ ដែលអាចជះឥទ្ធិពល និងជម្រុញឲ្យយុវវ័យក្មេងៗដ៏ទៀត ឲ្យធ្វើត្រាប់តាមខ្លួនដែលជាតារាសម្តែងក្នុងបទចម្រៀងនេះ។ បើសិននិយាយពីការប្រគុំតន្ត្រី កម្មវិធីប្រកួតកីឡា កម្មវិធីសិល្បៈមួយចំនួនធំត្រូវបានក្រុមហ៊ុនគ្រឿងស្រវឹងធំៗមួយចំនួនបានឧបត្ថម្ភផ្តាច់មុខ ហើយលើកស្លាកសញ្ញាក្រុមហ៊ុនពាណិជ្ជកម្ម ឬផលិតផលខ្លួនទាំងផ្ទាំងៗនៅលើឆាក ឬនៅតាមទីកន្លែងប្រារព្ធកម្មវិធីនោះ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងកម្មវិធីប្រគុំតន្ត្រីមិនថានៅក្នុងរាជធានីភ្នំពេញ ឬនៅតាមបណ្តាខេត្តនានា យើងសង្កេតឃើញថាក្រុមហ៊ុនគ្រឿងស្រវឹងទាំងនោះបានដាក់ជាស្តង់លក់ផលិតផលខ្លួនឲ្យប្រជាពលរដ្ឋ ឬអ្នកចូលទស្សនាបានទទួលទានផលិតផលរបស់ខ្លួនផងដែរ។ ទិដ្ឋភាពទាំងអស់នេះហើយ ដែលបានជំរុញឲ្យប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានចាប់យកគ្រឿងស្រវឹងយកមកទទួលទាន។ ក្រលេកមើលយុវវ័យខ្មែរសម័យថ្មីនេះចូលចិត្តធ្វើអ្វីប្លែកៗ តាមតារាសម្តែង តារាចម្រៀងល្បីៗទាំងនោះ តាមគ្រប់រូបភាព ទាំងការស្លៀកពាក់និងសម្ភារៈ។ ការថតស្ប៉តពាណិជ្ជកម្មគ្រឿងស្រវឹងមួយចំនួនធំ តែងតែយកតារាវ័យក្មេង យកមកថតផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹងរបស់ខ្លួន ដែលមានលក្ខណៈជម្រុញនិងលើកទឹកចិត្តដល់យុវវ័យខ្មែរឲ្យទទួលទានគ្រឿងស្រវឹងដូចដែលតារាៗទាំងនោះសម្តែងក្នុងស្ប៉តពាណិជ្ជកម្មនេះដែរ។ ការផ្សព្វផ្សាយពាណិជ្ជកម្មបែបនេះហាក់បីដូចជាកំពុងតែបំពុលបរិយាកាសក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះណាស់ ដែលធ្វើឲ្យពលរដ្ឋខ្មែរទាំងចាស់ទាំងក្មេង ទាំងប្រុសទាំងស្រី ចាប់យកគ្រឿងស្រវឹងដាក់មុខនៅគ្រប់កម្មវិធីមិនថាតូចធំឡើយ។ និយាយពី ការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងដែលលើកទឹកចិត្ត ដែលផ្តល់នូវរង្វាន់ដល់អ្នកលក់ និងអ្នកទទួលទានផលិតផលគ្រឿងស្រវឹងរបស់ក្រុមហ៊ុនខ្លួនផងដែរ។ ការផ្តល់រង្វាន់នេះ គឺជាការជុំរុញលើកទឹកចិត្ត ដល់អ្នកទទួលទានឲ្យមានទឹកចិត្តទទួលទានស្រាបៀរ នឹងអាចមានឱកាសឈ្នះនូវ

---

[25] គុង សុប្រាជ្ញ, *អ្នកនិពន្ធមួយចំនួនកំពុងរក់នឹងការតែងចម្រៀងបែបជំរុញឲ្យយុវជនជំនាន់ក្រោយមានជំនាញខាងផឹកស្រា* (ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣) (សូមមើលឧបសម្ព័ន្ធ២)។

រង្វាន់ផ្សេងៗយកមកវិញ។ ដោយឃើញមានការផ្តល់រង្វាន់បែបនេះ អ្នកប្រើប្រាស់គ្រឿងស្រវឹងមួយចំនួនបាន និងកំពុងខិតខំព្យាយាមទិញ ឬលក់ផលិតផលគ្រឿងស្រវឹង ដែលមានរង្វាន់នោះយកមកទទួលទានក្នុងគោលបំណង ចំណេញផង សប្បាយរីករាយផង និងចង់ឈ្នះបានរង្វាន់ផង។ ឧទាហរណ៍ ក្រុមហ៊ុនស្រាបៀរជាតិមួយ បានផ្សព្វផ្សាយក្នុងពាណិជ្ជកម្មខ្លួនថា ក្រុមហ៊ុនខ្លួនបង្កើតកម្មវិធីពិសេសមួយ ដែលផ្តល់រង្វាន់ដល់អ្នកទទួលទានមាននូវដូចជាឡាន ម៉ូតូ ទូរស័ព្ទទំនើបៗ រង្វាន់ប្រាក់លាន និងរង្វាន់ផ្សេងៗជាច្រើនទៀត។ រង្វាន់ទាំងអស់នោះមាននៅលើក្រវិលកំប៉ុងស្រាបៀរ ឬគំរបដបរបស់ខ្លួន ឬអ្នកទទួលទានអាចសរសេរឆ្នោតផ្សងសំណាងដែលមាននៅក្នុងកេសផលិតផលទាំងនោះរួចយកទៅដាក់ក្នុងធុងឆ្នោតដែលនៅជិតខ្លួន។ នៅពេលដែលអ្នកទទួលទានបើកក្រវិលកំប៉ុងស្រាបៀរ ពួកគេនឹងឃើញរូបសញ្ញារង្វាន់ ហើយពួកគេអាចយកមកប្តូរយករង្វាន់នៅតាមដេប៉ូចែកចាយ និងក្រុមហ៊ុន។ ទំរាំតែទទួលបានរង្វាន់នេះ អ្នកទទួលទានស្រាបៀរនេះបានចំនាយថវិកាអស់រាប់សិបម៉ឺនរៀល ហើយមិនត្រឹមតែប៉ុណ្ណោះ សុខភាពរបស់អ្នកទទួលទាននេះក៏កាន់តែធ្លាក់ចុះផងដែរ ពោលទំរាំតែបានឡាន ឬម៉ូតូជិះពីក្រុមហ៊ុនស្រាបៀរនោះសុខភាពរបស់អ្នកកាន់តែដុនដាបទៅៗ។ បើតាមលទ្ធផលនៃការស្ទង់មតិប្រជាពល រដ្ឋស្តីអំពីគ្រឿងស្រវឹងរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជា(CMH) បានឲ្យដឹងថាប្រជាពលរដ្ឋកម្ពុជាទទួលឥទ្ធិពលពីការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងក្នុងការជ្រើសរើសម៉ាកនៃគ្រឿងស្រវឹងក្នុងនោះ ៣៨ភាគរយដោយសាររសជាតិឆ្ងាញ់ ២៨ភាគរយដោយសារ ម៉ាកល្បី១៦ភាគរយដោយសារតែតម្លៃថោក និង១១ភាគរយដោយសារចង់បានរង្វាន់[26]។ ហេតុផលទាំងអស់នេះសុទ្ធតែជាការទាក់ទាញដែលគេប្រើក្នុងការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។

### ២.១.៣ កំណើននៃចំនួនក្លឹបកំសាន្ត និងកន្លែងផឹកស៊ី

វត្តមាននៃក្លឹបកំសាន្ត និងកន្លែងផឹកស៊ីកំពុងតែមានការកើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន។ ក្លឹបកំសាន្តខ្លះ គឺមានច្បាប់អនុញ្ញាតបើកធ្វើអាជីវកម្មត្រឹមត្រូវស្របតាមច្បាប់ និងមួយចំនួនទៀតគឺគ្មានច្បាប់អនុញ្ញាតនោះទេ។ ប៉ុន្តែយើងសង្កេតឃើញថាក្លឹបកំសាន្តទាំងអស់នោះ គឺបើកបម្រើឲ្យមនុស្សចូលកំសាន្តគ្រប់រូបភាព ក្នុងនោះក៏មានការទទួលទានគ្រឿងស្រវឹងរួមបញ្ចូលផងដែរ។ អ្នកចូលទៅក្លឹបកំសាន្ត ភាគច្រើនគឺជាយុវវ័យ ខ្លះទៀតមានអាយុក្រោម២០ឆ្នាំ និងខ្លះជាសិស្សសាលាទៀតផង។ ឧទាហរណ៍ជាក់ស្តែងមួយ ក្លឹបកំសាន្តដែលមានទីតាំងក្នុងផ្សារទំនើបមួយ បានបើកឲ្យសិស្សានុសិស្ស ដែលមានអាយុក្រោម១៨ឆ្នាំចូលផឹកស៊ី រាំលេងកំសាន្ត

[26] អង្គការចលនាសុខភាពដើម្បីកម្ពុជា, *លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង* (ភ្នំពេញ៖ អង្គការចលនាសុខភាពដើម្បីកម្ពុជា២០១៤ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

ទាំងកណ្តាលថ្ងៃ។ អ្នកចូលលេងកំសាន្តនៅក្នុងក្លឹបកំសាន្តនេះភាគច្រើនគឺជាយុវវ័យ មានទាំងប្រុស ទាំងស្រី។ ពួកគេរមែងតែងតែនាំគ្នាក្រេបគ្រឿងស្រវឹង មានដូចជាស្រាក្រឡុក ស្រាបៀរ ស្រាក្រហមជាដើម។ មជ្ឈដ្ឋានជាច្រើនបានធ្វើការរិះគន់ និងស្នើឲ្យអាជ្ញាធរចុះមកធ្វើការត្រួតពិនិត្យ និងមានវិធានការទៅលើក្លឹបកំសាន្តនេះ។ ខាងក្រោមនេះ គឺជាការលើកបញ្ហាពីក្លឹបកំសាន្តមួយដែលបើកនាពេលថ្ងៃ ឲ្យសិស្សានុសិស្សក្មេងៗចូលមកកំសាន្តៈ

<u>ករណីសិក្សាៈ</u>

**ក្លឹបកំសាន្ត Fever ក្នុងផ្សារផេនស៊ីល កំពុងតែអូសទាញសិស្សសាលា និងក្រុមក្មេងស្ទាវ ក្នុងរាជធានីភ្នំពេញ**

ក្លឹបកំសាន្ត Fever ដែលមានទីតាំងនៅក្នុងផ្សារផេនស៊ីលមាត់ទន្លេ បានទាក់ទាញសិស្សសាលាដែលមានអាយុក្រោម១៨ឆ្នាំ ចូលមកកំសាន្ត និងផឹកស៊ីទាំងកណ្តាលថ្ងៃ។ គេឃើញថាមានយុវសិស្សក្មេងៗទាំងប្រុស ទាំងស្រី នាំគ្នាពពាក់ពពូនគ្នាទៅផឹកស៊ី រាំលេងកំសាន្តយ៉ាងសប្បាយរីករាយ។ យុវសិស្សក្មេងៗទាំងនោះ តែងតែមកកំសាន្តនៅក្លឹបនេះ រៀងរាល់ថ្ងៃសុក្រ សៅរ៍ និងអាទិត្យ ដែលមួយចំនួនបានគេចសាលាមិនចូលរៀន បែរមកចូលកំសាន្ត ផឹកស៊ីនៅក្លឹបនេះ។ នេះបើតាមលើកឡើងពីអាជីវករលក់ដូរនៅក្នុងផ្សារនេះ។ អ្នកដែលចូលកំសាន្តនេះ តែងតែចំណាយប្រាក់ចាប់ពី ៣ដុល្លារ ទៅដល់រាប់សិបដុល្លារ ដើម្បីទទួលទានគ្រឿងស្រវឹង ដូចជាស្រាបៀរ ស្រាក្រឡុក ឬស្រាក្រហមជាដើម។ អ្នករត់តុនៅទីនោះបានឲ្យដឹងថា មនុស្សដែលចូលចិត្តមករាំលេងនៅទីនេះ ភាគច្រើនជាសិស្សសាលា មានទាំងប្រុស ទាំងស្រី ស្ទាវៗ មានអាយុក្រោម២០ឆ្នាំ។ ពួកគេបាននាំសង្សារចូលមកផឹកស៊ី អង្គុយនៃបនិត្យ និងរាំឱបគ្នា ជារៀងរាល់ថ្ងៃ និងយប់ ជាពិសេសបើថ្ងៃសុក្រ សៅរ៍ និង ថ្ងៃអាទិត្យវិញ គឺមានមនុស្សចូលច្រើនជាងថ្ងៃធម្មតាព្រោះមានកម្មវិធីពិសេសៗ ដូចជាការប្រគុំតន្ត្រីជាដើម[27]។ យុវសិស្សទាំងនេះ ដែលភាគច្រើនបាននាំគេចវេសមិនទៅសាលារៀន បែរជាមករាំកំសាន្តផឹកស៊ីនៅទីនេះ។ អាណាព្យាបាលសិស្សជាច្រើន កំពុងតែព្រួយបារម្ភពីបញ្ហានេះ ហើយបានសំណូមពរដល់សាលាខណ្ឌដូនពេញ ចេញវិធានការទប់ស្កាត់ ឬចុះទៅត្រួតពិនិត្យក្លឹបកំសាន្តនេះ ដើម្បីចាត់វិធានការឲ្យម្ចាស់ហាងនេះ មិនអនុញ្ញាតឲ្យសិស្ស ឬក្មេងដែលមិនទាន់គ្រប់អាយុឲ្យចូលក្នុងក្លឹបនេះ។

លើសពីនេះទៅទៀត កន្លែងអស់នោះតែងតែបង្កើតឲ្យមានកម្មវិធីប្លែកៗ និងកម្មវិធីចាប់រង្វាន់បញ្ចុះតម្លៃផលិតផលគ្រឿងស្រវឹងផ្សេងៗ ក្នុងគោលបំណងទាក់ទាញឲ្យមានអតិថិជនចាប់

[27] លោក វិសាល, *ក្លឹបកំសាន្ត Fever ក្នុងផ្សារផេនស៊ីល កំពុងតែអូសទាញសិស្សសាលា និងក្រុមក្មេងស្ទាវ* (ភ្នំពេញៈ គេហទំព័រCNE ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១២) (សូមមើលឧបសម្ព័ន្ធ២)។

អារម្មណ៍ចូលមកកំសាន្ត និងទទួលទាននៅក្នុងហាងខ្លួន។ ប៉ុន្តែបើយើងក្រលេកមើលទៅលើកន្លែងកំសាន្តសាធារណៈមួយចំនួនក្នុងសង្គមរបស់យើងនូវមិនទាន់ឆ្លើយតបទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់បានទេ។ ជាក់ស្តែងនៅក្នុងរាជធានីភ្នំពេញ កន្លែងសំរាប់ធ្វើការកំសាន្តទីសាធារណៈសំរាប់ប្រជាពលរដ្ឋរស់នៅទីនេះផ្ទាល់ ពិតជាមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ដោយសារទីក្រុងរបស់យើងគឺជាទីក្រុងកំពុងអភិវឌ្ឍ ដែលវាទាមទារនូវពេលវេលាជាច្រើនទៀតដើម្បីសិក្សាក្នុងការកសាងកន្លែងកំសាន្តសាធារណៈផ្សេងៗបន្ថែមទៀត សំរាប់បំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ដូច្នេះហើយវាគឺហេតុផលដែលប្រជាពលរដ្ឋមួយចំនួន ជាពិសេសយុវវ័យផ្ទាល់សម្រេចចិត្តចូលកំសាន្តក្នុងក្លឹប ឬកន្លែងផឹកស៊ី ដើម្បីធ្វើការជួបជុំពិភាក្សា ក៏ដូចជាការលំហែនូវអារម្មណ៍របស់ពួកគេ[28]។

## ២.១.៤ កង្វះកន្លែងលំហែកាយ និងណាត់ជួប

យុវវ័យសម័យថ្មីតែងតែធ្វើការណាត់ជួបគ្នា ពិភាក្សាអំពីកិច្ចការងារ ការសិក្សា និងជីវភាពរស់នៅរបស់ខ្លួននៅទីកន្លែងណាមួយដែលពួកគេអាចជួបជុំគ្នាបាន។ ទីកន្លែងទាំងអស់នោះមានដូចជា សួរច្បារសាធារណៈ ផ្សារទំនើប រមណីយដ្ឋាន ហាងកាហ្វេ និងអាហារដ្ឋាន។ល។ ដែលជាទីដែលមនុស្សម្នាចូលចិត្តធ្វើការណាត់ជួបគ្នា។ កំណើនមនុស្សក៏កាន់ចេះតែកើនឡើង ទីលំហែកាយឬណាត់ជួបក៏កាន់តែចង្អៀត និងមិនមានគ្រប់គ្រាន់សម្រាប់ឲ្យពួកគេមកជួបជុំគ្នា និងធ្វើការកំសាន្ត។ ដោយសារតែកង្វះខាតទីណាត់ជួប និងលំហែកាយបែបនេះហើយ ទើបធ្វើឲ្យយុវវ័យសម័យថ្មីនេះ នាំគ្នាទៅធ្វើការណាត់ជួបគ្នានៅក្នុងក្លឹបកំសាន្ត តៀមស្រា និងបៀហ្គាដិនផ្សេងៗជាដើម។ បើតាមការសម្ភាសន៍ផ្ទាល់ជាមួយនិស្សិតមួយក្រុមបានឲ្យដឹងថា ពួកគេពិតជាពិបាករកកន្លែងលំហែកាយ និងណាត់ជួបគ្នាណាស់នាពេលបច្ចុប្បន្ននេះនៅរាជធានីភ្នំពេញ។ ដូច្នេះហើយពួកគេតែងតែនាំគ្នាទៅក្លឹបកំសាន្ត តៀមស្រា និងបៀហ្គាដិន ដើម្បីធ្វើការណាត់ជួបគ្នា ជួបជុំមិត្តភក្តិពិភាក្សាគ្នាលេង។ នៅពេលដែលពួកគេទៅទីកន្លែងទាំងនោះ ពួកគេតែងតែជ្រើសរើសយកគ្រឿងស្រវឹងដូចជា ស្រាក្រហម ស្រាបៀរ និងស្រាក្រឡុកជាដើម ដើម្បីយកមកទទួលទាន[29]។ កិច្ចសម្ភាសន៍មួយផ្សេងទៀតជាមួយនឹងយុវតីម្នាក់ទៀតក៏បានឲ្យដឹងដែរថា នៅពេលទំនេរបន្ទាប់ពីការសិក្សាជាពិសេសនៅចុងសប្តាហ៍ នាងនិងមិត្តភក្តិ មិនដឹងថាទៅណាទេ ព្រោះកន្លែងដើរលេងនៅភ្នំពេញ ក្រៅពីទៅហាងហូបអី និងបន្តទៅ Pub ឬLounge ព្រោះនាងចូលចិត្តស្តាប់ភ្លេង ផឹកស្រា

[28] វ៉េត មុនីនាថ, *យុវជនចង់ឲ្យមានទីលម្ហែច្រើនសម្រាប់លម្ហែកាយ* (ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

[29] វ៉េត មុនីនាថ, *យុវជនចង់ឲ្យមានទីលម្ហែច្រើនសម្រាប់លម្ហែកាយ* (ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

បន្តិចបន្តួច និងជជែកគ្នាលេង។ បើតាមការសង្កេតរបស់លោក នុត សុខា នាយកប្រតិបត្តិនៅក្រុមហ៊ុន ខេមបូឌាមេត្រូបានឲ្យដឹងថា ភាគច្រើននៃភ្ញៀវដែលមក Pub មេត្រូ មានអាយុចាប់ពី ២០ ទៅ ៣៥ឆ្នាំ ហើយពួកគេមកជួបជុំគ្នាហូបអី ផឹកស្រាក្រហម ស្រាបៀរ ឬស្រាក្រឡុកតាមចំណូលចិត្តរបស់គេនីមួយៗ[30]។ កង្វះខាតទៅកន្លែងលំហែកាយ និងណាត់ជួបនេះ ក៏ជាចំណែកមួយដែលធ្វើឲ្យយុវវ័យមួយចំនួន ទៅរកក្លឹបកំសាន្ត តៀមស្រា បៀហ្គាដិនផ្សេងៗ ដែលអាចឲ្យពួកគេទទួលទានគ្រឿងស្រវឹងផ្សេងៗរហូតក្លាយទៅជាទម្លាប់របស់ពួកគេ។

### ២.១.៥ បុគ្គលខ្លួនឯង

ជាធម្មតាមនុស្សម្នាក់ៗតែងតែមានចំណង់ចំណូលចិត្តខុសៗគ្នា អាស្រ័យទៅតាមបុគ្គលិកលក្ខណៈរបស់បុគ្គលរៀងៗខ្លួន។ អ្នកខ្លះមានចំណង់ចំណូលចិត្ត ធ្វើអ្វីមួយឲ្យបានប្រសើរមកលើខ្លួន និងគ្រួសារ ហើយអ្នកខ្លះទៀតមានចំណង់ចំណូលចូលចិត្តធ្វើអ្វីប្លែកៗ ហើយរមែងតែមានបញ្ហាដល់ខ្លួនឯង គ្រួសារ និងសង្គមផងដែរ។ បើយើងក្រលេកមើលពីយុវវ័យមួយចំនួន ក៏ដូចជាមនុស្សវ័យកណ្តាលមួយចំនួន បានចាប់យកគ្រឿងស្រវឹងដើម្បីដោះស្រាយបញ្ហាក្នុងខ្លួន និងរំងាប់ចិត្តរបស់ខ្លួន។ យ៉ាងណាមិញហេតុផលមួយចំនួនដែលជម្រុញឲ្យបុគ្គលខ្លួនឯងសេព ក៏ដូចជាប្រើប្រាស់គ្រឿងស្រវឹងនេះ គឺបណ្តាល មកពីទទួលរងវិបត្តិផ្លូវចិត្ត តួយ៉ាងបញ្ហាគ្រួសារ សម្ពាធការងារ និងបញ្ហាស្នេហា។ បើនិយាយពីបញ្ហាគ្រួសារវិញ គឺកើតចេញពីទំនាស់ក្នុងគ្រួសារ ការមិនយល់ចិត្តគ្នា កង្វះខាតថវិកាផ្គត់ផ្គង់ក្រុមគ្រួសារជាដើម ហើយសម្ពាធការងារ គឺកើតមានឡើងនៅពេលដែលបុគ្គលផ្ទាល់មិនអាចរកដោះស្រាយកិច្ចការឲ្យបានសម្រេច ឬត្រូវបានថៅកែ ឬប្រធានខ្លួនស្តីបន្ទោសផ្សេងៗ។ បន្ថែមពីលើនេះបញ្ហាស្នេហាក៏ជាបញ្ហាចោទផងដែរសំរាប់យុវវ័យក្នុងពេលបច្ចុប្បន្ននេះដែលរុញច្រានឲ្យពួកគេសេពគ្រឿងស្រវឹងគឺដោយសារមានការឈ្លោះប្រកែកគ្នាពីសំណាក់ដៃគូរ ន ឬការបែកបាក់ស្នេហារបស់គេផ្ទាល់។ ដើម្បីបំបាត់ទុក្ខកង្វល់ទាំងអស់នេះបានពួកគេតែងតែចាប់យកគ្រឿងស្រវឹងយកមកដាក់មុខហើយទទួលទានវា ដើម្បីបំភ្លេចនូវក្តីឈឺចាប់ទាំងឡាយដែលខ្លួនកំពុងតែប្រឈមមុខ។ ម្យ៉ាងវិញទៀត ការអូសទាញពីមិត្តភិក្ត ឬតាមរយៈការបញ្ចុះបញ្ចូល ការកុហក ជាមួយនឹងការនិយាយបន្ទោសបង្អាប់ក៏ជាកត្តាមួយផងដែរ ដែលជម្រុញឲ្យបុគ្គលខ្លួនឯងផ្ទាល់សេព ក៏ដូចជាប្រើប្រាស់គ្រឿងស្រវឹងនេះ។ ជាពិសេស គឺមកពីបុគ្គលខ្លួនឯងផ្ទាល់តែម្តងដែលទទួលទានគ្រឿងស្រវឹងទៀងទាត់ជារៀងរាល់ថ្ងៃដែលជាហេតុបណ្តាលឲ្យខ្លួនឯងញៀន និងត្រូវការវាដោយខានពុំបាន។ បើមិនបានទទួលទានគ្រឿងស្រវឹងក្នុងមួយថ្ងៃទេក្នុងខ្លួនហាក់បីដូចជា ខ្វះនូវអ្វីម្យ៉ាងអញ្ចឹង នេះបើតាមពាក្យនិយាយលេងគេហៅថា "**ដុះមេ**"។ អ្នកដែលចូលចិត្តទទួលទានគ្រឿង

---

[30] វ៉េត មុនីនាថ, *យុវជនចង់ឲ្យមានទីលម្ហែច្រើនសម្រាប់លម្ហែកាយ* (ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៥)។

ស្រវឹងនេះ ជារៀងរាល់ថ្ងៃនេះបានក្លាយទៅជាអ្នកប្រមឹក ដែលខ្វះស្រាមិនបាន បើមិនបានផឹកស្រាមួយថ្ងៃ ដូចជាមនុស្សគ្មានកម្លាំងកំហែងធ្វើការអញ្ចឹង។

## ២.២ ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង និងករណីសិក្សា

ដូចដែលយើងដឹងស្រាប់ហើយថា ការក្រេប ឬទទួលទានគ្រឿងស្រវឹងហួសប្រមាណ ឬហួសពីការកំណត់រមែងតែងតែនាំឲ្យអ្នកទទួលទានទាំងនោះជួបប្រទះនឹងបញ្ហាមួយចំនួនផងដែរ។ តាមការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ បានរកឃើញនូវផលប៉ះពាល់ចំនួនប្រាំដែលកើតឡើងដោយសារគ្រឿងស្រវឹងផងដែរ។ ផលប៉ះពាល់ទាំងប្រាំនោះគឺ៖

### ២.២.១ សុខភាព

ជាពិតណាស់ការសេព ឬទទួលទានគ្រឿងស្រវឹងហួសប្រមាណ តែងតែធ្វើឲ្យសុខភាពអ្នកទទួលទានជួបប្រទះនឹងបញ្ហា ព្រមទាំងបង្ករឲ្យមានជម្ងឺក្នុងខ្លួនជាបន្តបន្ទាប់។ តាមរយៈការស្រាវជ្រាវរបស់អ្នកជំនាញខាងសុខភាពបានឲ្យដឹងថា បន្ទាប់ពីទទួលទានគ្រឿងស្រវឹងហើយ អ្នកទទួលទានរមែងមានអារម្មណ៍ធឹងធោង ភាំងៗ មានអាការៈតានតឹង និងញ័រខ្លួន ហើយពេលខ្លះនឹងមិនមានការចងចាំអំពីអ្វីដែលកើតឡើងនោះទេ។ បើតាមការស្រាវជ្រាវរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជា(CMH)បានឲ្យដឹងថា ការទទួលទានគ្រឿងស្រវឹងហួសកម្រិត អាចបណ្តាលឲ្យអ្នកទទួលទានប្រឈមមុខនឹងជម្ងឺជាង២០០ប្រភេទ។ នៅពេលអ្នកទទួលទានគ្រឿងស្រវឹងនេះច្រើនហួសហេតុនឹងបង្កឱ្យមានរោគសញ្ញា ដូចជាហូរឈាមក្នុងក្រពះ ស្បែកពណ៌លឿង មានជម្ងឺថ្លើម អសមត្ថភាពផ្លូវភេទ ធ្លាក់ទឹកចិត្ត ធ្វើអត្តឃាត មានបញ្ហាដំណេក ភាន់គំនិត បាត់បង់ស្មារតី ខូចប្រព័ន្ធប្រសាទ និងខូចខួរក្បាលជាដើម។ មិនតែប៉ុណ្ណោះ អ្នកដែលទទួលទានគ្រឿងស្រវឹងច្រើនហួសហេតុ នឹងអាចមានផ្ទុកមេរោគអេសដ៍ដោយសារតែការប្រថុយគ្រោះថ្នាក់រួមភេទដោយមិនបានប្រើស្រោមអនាម័យ[31]។ ឧទាហរណ៍ជាក់ស្តែងមួយ ដែលក្រុមយើងខ្ញុំបានស្រាវជ្រាវ មានស្ត្រីចំណាស់ម្នាក់ដែលមានវិបត្តិផ្លូវចិត្តដោយសារប្តីរបស់គាត់បានរត់ចោលគាត់ ហើយគាត់ក៏បានយកស្រាថ្នាំ យកមកទទួលទានដើម្បីរំងាប់ចិត្តបំភ្លេចរាល់ទុក្ខកង្វល់។ ការទទួលទានស្រាថ្នាំហួសប្រមាណរបស់គាត់ បានបណ្តាលឲ្យគាត់បាត់បង់ស្មារតីតែងតែនិយាយតែម្នាក់ឯង ដេរគេឯងឥតឈប់ឈរ។ ដោយសារការបាត់បង់ស្មារតីរបស់គាត់ ស្ត្រីរូបនេះត្រូវបានសង្គមស្អប់ខ្ពើម ខ្លាចមិនហ៊ាននិយាយរក ឬនៅក្បែរ។ ដើម្បីជ្រាបឲ្យកាន់ច្បាស់ពីផលប៉ះពាល់ដល់សុខភាពពីការទទួលទានគ្រឿងស្រវឹងនេះ ក្រុមយើងខ្ញុំសូមលើកនូវលទ្ធផលស្រាវជ្រាវមួយចំនួនយកមកជម្រាបដូចតទៅ៖

[31]ទស្សនាវដ្តីសុខភាពយើង, *អ្នកទទួលទានគ្រឿងស្រវឹងហួសហេតុ* (ភ្នំពេញ៖ ទស្សនាវដ្តីសុខភាពយើង លេខ០៦៨ ខែកញ្ញា ឆ្នាំ២០១១) អាចរកបាននៅ http://www.healthcambodia.com/p15821/ ។

**⁕ ទារក និងគ្រឿងស្រវឹង**

ពេលមានផ្ទៃពោះ គឺមានន័យថាទារកចាប់ផ្តើមធំធាត់នៅក្នុងផ្ទៃរបស់អ្នក។ ម្ហូបអាហារ និងភេសជ្ជៈដែលអ្នកទទួលទានក្នុងកំឡុងពេលមានផ្ទៃពោះផ្តល់ការប៉ះពាល់ដល់ទារកក្នុងផ្ទៃ។ប្រសិនបើអ្នកទទួលទានគ្រឿងស្រវឹង វាអាចបង្កគ្រោះថ្នាក់ដល់ការលូតលាស់របស់ទារកក្នុងផ្ទៃ។ កូនរបស់អ្នកអាចមានបញ្ហាផ្លូវកាយនិងបញ្ហាផ្លូវចិត្តដែលអាចស្ថិតនៅអស់មួយជីវិតរបស់ពួកគេ។

ទារកមានរោគជាតិស្រវឹងពេលនៅក្នុងគភ៌ (fetal alcohol syndrome)អាចប្រឈមនឹងគ្រោះថ្នាក់ដូចខាងក្រោម៖

- ទារកកើតមកមិនគ្រប់គីឡូ
- មានបញ្ហា ចំពោះការបរិភោគអាហារ និងការគេង
- មានបញ្ហាចំពោះភ្នែក និងត្រចៀក
- មានផលពិបាកក្នុងការស្គាល់ទិសតំបន់ និងពិបាកក្នុងការហាត់រៀននូវការងារងាយៗ
- មានការលំបាកក្នុងការផ្ចង់អារម្មណ៍ ចំពោះការរៀនមុខវិជ្ជាក្នុងសាលា
- ត្រូវបណ្តុះបណ្តាលពួកគេដោយរើសគ្រូជំនាញ និងសាលាល្អៗ
- ពិបាកក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សក្នុងសង្គមនិងពិបាកក្នុងគ្រប់គ្រងឥរិយាបទរបស់ពួកគេ
- ត្រូវការការថែទាំផ្នែកវេជ្ជសាស្ត្រពេញមួយជីវិតរបស់ពួកគេប្រសិនបើអ្នកទទួទានជាតិស្រវឹង

មុនពេលបានដឹងថាខ្លួនមានផ្ទៃពោះ សូមអ្នកឈប់ទទួលទានគ្រឿងស្រវឹងឥឡូវនេះភ្លាម។ ជាតិស្រវឹងអាចបង្កគ្រោះថ្នាក់ដល់កូនរបស់អ្នក សូម្បីតែអ្នកមានផ្ទៃពោះត្រឹម ១ឬ ២ខែ ក៏ដោយ។

**⁕ គ្រឿងស្រវឹងបង្កផលប៉ះពាល់ទៅលើសុខភាពផ្លូវចិត្ត**

ផលប៉ះពាល់ទាំងនេះគឺមានទំនាក់ទំនងរវាងផ្លូវកាយ និងផ្លូវចិត្ត ដូចជាការប៉ះពាល់ទៅដល់ខួរក្បាល ពោលគឺអាចឈានទៅដល់ជម្ងឺវិកលចរិតនៅពេលដែលមានកង្វះជីវជាតិបេ១(B1)។ មិនតែប៉ុណ្ណោះទេ គឺអាចនាំឱ្យមានជម្ងឺថប់អារម្មណ៍ បញ្ចេញរោគសញ្ញាទៅជាភ័យខ្លាច តក់ស្លុតបាក់ស្បាត និងអាចមានជម្ងឺធ្លាក់ទឹកចិត្តទៀតផង។ មួយវិញទៀតគឺមានផលប៉ះពាល់ឱ្យទៅជាមានជម្ងឺចាស់វង្វេង លោកអ្នកមួយចំនួនដែលទទួលទានស្រាហួសកំណត់គឺអាចបណ្តាលមានការវង្វេងមុនអាយុ គឺដោយសារតែជាតិស្រាបានទៅបំពុលកោសិកាខួរក្បាល ក្នុងរយៈពេលយូរទៅនឹងនាំឱ្យ

បាត់បង់នូវតួនាទីរបស់ខួរក្បាលមិនអាចបំពេញបាន ដូចនេះគឺនាំឱ្យមានការវង្វេងច្រើន ភ្លេចច្រើន និយាយជារួម គឺវាបានទៅប៉ះពាល់ដល់តំបន់ចងចាំនៃខួរក្បាល[32]។

### ❋ គ្រឿងស្រវឹងបង្កផលប៉ះពាល់ទៅលើសុខភាពផ្លូវកាយ

សុរាស្ទើរតែមានផលប៉ះពាល់ចំពោះសរីរាង្គទាំងអស់ តែមានសរីរាង្គមួយចំនួនគឺងាយនឹងប៉ះពាល់ ដូចជាថ្លើម ប្រដាប់រំលាយអាហារ ក្រពះ ពោះវៀន បេះដូង ប្រព័ន្ធសរសៃឈាម ឆ្អឹង ស្បែក សាច់ដុំ ខួរក្បាល ប្រព័ន្ធសរសៃប្រសាទ ប្រដាប់ភេទ ដែលអាចបណ្តាលឱ្យខ្សោយផ្លូវភេទ ធ្វើឱ្យប្រព័ន្ធការពាររាងកាយចុះខ្សោយងាយនឹងឆ្លងជម្ងឺកង្វះអាហារូបត្ថម្ភ ហើយនិងអាចឈានទៅដល់ជម្ងឺមហារីក។ ចំពោះស្ត្រីដែលមានផ្ទៃពោះ គឺរឹតតែមានផលប៉ះពាល់ ពិសេសប៉ះពាល់ដល់ទារកក្នុងផ្ទៃ ដែលអាចបណ្តាលឱ្យមានពិការភាពពីកំណើត។ ការប៉ះពាល់ទាំងនោះនឹងផ្តល់ផលវិបាកដូចខាងក្រោមនេះ[33]។

**១ . ថ្លើម ៖** បើសិនជាលោកអ្នកទទួលទានសុរាហួសកម្រិតហើយមានរយៈពេលយូរ នឹងធ្វើឱ្យលោកអ្នកប្រឈមមុខនឹង ជម្ងឺក្រិនថ្លើម ហើយបើនៅតែបន្តទទួលទានសុរាទៀតនោះនឹងមានជម្ងឺទាចទឹក ក្នុងករណីមិនឈប់អាចឈានទៅដល់ជម្ងឺមហារីកថ្លើមទៀតផង។

**២ . ប្រដាប់រំលាយអាហារ ៖** ការទទួលទានគ្រឿងស្រវឹងច្រើនហួសកម្រិតនឹងធ្វើឱ្យរលាកបំពង់អាហារ ចំណីអាហារនៅក្នុងក្រពះត្រូវភើឡើងលើវិញឱ្យទៅជារលាកក្រពះ យូរៗទៅគឺអាចធ្វើឱ្យទៅជាមហារីកពោះវៀនតូច នាំឱ្យការជម្រាបអាហារមិនបានល្អ ដែលបណ្តាលឱ្យកង្វះអាហារូបត្ថម្ភ។ ជាធម្មតាអ្នកផឹកស្រាមិនសូវញ៉ាំអាហារទេ ជាហេតុនាំឱ្យជាតិស្រាបង្កការរលាកពោះវៀនតូច ពោះវៀនធំ គឺធ្វើឱ្យងាយបាត់បង់សារជាតិចិញ្ចឹមសរីរាង្គកាយ។

**៣ . បេះដូង ៖** សុរាធ្វើឱ្យចង្វាក់បេះដូងលោតខុសពីធម្មតា។ បើទទួលទានខ្លាំងមែនទែនអាចធ្វើឲ្យគាំងបេះដូងស្លាប់តែម្តង អាចធ្វើឱ្យលើសឈាម និងធ្វើឱ្យសាច់ដុំបេះដូងខ្សោយដោយសារតែការលោតញាប់របស់ចង្វាក់បេះដូង។

---

[32] ទស្សនាវដ្តីសុខភាពយើង, *គ្រឿងស្រវឹងបង្កផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយ* (ភ្នំពេញ៖ ទស្សនាវដ្តីសុខភាពយើង លេខ៤៧ ធ្នូ ២០០៩)អាចរកបាននៅ http://www.healthcambodia.com/p11620/ ។

[33] ទស្សនាវដ្តីសុខភាពយើង, *គ្រឿងស្រវឹងបង្កផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយ* (ភ្នំពេញ៖ ទស្សនាវដ្តីសុខភាពយើង លេខ៤៧ ធ្នូ ២០០៩)អាចរកបាននៅ http://www.healthcambodia.com/p11620/ ។

៤ . **ខួរក្បាល** ៖ សុរាធ្វើឱ្យការចងចាំមិនបានល្អចំពោះរឿងរ៉ាវដែលបានកើតឡើង ពោលគឺមានការប៉ះពាល់ទៅដល់តំបន់ចងចាំ ទៅបំពុលកោសិកាខួរក្បាលរហូតដល់ស្លាប់។ បើទទួលទានកាន់តែយូរនឹងបង្កឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ អ្នកជម្ងឺចាប់ផ្តើម និយាយត្រដិត វង្វេង ភ្លេចភ្លាំង លែងចេះគិតពិចារណា។ បើរឹតតែយូរថែមទៀតគឺនឹងធ្វើឱ្យអ្នកជម្ងឺបាត់បង់វីតាមីនបេ១ បង្កមានជម្ងឺវិកលចរិតទៀតផង។

៥ . **ផ្លូវភេទ** ៖ នៅពេលដែលទទួលទានគ្រឿងស្រវឹងហួសកម្រិតនឹងនាំឱ្យសមត្ថភាពនៃការរួមសង្វាសថយចុះ ដូចនេះការទទួលសុរាកាន់តែច្រើនកាន់តែបំផ្លាញសុខភាព និងសេចក្តីសុខរបស់ខ្លួន។

បន្ទាប់ពីធ្វើបកស្រាយពីបញ្ហាសុខភាព ដែលបណ្តាលមកពីការទទួលទានគ្រឿងស្រវឹងនេះ យើងឃើញថា គ្រឿងស្រវឹងដែលមានដូចជា ស្រា ស្រាបៀរ ស្រាក្រហម ស្រាក្រឡុកទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់អ្នកទទួលទានជាខ្លាំង ដែលឈានដល់ការបាត់បង់ស្មារតី បាត់បង់អាយុជីវិតផងដែរ នៅពេលដែលអ្នកទទួលទានស្រាលើសប្រមាណ។ បើតាមការស្រាវជ្រាវរបស់អង្គការសុខភាពពិភពលោក (WHO) បានឲ្យដឹងថា ជម្ងឺប្រមាណ២០០មុខ រួមមានជម្ងឺមហារីកបំពង់អាហារ មហារីកថ្លើម ជម្ងឺលើសសំពាធ ជម្ងឺស្ទះសរសៃឈាមបេះដូង ខួរក្បាល ជម្ងឺក្រិនថ្លើម រលាករំពែង វិកលវិបល្លាស សុទ្ធតែបង្កឡើងដោយសេពគ្រឿងស្រវឹងនេះ។

## ២.២.២ គ្រោះថ្នាក់ចរាចរណ៍

បន្ទាប់ពីការស្លាប់ដោយសារជម្ងឺអេដស៍ គ្រោះថ្នាក់ចរាចរណ៍គឺបានឈរនៅលំដាប់លេខរៀងទីពីរ ដែលបានឆក់យកអាយុជីវិតប្រជាជនកម្ពុជាអស់រាប់រយនាក់ជារៀងរាល់ឆ្នាំ។ គ្រោះថ្នាក់ចរាចរណ៍នេះ កើតឡើងដោយសារកត្តាបួនយ៉ាងគឺ កត្តាផ្លូវថ្នល់ កត្តាយានយន្ត កត្តាអាកាសធាតុ និងកត្តាបុគ្គលខ្លួនឯង។ ដូចយើងឃើញស្រាប់ហើយថា គ្រោះថ្នាក់ចរាចរណ៍មួយចំនួនធំបានកើតឡើងបណ្តាលមកពី អ្នកបើកបរស្ថិតនៅក្នុងស្ថានភាពស្រវឹង គ្រប់គ្រងស្មារតីខ្លួនឯងមិនបាន។ មិនថាអ្នកបើកបរជាជនជាតិខ្មែរទេ សូម្បីតែជនបរទេសដែលរស់នៅកម្ពុជា ក៏បង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ដោយសារបាត់បង់ការគ្រប់គ្រងស្មារតីរបស់ខ្លួនក្នុងស្ថានភាពស្រវឹងនេះ។ ជារៀងរាល់ថ្ងៃក្នុងបណ្តាសារព័ត៌មានទាំងកាសែត វិទ្យុ និងទូរទស្សន៍ក្តី តែងតែផ្សាយព័ត៌មានស្តីពី គ្រោះថ្នាក់នេះ ដែលភាគច្រើននៃគ្រោះថ្នាក់នេះ គឺកើតឡើងបណ្តាលមកពីអ្នកបើកបរស្ថិតនៅក្នុងស្ថានភាពស្រវឹង។ ស្រវឹងបុករះឡាន ម៉ូតូ ស្រវឹងបុកបង្គោលភ្លើង ស្រវឹងបុករបងផ្ទះ ស្រវឹងធ្លាក់ប្រលាយ ស្រវឹងបុកបង្គោលក្បាលនាគពុះចែកផ្លូវ។ល។ តែងតែកើតឡើងស្ទើរតែរៀងរាល់ថ្ងៃ និងយប់នៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានាផងដែរ។ ភាគច្រើននៃគ្រោះថ្នាក់ចរាចរណ៍នេះ គឺកើត

ឡើងដោយសារការបើកបរក្នុងស្ថានភាពស្រវឹងនេះដែលតែងតែកើតឡើងនៅពេលយប់អាធ្រាត ឬនៅក្នុងថ្ងៃបុណ្យទានជាដើម។ នៅពេលយប់មនុស្សម្នា ទាំងប្រុសទាំងស្រី មិនថាមន្ត្រីរាជស៊ីវិល បុគ្គលិកឯកជន និស្សិត អ្នកជំនួញ ឬអ្នកមានទ្រព្យសម្បត្តិមួយចំនួន តែងតែចូលចិត្តទៅកំសាន្តអារម្មណ៍ ទទួលទានគ្រឿងស្រវឹងលើសលប់នៅតាមបណ្តាហាងផឹកស៊ី បៀហ្គាឌិន គៀមស្រា ឬក្លឹបមួយចំនួនទាំងនោះ ដែលតែងតែធ្វើឲ្យខ្លួនស្រវឹងជោគជាំ វង្វេងស្មារតី បាត់បង់ម្ចាស់ការ ។ល។ នេះហើយដែលនាំឲ្យខ្លួនមិនអាចគ្រប់គ្រងខ្លួនឯងលែងបានក្នុងការបើកបរ។ ដូចយើងឃើញស្រាប់ហើយ គ្រោះថ្នាក់ចរាចរណ៍មួយចំនួនធំ តែងតែធ្វើឲ្យខូចខាតដល់សម្បត្តិសាធារណៈ និងឯកជនផ្សេងៗទៀត។ ការខូចខាតទាំងអស់នេះ បានជះឥទ្ធិពលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារយ៉ាងខ្លាំង តួយ៉ាងសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលត្រូវធ្វើការចំណាយនូវថវិកាជាតិរាប់រយលានដុល្លារក្នុងមួយៗឆ្នាំ ដើម្បីជួសជុល កែលម្អនូវហេដ្ឋារចនាសម្ព័ន្ធ និងសម្បត្តិសាធារណៈ ដែលខូចខាតទាំងនោះ។ មិនតែប៉ុណ្ណោះ គ្រោះថ្នាក់នេះក៏ធ្វើឲ្យអ្នកបង្កប្រឈមមុខនឹងការបាត់បង់អាយុជីវិត ឬពិការអស់មួយជីវិត និងធ្វើឲ្យគ្រួសារចំនាយថវិកាច្រើនលើសលុប ក្នុងការព្យាបាលជាដើម។ បើតាមការស្រាវជ្រាវរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជា បានឲ្យដឹងថាក្នុងមួយឆ្នាំៗមានពលរដ្ឋកម្ពុជាប្រមាណ៣០០នាក់បានបាត់បងជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងនេះជារៀងរាល់ឆ្នាំ[34]។ ដើម្បីឲ្យយល់កាន់តែច្បាស់អំពីគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាមកពីការបើកបរក្នុងស្ថានភាពស្រវឹង យើងខ្ញុំសូមលើកករណីសិក្សាជាក់ស្តែងមួយចំនួនយកមកបង្ហាញដូចតទៅ៖

**<u>ករណីសិក្សា៖</u>**

**ស្រវឹងខ្លាំងពេកបើករថយន្តបុកបង្គោលភ្លើង ពេលសមត្ថកិច្ចសួរ ប្រាប់ថាបង្គោល ភ្លើងបុករថយន្តទៅវិញ៖**

រាជធានីភ្នំពេញ ៖ បុរសម្នាក់**ស្រវឹងជោគជាំ**បើករថយន្តមួយគ្រឿងម៉ាក OD ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2X 6927 ទៅបុកបង្គោលភ្លើងបំភ្លឺផ្លូវទ្រេត និងធ្លាក់បែកអំពូលភ្លើង ហើយព្យាយាមបើករត់គេចរហូតដល់មុខក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តាមមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ទើបបើកទៅមុខលែងរួច ត្រូវបានអ្នករត់រ៉ឺម៉កម៉ូតូឃើញជិះទៅប្រាប់សមត្ថកិច្ចឱ្យឃាត់ធ្វើការសាកសួរ។ ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង៤ទៀបភ្លឺ ថ្ងៃទី១ មេសា នៅមុខមជ្ឈមណ្ឌលរ៉ុក តាមមហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក

[34] អង្គការចលនាដើម្បីសុខភាពកម្ពុជា, *លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង* (ភ្នំពេញ៖ អង្គការចលនាសុខភាពដើម្បីកម្ពុជា២០១៤ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

ខណ្ឌចំការមន។ នៅចំពោះមុខសមត្ថកិច្ចអ្នកបើកបររថយន្តបង្កបាននិយាយទាំង**ស្រវឹងជោកជាំ** លែងដឹងខ្លួនថារថយន្តរបស់គាត់មិនបានបុកបង្គោលភ្លើងទេ គឺបង្គោលភ្លើងជាអ្នកបុករថយន្តរបស់គាត់។ ដោយ សារតែអ្នកបើកបរស្រវឹងខ្លាំងពេកសមត្ថកិច្ចបានឃាត់ខ្លួន និងបើករថយន្តយកទៅរក្សាទុកនៅអធិការដ្ឋានខណ្ឌចំការមនសិន ប៉ុន្តែអ្នកបើករថយន្តមិនព្រមឲ្យយករថយន្តទៅទេ ដោយនិយាយថា ប៉ូលិសសំរ៉ែ អញ្ចឹង គាត់មិនចង់ឲ្យប៉ះរថយន្តរបស់គាត់ទេ គាត់មានបងប្អូនធ្វើការនៅក្រសួងតែមិនបានប្រាប់ថាក្រសួងណាមួយទេ [35]។

## <u>ករណីសិក្សា</u>

### នារីម្នាក់បើករថយន្តទាំងស្រវឹងបុកអង្គរក្សយាមភូមិគ្រឹះសម្តេចរងរបួសធ្ងន់២នាក់៖

រាជធានីភ្នំពេញ ៖ នារីម្នាក់បើករថយន្ត**ទាំងស្រវឹង**បួងចង្កូតព័ទ្ធរង្វង់មូលវិមានឯករាជ្យលឿនពេក បានជ្រុលទៅបុកអង្គរក្សយាមតាមរបងភូមិគ្រឹះ២នាក់រងរបួសធ្ងន់ និងបុករះម៉ូតូ៤គ្រឿងរួចបុកដើមឈើអស់២ដើមទៀតនៅជាប់របងភូមិគ្រឹះសម្តេចតេជោ ខាងជើងរង្វង់មូលវិមានឯករាជ្យតាមបណ្តោយផ្លូវសុរាម្រិត កែងផ្លូវព្រះនរោត្តម ក្នុងសង្កាត់ចតុមុខ ខណ្ឌដូនពេញ កាលពីវេលាម៉ោង០២ និង១៥នាទីរំលងអធ្រាត្រឈានចូលថ្ងៃទី១ មេសា ២០១៥[36]។

ប្រភពពីកន្លែងកើតហេតុឱ្យដឹងថា រថយន្តបង្កម៉ាក BMW ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2AE 1113 ជិះគ្នា៥នាក់ មានស្រីមានប្រុស ជាយុវវ័យបើកបរដោយនារីម្នាក់ ពាក់អាវពណ៌ខ្មៅក្នុងស្ថានភាពស្រវឹង ដោយធ្វើដំណើរតាមមហាវិថីព្រះនរោត្តម ពីត្បូងទៅជើង មកដល់រង្វង់មូលវិមានឯករាជ្យបានព័ទ្ធតាមរង្វង់មូលបើកលឿនពេកបួងចង្កូតជ្រុលទៅបុកអង្គរក្ស២នាក់ ដែលកំពុងតែឈរយាមហើយនិយាយគ្នានៅរបងភូមិគ្រឹះ បណ្តាលឱ្យដួលបាក់ជើង និងបែកក្បាលរងរបួសធ្ងន់ទាំង២នាក់ ក្នុងនោះមានម្នាក់ជាឧត្តមសេនីយ៍ទោផ្កាយ២ រួចហើយរថយន្តបង្កបានជ្រុលទៅបុកម៉ូតូហុងដាឌ្រីមស៊េរី២០១០ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AQ 9990 ជាម៉ូតូរបស់អង្គរក្សចតនៅក្បែរនោះ បណ្តាលឲ្យដួលខ្ទាតទៅខាងស្តាំ ហើយរថយន្តបើកទៅបុកគល់ឈើដែលងាប់រលើងទាំងឬស រថយន្តនៅតែមិនទាន់អស់ល្បឿន បានជ្រុលទៅបុកដើមឈើបាក់មួយដើមទៀត និងបុករះម៉ូតូអង្គរក្ស៣គ្រឿងទៀតកៀបជាប់ពីមុខរថយន្តបើកទៅមុខលែងរួច ។

[35] កោះសន្តិភាព, *ស្រវឹងខ្លាំងពេកបើករថយន្តបុកបង្គោលភ្លើង ពេលសមត្ថកិច្ចសួរ ប្រាប់ថាបង្គោលភ្លើងបុករថយន្តទៅវិញ*ច(ភ្នំពេញ៖ កោះសន្តិភាព ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ៣)។

[36] កោះសន្តិភាព, *នារីម្នាក់បើករថយន្តទាំងស្រវឹងបុកអង្គរក្សយាមភូមិគ្រឹះសម្តេចរងរបួសធ្ងន់២នាក់* (ភ្នំពេញ៖ កោះសន្តិភាព ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ៣)។

ក្រោយពេលកើតហេតុ អ្នករងរបួសធ្ងន់ទាំង២នាក់ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត ចំណែកអ្នកបើករថយន្តបង្កត្រូវបានសមត្ថកិច្ចឃាត់រួមជាមួយរថយន្តនិងម៉ូតូ ដែលរងការខូចខាតយកទៅការិយាល័យនគរបាលចរាចរណ៍ផ្លូវគោករង់ចាំធ្វើការដោះស្រាយតាមផ្លូវច្បាប់។

ករណីសិក្សា

**ផឹកស៊ីឆ្លងឆ្នាំត្រឡប់ទៅផ្ទះរំលងអធ្រាត្រ បុកគូទរថយន្តឈប់ស្ងៀមស្លាប់៣នាក់៖**

ខេត្តបាត់ដំបង ៖ យុវជន៣នាក់ទំនងទើបចេញពី**កន្លែងផឹកស៊ី** បានបើករថយន្តទៅបុកគូទរថយន្តដឹកទឹកកក ដែលឈប់ស្ងៀម នៅលើចិញ្ចើមថ្នល់ជាតិលេខ៥ បណ្តាលឲ្យស្លាប់ទាំង៣នាក់ កាលពីវេលាម៉ោង៣ រំលងអធ្រាត ឈានចូលថ្ងៃទី១៧ មេសា ត្រង់ចំនុចភូមិកកោះ ឃុំអូរតាគី ស្រុកថ្មគោល ។ សមត្ថកិច្ចបានប្រាប់ថា រថយន្តម៉ាកនីស្សាន់ ពណ៌ក្រហម ជិះគ្នា៣នាក់ ដែលទំនងទើបចេញពីកន្លែងផឹកស៊ី ឬចេញពីក្លឹបខារ៉ាអូខេណាមួយ នៅក្នុងក្រុងបាត់ដំបង ហើយបើកត្រឡប់ទៅផ្ទះវិញ នៅឯស្រុកថ្មគោល ក៏ជួបគ្រោះថ្នាក់តែម្តង ។ សមត្ថកិច្ចបន្តថា ពេលបើកដល់ចំនុចខាងលើ រថយន្តនីស្សាន់នោះ ក៏បុកគូទរថយន្តដឹកទឹកកកពីក្រោយពេញទំហឹង បណ្តាលឲ្យស្លាប់ទាំង៣នាក់ កៀបជាប់ក្នុងរថយន្ត។ គ្រានោះមានមនុស្ស៣នាក់ កៀបជាប់នៅក្នុងរថយន្តស្ងាត់មាត់ឈឹងពោរពេញទៅដោយឈាមជោកជាំក្នុងរថយន្ត។ ប៉ុន្តែគេមិនអាចជួយទាញមនុស្សចេញពីក្នុងរថយន្តបានទេបានត្រឹមតែរាយការណ៍ប្រាប់សមត្ថកិច្ចតែប៉ុណ្ណោះ[37]។

## ២.២.៣ អំពើហិង្សាក្នុងគ្រួសារ និងសង្គម

ហិង្សា គឺជាការបៀតបៀន ការពាធា ការធ្វើអាក្រក់រកគ្នា ឬការធ្វើទុក្ខគ្នាទៅវិញទៅមកនេះ បើតាមវចនុក្រមខ្មែរ[38] អំពើហិង្សានេះតែងតែកើតមានឡើងនៅក្នុងគ្រួសារ ក៏ដូចជានៅក្នុងសង្គមជាតិដែរ។ អំពើហិង្សានេះមួយចំនួន គឺកើតឡើងដោយសារតែបុគ្គលអ្នកប្រព្រឹត្តបាត់បង់ស្មារតី ឆេវឆាវ ដោយសារតែក្រេបគ្រឿងស្រវឹងហួសប្រមាណ។ ហិង្សានេះ តែងតែធ្វើឲ្យមនុស្សបាត់បង់នូវក្តីស្រលាញ់ ក្តីគោរព និងអាចឈានដល់ការលែងលះ បាត់បង់ជីវិត ឬពិការជាដើម។ អំពើហិង្សានេះ គឺកើតមានឡើងគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ។ ប្តីស្រវឹងស្រា វាយធ្វើបាបជេរស្តីប្រពន្ធកូន និងមិត្តភក្តិបនភៀនស្រវឹង ជេរឬវាយតបគ្នា រហូតកាប់សម្លាប់គ្នាក៏មានដែរ។ អំពើហិង្សានេះ តែងតែបានបណ្តាលឲ្យមាន ប្តីប្រពន្ធលែងលះគ្នា ការប៉ះពាល់ផ្លូវចិត្តស្ត្រី និងកូនៗ ស្ត្រី

[37] កោះសន្តិភាព, *ផឹកស៊ីឆ្លងឆ្នាំត្រឡប់ទៅផ្ទះរំលងអធ្រាត្រ បុកគូទរថយន្តឈប់ស្ងៀមស្លាប់៣នាក់* (ភ្នំពេញ៖ កោះសន្តិភាព ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ៣)។

[38] ពុទ្ធសាសនបណ្ឌិត្យ, *"វចនានុក្រមខ្មែរ"* (ភ្នំពេញ៖ ឆ្នាំ១៩៦៧) ទំព័រ១៥១៦។

ក្លាយជាស្ត្រីមេម៉ាយ រីឯកូនក្លាយជាកុមារកំព្រា[39] បាត់បង់កិត្តិយស ថវិកា មិត្តភក្តិ សុខភាព និងអាយុជីវិតផងដែរ។ ឥទ្ធិពលនៃគ្រឿងស្រវឹង អាចធ្វើឲ្យមនុស្សបាត់បង់ម្ចាស់ការ វង្វេងវង្វាន់ លែងដឹងខុសត្រូវ ប្រែជាកោងកាច ដែលបណ្តាលឲ្យខ្លួនឈានទៅប្រព្រឹត្តហិង្សា វាយតបគ្នា ធ្វើឲ្យរងរបួសរៀងៗខ្លួន។ ដូចយើងឃើញស្រាប់ហើយ នៅតាមបណ្តាខេត្ត ឬស្រុកដាច់ស្រយាលមួយចំនួន បុរសជាប្តី ដែលញៀននឹងផឹកស្រា នៅពេលស្រវឹងម្តងៗតែងតែមកផ្ទះវិញ ជេរស្តី វាយធ្វើបាបប្រពន្ធកូនខ្លួន ជានិច្ច។ មិនមែនមានតែបុរសជាប្តីទេ សូម្បីតែស្ត្រីជាប្រពន្ធមួយចំនួន ក៏ញៀននឹងការផឹកស្រាផងដែរ។ ស្ត្រីខ្លះផឹកហើយកាលណា កាចកាលហ្នឹង។ និយាយស្តីលែងដឹងអ្វី គិតតែជេរស្រែកឡូឡាពាសពេញភូមិជាដើម។ បើតាមលទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹងរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជា(CMH)ឆ្នាំ២០១៤បានឲ្យដឹងថា ៩០ភាគរយនៃកុមារកម្ពុជាដែលមានអាយុចន្លោះពី ១០ ទៅ១២ឆ្នាំ បានឆ្លើយថាគ្រឿងស្រវឹងជាមូលហេតុចម្បងដែលធ្វើឲ្យមានអំពើហិង្សាក្នុងគ្រួសារ និងសហគមន៍។ ស្ទើរតែគ្រប់ប្រភេទនៃអំពើហិង្សាក្នុងគ្រួសារមានកើនឡើងស្របគ្នា នឹងភាពញឹកញាប់នៃការផឹកគ្រឿងស្រវឹងរបស់ប្តីឬប្រពន្ធ។ ជាក់ស្តែង បើមានសេពគ្រឿងស្រវឹងស្ទើរតែរៀងរាល់ថ្ងៃនោះអំពើហិង្សាដោយការជេរប្រមាថកើនឡើង៣០ភាគរយ បើធៀបនឹងការមិនសេពគ្រឿងស្រវឹង[40]។ បើនិយាយនៅក្នុងសង្គមវិញ យុវវ័យសម័យថ្មីនេះ មួយចំនួនចូលចិត្តក្រេបគ្រឿងស្រវឹង ខ្លះក្រេបឡើងជោកជាំ ហើយខ្លះពេលស្រវឹងកាលណា តែងតែមានមោទនភាពលើខ្លួនឯង គិតថាខ្លួនជាអ្នកខ្លាំងប្រចាំភូមិជាដើម។ នៅពេលដែលស្រវឹងម្តងៗ យុវវ័យទាំងនោះតែងតែបង្កនូវអំពើហិង្សាទៅលើក្រុមគ្រួសារខ្លួន និងអ្នកដទៃផងដែរ។ ពេលបុណ្យទាននៅតាមស្រុកភូមិនាពេលបច្ចុប្បន្ននេះម្តងៗ យើងតែងតែឮសូរថា មានការកាប់សម្លាប់ វាយដំគ្នា នៅក្នុងវង់រាំតាមភូមិ ដោយសារការរាំជាន់ជើង ឬមើលមុខគ្នាជាដើម។ តែបើយើងសិក្សាឲ្យស៊ីឲ្យជម្រៅទៅ យើងអាចទាញមូលហេតុដែលបណ្តាឲ្យមានការវាយដំគ្នានេះ គឺដោយសារការផឹកគ្រឿងស្រវឹងនេះ។ ពេលស្រាចូលដល់ក្នុងខ្លួន យុវវ័យមួយចំនួននោះតែងតែគិតថាខ្លួនខ្លាំងពូកែ មានអំណាចអស្ចារ្យ វាយដំក៏មិនឈឺ កាប់ដាច់សាច់ក៏មិនជាអ្វី។ល។ ទាំងនេះហើយដែលបណ្តាលឲ្យមានអំពើហិង្សានៅក្នុងសង្គមនេះ ដែលធ្វើឲ្យខូចសីលធម៌ខ្មែរ និងមុខមាត់សង្គមជាតិ។ ដើម្បីយល់កាន់តែច្បាស់ពីអំពើហិង្សាដែលកើតឡើងដោយសារការក្រេបគ្រឿងស្រវឹងនេះ ក្រុមយើងខ្ញុំ សូមលើកករណីសិក្សាជាក់ស្តែងមួយចំនួនយកមកធ្វើជាឧទាហរណ៍ដូចតទៅនេះ៖

---

[39] ទស្សនាវដ្តីសុខភាពយើង, *អំពើហិង្សាក្នុងគ្រួសារ បំផ្លាញសុភមង្គល* (ភ្នំពេញ៖ ទស្សនាវដ្តីសុខភាពយើង លេខ០០៣ ខែមេសា ឆ្នាំ២០០៦)អាចរកបាននៅ http://www.healthcambodia.com/p2372/ ។

[40] អង្គការចលនាដើម្បីសុខភាពកម្ពុជា, *លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង* (ភ្នំពេញ៖ អង្គការចលនាសុខភាពដើម្បីកម្ពុជា២០១៤ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

<u>ករណីសិក្សា</u>

**តូចចិត្តនឹងប្តីប្រមឹកវាយដំរាល់ថ្ងៃ នាងផឹកថ្នាំពុលប៉ងបញ្ចប់ជីវិត៖**

ខេត្តប៉ៃលិន៖ ស្ត្រីម្នាក់ដោយសារតែតូចចិត្តនឹងប្តីប្រមឹកវាយដំច្រំធាក់ជារៀងរាល់ថ្ងៃ ក៏ដាច់ចិត្តរត់ទៅទាញយកថ្នាំពុលបាញ់ស្មៅ ប្រភេទទឹកខៀវនៅក្នុងបន្ទប់ផ្ទះរបស់ខ្លួនទៅសំងំផឹក លុះប្តីធុំក្លិនថ្នាំពុល និងលឺនាងក្អួតចង្អោរក៏ឡើងទៅមើលឃើញ ក៏ទាត់បីដុងចេញ រួចក៏ប្រញាប់ហៅអ្នកជិតខាងឲ្យបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកខេត្ត[41]។ ហេតុការណ៍នេះកើតឡើងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ស្ថិតនៅក្នុងភូមិអូរអិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ។ ប្រភពបានឲ្យដឹងថា ស្ត្រីរងគ្រោះឈ្មោះ សន សារីម អាយុ៤៩ឆ្នាំ ជាកសិករ មានប្តីឈ្មោះ ព្រាប លឿង អាយុ៥២ឆ្នាំ មានកូនចំនួន០៦នាក់។ បើតាមសាច់ញាតិស្ត្រីរងគ្រោះបានរៀបរាប់ឲ្យដឹងថា មុនពេលកើតហេតុ បុរសជាប្តីបានដើរមកពីមើលគេលេងកីឡាប្រដាល់នៅក្នុងភូមិ ហើយបាន **ផឹកស្រាស្រវឹងជោកជាំ** ដោយមកទាររកលុយពីប្រពន្ធចំនួន ១០.០០០រៀល យកទៅបន្ត**ផឹកស្រា**ទៀត។

<u>ករណីសិក្សា</u>

**ក្នុងវង់ផឹកស៊ី ញ៉ែប្រពន្ធគេ ត្រូវ៣ផ្លែដែកឆាបបណ្តាលឲ្យរបួសធ្ងន់៖**

ខេត្តកំពង់ឆ្នាំង៖ បុរសម្នាក់ត្រូវបានគេលួចចាក់ចំពោះ និងទ្រូង ៣ផ្លែដែកឆាប បណ្តាលឲ្យរងរបួសធ្ងន់ ធ្លាយពោះវៀង បាក់ឆ្អឹងជំនីរ និងរងរបួសថ្លើមធ្ងន់ធ្ងរ ដោយសាររឿងជម្លោះ និងភ្លើងប្រច័ណ្ឌក្នុងវង់ផឹកស៊ី ដោយសាររងគ្រោះជជែកលេង ជាមួយប្រពន្ធជនសង្ស័យ ពេលផឹកស៊ីក្នុងផ្ទះកាលពីវេលាម៉ោង ១០និង៣០នាទីយប់ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៤ នៅផ្ទះឪពុកមាជនដៃដល់ក្នុងភូមិអណ្តូងជ្រៃ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។[42] បុរសជនរងគ្រោះមានឈ្មោះ មាស រី អាយុ៣០ឆ្នាំ រស់នៅក្នុងភូមិឃុំកើតហេតុ បានប្រាប់ឲ្យដឹង ក្រោយពីបាននិយាយរួចគាត់បានទិញស្រាកន្លះលីត្រ យកទៅផឹកនៅផ្ទះពូ ឈ្មោះ វណ្ណា ជាអ្នករស់នៅក្នុងភូមិជិតគ្នា។ ក្នុងពេលផឹកស៊ី គាត់បាននិយាយលេងជាមួយស្ត្រីម្នាក់ ដែលត្រូវជាក្មួយរបស់ពូ វណ្ណា ហើយបន្ទាប់មកប្តីរបស់ស្ត្រីនោះឈ្មោះ រក្ស អាយុជាង ៣០ឆ្នាំ បានមកដល់ និងបានស៊ីផឹកជាមួយគាត់។ ពេលផឹកស្រាអស់ គាត់ក៏ដើរចេញទៅផ្ទះវិញ ខណៈនោះឈ្មោះ រក្ស ក៏បានរត់មកស្ទាក់ពីមុខ ហើយបានផ្លែដែកឆាប មុតស្រួច ១ដើម ចាក់ចំពោះនឹងដើមទ្រូង របស់គាត់បណ្តាលឲ្យរបួសធ្ងន់ធ្ងរ ៣កន្លែង។

[41] កោះសន្តិភាព, *តូចចិត្តនឹងប្តីប្រមឹកវាយដំរាល់ថ្ងៃ នាងផឹកថ្នាំពុលប៉ងបញ្ចប់ជីវិត* (ភ្នំពេញ៖ កោះសន្តិភាព ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ៣)។

[42] មហានគរ, *ក្នុងវង់ផឹកស៊ី ញ៉ែប្រពន្ធគេត្រូវ ត្រូវ៣ផ្លែដែកឆាបបណ្តាលឲ្យរបួសធ្ងន់* (កំពង់ឆ្នាំង៖ គេហទំព័រមហានគរ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៤) (សូមមើលឧបសម្ព័ន្ធ៣)។

ករណីហិង្សានេះកើតឡើង ដោយសារតែភ្លើងប្រច័ណ្ឌផង និងឥទ្ធិពលនៃស្រាផងដែរ។ ដោយសារតែឥទ្ធិពលនៃស្រាចូលដល់ក្នុងពោះជនល្មើស បានបង្កឲ្យជនល្មើសខឹងច្រឡោត គ្រប់គ្រងស្មារតីខ្លួនមិនបាន។

## ២.២.៤ ផលប៉ះពាល់សីលធម៌ក្នុងសង្គម និងប្រពៃណីជាតិ

### ២.២.៤.១ ការប៉ះពាល់ដល់សីលធម៌ក្នុងសង្គម

ពិតណាស់ សីលធម៌នៃជនជាតិខ្មែរ នាសម័យថ្មីនេះកំពុងតែធ្លាក់ចុះបន្តិចម្តងៗ ដោយសារការប្រព្រឹត្ត អំពើពាលាអាវ៉ាសែ អំពើអបាយមុខមួយចំនួន។ល។ នាពេលសព្វថ្ងៃនេះ។ ឥទ្ធិពលគ្រឿងស្រវឹងក៏ជាចំណែកមួយ ដែលធ្វើឲ្យសីលធម៌នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះធ្លាក់ចុះផងដែរ។ បើយើងក្រលេកមើលទៅអតីតកាល មានតែមនុស្សវ័យចំណាស់ដែលមានការងារធ្វើជាពិសេសបុរសៗទេ ដែលអាចទទួលទានគ្រឿងស្រវឹងបាន តែបើសិនក្រលេកមកមើលទិដ្ឋភាពនាបច្ចុប្បន្ននេះ យើងអាចសង្កេតឃើញថា មិនមែនមានតែមនុស្សចាស់មានការងារធ្វើទេ ដែលអាចទទួលទានស្រាបាន ក្មេងជំទង់ៗមិនទាន់គ្រប់អាយុមួយចំនួនធំ ក៏អាចទទួលទានស្រានេះបានផងដែរ។ យុវវ័យសម័យថ្មីនេះមួយចំនួន បានឈានជើងប្រឡូកក្នុងការផឹកស៊ីតាំងពីមិនទាន់គ្រប់អាយុ (១៣-១៨ឆ្នាំ) ដែលកំពុងបិតនៅក្នុងវ័យសិក្សា បាននាំគ្នាទទួលទានគ្រឿងស្រវឹងដូចជា ស្រាបៀរ ស្រាទឹកផ្លែឈើ ឬស្រាក្រឡុកជាបណ្តើរៗហើយ។ មិនមែនមានយុវជនតែមួយផ្នែកនោះទេ យុវតីមួយចំនួនក៏ចាប់ផ្តើមចេះទទួលទានគ្រឿងស្រវឹង ដូចយុវជនផងដែរនាពេលបច្ចុប្បន្ននេះ។ នៅតាមហាងផឹកស៊ី បៀរហ្គាឌិន ក្លឹបកំសាន្ត និងកន្លែងកំសាន្តផ្សេងទៀត យើងឃើញថាមានយុវវ័យក្មេងៗជំទង់ៗជាច្រើន នាំគ្នាពពាក់ពពូនទៅទទួលទានគ្រឿងស្រវឹងនៅកន្លែងទាំងនោះ នាពេលថ្ងៃឈប់សម្រាក ឬចូលរួមមានកម្មវិធីផ្សេងៗដូចជា ពិធីខួបកំណើតជាដើម។ យុវជនខ្លះ នៅពេលដែលសុរា ឬគ្រឿងស្រវឹងទាំងនោះចូលខ្លួនហើយ រមែងតែបាត់បង់ភាពម្ចាស់ការលើខ្លួន ស្រែកឡូឡា ប្រែទៅជាកាច និយាយខ្លាំង មានអារម្មណ៍ចង់រួមភេទ ឬឈានទៅវាយតបគ្នា ប្រើអំពើហិង្សាកាប់ចាក់គ្នាជាដើម។ នៅពេលខ្លះ យុវជនមួយចំនួនដែលបាត់បង់ភាពម្ចាស់ការ ដោយសារទទួលទានគ្រឿងស្រវឹងនេះ ទៅប្រព្រឹត្តរឿងមិនគប្បីមួយចំនួន ដូចជា ប្រើអំពើហិង្សាលើគ្រួសារខ្លួន (ម្តាយឪពុក) ឬប្រព្រឹត្តអំពើសេពសន្ថវៈ។ល។ ដែលធ្វើឲ្យប៉ះពាល់ដល់សីលធម៌ និងសណ្តាប់ធ្នាប់ក្នុងសង្គម។ នេះហើយ គឺជាផ្នែកមួយដែលធ្វើឲ្យសីលធម៌របស់យុវជនខ្មែរនាពេលបច្ចុប្បន្ននេះធ្លាក់ចុះ។ មិនតែប៉ុណ្ណោះ យើងឃើញថាប្រជាពលរដ្ឋខ្មែរមួយចំនួនដែលប្រកបរបរដូចជា ធាក់ស៊ីក្លូ រត់ម៉ូតូឌុប រត់រម៉ក កម្មករផ្សេងៗ។ល។ តែងតែទទួលទានគ្រឿងស្រវឹងផ្សេងៗ បន្ទាប់ពីធ្វើការរកស៊ីរួចនៅតាមទីសាធារណៈដូចជានៅ សួនច្បារសារធារណៈ ទីរមណីយដ្ឋានទេសចរណ៍ ផ្សារ និងនៅតាម

ចិញ្ចើមផ្លូវសាធារណៈជាដើម។ ដែលវាបានធ្វើឲ្យខូចអស់នូវសណ្តាប់ធ្នាប់ និងសីលធម៌សង្គម។ នៅពេលដែលពួកគាត់ទទួលទានគ្រឿងស្រវឹងទាំងនេះ ពួកគាត់តែងប្រែទៅជាស្រវឹង និយាយខ្លាំងៗ ខ្លះក្អួតចង្អោរ ខ្លះស្រវឹងដេកនៅនឹងកន្លែង ខ្លះប្រើអំពើហិង្សា ជេរគ្នាលឺៗ ។ល។ ទាំងអស់នេះហើយ ដែលធ្វើឲ្យសណ្តាប់ធ្នាប់ និងសីលធម៌ក្នុងសង្គមរបស់យើងនាពេលបច្ចុប្បន្ននេះធ្លាក់ចុះគួរឲ្យកត់សម្គាល់។

ដើម្បីឲ្យជ្រាបកាន់តែច្បាស់ យើងខ្ញុំសូមលើកនូវករណីសិក្សាជាក់ស្តែងមួយចំនួន ដែលមានទាក់ទងនឹងសណ្តាប់ធ្នាប់ និងសីលធម៌ ក្នុងសង្គម ដែលបណ្តាលមកពីគ្រឿងស្រវឹងដូចតទៅ៖

<u>ករណីសិក្សា</u>

**កូនអកតញ្ញូផឹកស្រាស្រវឹងបំផ្លាញទ្រព្យសម្បត្តិដេញកាប់ម្តាយផ្អើលពេញភូមិ៖**

ខេត្តកណ្តាល ៖ បុរសស្រវឹងខូបម្នាក់ត្រូវបាននគរបាលប៉ុស្តិ៍ទឹកវិល ចាប់ខ្លួនបន្ទាប់ពីបុរសនោះផឹកស្រាស្រវឹងជោកជាំខ្លាំងមកដល់ផ្ទះរករឿងម្តាយ វាយបំផ្លាញទ្រព្យសម្បត្តិ និងទាញកាំបិតប៉ុងតោដេញកាប់ម្តាយផ្អើលពេញភូមិ កាលពីម៉ោង៧និង៣០នាទីយប់ ថ្ងៃទី០៩ ឧសភា ២០១៥ នៅចំណុចភូមិព្រែកពោធិ ឃុំទឹកវិល ស្រុកស្អាង ។ ជនសង្ស័យដែលចាប់ខ្លួនពីបទប្រើអំពើហិង្សាក្នុងគ្រួសារឈ្មោះខុម ចិន្តា ភេទប្រុស អាយុ២៥ឆ្នាំ។ ចំណែកស្ត្រីរងគ្រោះជាម្តាយឈ្មោះ ជួប ឌីណា អាយុ៥១ឆ្នាំ មានទីលំនៅភូមិ-ឃុំកើតហេតុខាលើ។ ប្រភពដដែលបានឲ្យដឹងទៀតថា នៅពេលកើតហេតុម៉ោង៧និង៣០នាទីយប់ ថ្ងៃទី០៩ ឧសភា ២០១៥ ជនសង្ស័យឈ្មោះខុម ចិន្តា ត្រឡប់ពីផឹកស្រាស្រវឹងជោកជាំមកដល់ផ្ទះអត់មានបាយហូប ក៏ររករឿងជេរបញ្ចោរឈ្លោះប្រកែកជាមួយម្តាយ ពេលនោះជនសង្ស័យក៏យកក្បាលវីស៊ីឌី និងធុងបាស់បោកទៅលើដី បណ្តាលឲ្យបែកខូច និងបានយកកាំបិតប៉ុងតោដេញកាប់ម្តាយផ្អើលអ្នកភូមិ តែកាប់មិនត្រូវទេដោយសារម្តាយរត់គេចរួច និងមានអ្នកភូមិជួយចាប់ឃាត់ទាន់ កុំអីកូនប្រមឹកកំណាចនេះ កាប់ម្តាយស្លាប់ទៅហើយ។[43] ភ្លាមៗនោះនគរបាលប៉ុស្តិ៍ទឹកវិល បានអន្តរាគមន៍ដល់កន្លែងកើតហេតុឃាត់ខ្លួនឈ្មោះ ខុម ចិន្តា មកសាកសួរ ដោយសារតែកន្លងមកឈ្មោះ ខុម ចិន្តា នេះតែងតែផឹកស្រាស្រវឹង ហើយបង្ករឿងជាមួយម្តាយបងប្អូន និងអ្នកជិតខាងជាញឹកញាប់ លើកនេះទើបម្តាយ និងបងប្អូនទ្រាំទង្វើដដែលៗលែងបានក៏សម្រេចចិត្តដាក់ពាក្យបណ្តឹង ដើម្បីឲ្យនគរបាលកសាងសំណុំរឿងទៅតាមនីតិវិធីច្បាប់។

[43] កោះសន្តិភាព, *កូនអកតញ្ញូផឹកស្រាស្រវឹងបំផ្លាញទ្រព្យសម្បត្តិដេញកាប់ម្តាយផ្អើលពេញភូមិ* (ភ្នំពេញ៖ កោះសន្តិភាព ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ៣)។

<u>ករណីសិក្សា</u>

**ស្រវឹងស្រាជេរ និងវាយអ្នកជិតខាងរបួសត្រូវនគរបាលចាប់ខ្លួន**

ខេត្តបន្ទាយមានជ័យ ៖ យុវជនទំនើងម្នាក់ស្រវឹងស្រាបានស្រែកជេរបញ្ចោ រួចយកយកអំបោសវាយទៅលើស្ត្រីម្នាក់ដែលរស់នៅផ្ទះជិតខាងគ្នា ព្រមទាំងទះកំផ្លៀងចំនួន២ដៃ និងរុញផ្ទប់ទៅនឹងសសរផ្ទះ បណ្តាលឲ្យរងរបួស ត្រូវបានកម្លាំងនគរបាលក្រុងសិរីសោភ័ណ ចាប់ឃាត់ខ្លួន និងបញ្ជូនមកកាន់ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ដើម្បីរៀបចំសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តនៅព្រឹកថ្ងៃទី០១ មេសា ២០១៥នេះ[44]។ អធិការនគរបាលក្រុងសិរីសោភ័ណបានឲ្យដឹងថា ជនសង្ស័យដែលឃាត់ខ្លួនឈ្មោះពុធ ឆៃយ៉ា ភេទប្រុស អាយុ២៥ឆ្នាំ នៅភូមិកន្ទួត សង្កាត់ភ្នៀត ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ចំណែកស្ត្រីរងគ្រោះឈ្មោះផាន់ លីន អាយុ៣៨ឆ្នាំ នៅភូមិជាមួយគ្នា។ លោកអធិការបានបន្តថា រឿងហេតុដែលបង្កឲ្យមានអំពើហិង្សានេះតាមការស្រាវជ្រាវរបស់សមត្ថកិច្ច មុនពេលកើតហេតុស្ត្រីរងគ្រោះបានចេញពីផ្ទះទៅស្រាយអង្រឹងចងមុខផ្ទះ ពេលនោះឈ្មោះ វុន ដែលកំពុងអង្គុយផឹកជាមួយឈ្មោះឆៃយ៉ា ស្រែកឡូឡាថា រកតែដេកពួនមិនបាន ឮដូច្នោះស្ត្រីឈ្មោះ លីន ក៏បានតបតថា ផ្ទះអ៊ុំក៏ផឹក ផ្ទះខ្ញុំក៏ផឹក ពេលនេះមិនទាន់មានអ្នកដេកពួនទេ។ ពេលនោះស្រាប់តែឈ្មោះ ឆៃយ៉ា ដោយអំណាចនៃស្រាចូលពោះផងនោះបានស្ទុះមកជេរស្ត្រីរងគ្រោះ រួចយកអំបោសវាយ និងរុញផ្ទប់នឹងសសរផ្ទះ ព្រមទាំងទះកំផ្លៀងចំនួន២ដៃថែមទៀត។ ជាមួយគ្នានោះដែរ ពេលដែលសមត្ថកិច្ចចុះទៅដល់កន្លែងកើតហេតុ ស្ត្រីរងគ្រោះសុំឲ្យឪពុកម្តាយខាងភាគីល្មើសសងជម្ងឺចិត្ត២លានរៀលដើម្បីបញ្ចប់រឿង តែឪពុកខាងភាគីបង្កបាននិយាយថា សុខចិត្តបង់លុយឲ្យតុលាការ ចំពោះអ្នកឯងតែ១.០០០រៀលក៏មិនបង់ឲ្យដែរ ចង់ប្ដឹងចាប់វាយកទៅណាក៏យកទៅ។ ជនសង្ស័យរូបនេះ ត្រូវបានកម្លាំងជំនាញការិយាល័យរបស់លោករៀបចំសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃទី០១ មេសា ២០១៥នេះផងដែរ។

**២.២.៤.២ ការប៉ះពាល់ដល់ប្រពៃណី**

ក្រលេកមើលពីប្រពៃណីជាតិខ្មែរ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ យើងឃើញថាពលរដ្ឋខ្មែរភាគច្រើន បាននឹងកំពុងតែជ្រើសយកការជួបជុំដោយមានគ្រឿងស្រវឹងនៅកំដរ មិនថាការជួបជុំគ្នាធម្មតា ឬពិធីជប់លៀងនានានោះទេ ជាពិសេសគឺថ្ងៃបុណ្យធំៗ ដូចជាភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំតែ

[44] កោះសន្តិភាព, *ស្រវឹងស្រាជេរ និងវាយអ្នកជិតខាងរបួសត្រូវនគរបាលចាប់ខ្លួន* (ភ្នំពេញ៖ កោះសន្តិភាព ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ៣)។

ម្តង។ នៅពេលដែលការទទួលទានគ្រឿងស្រវឹងនៅពេលចូលឆ្នាំ ក្លាយជាទម្លាប់ គេសង្កេតឃើញការកំសាន្តបែបប្រពៃណី និងការលេងល្បែងប្រជាប្រិយខ្មែរនៅតាមស្រុកភូមិនានា ចាប់ផ្តើមបាត់បង់បន្តិចម្តងៗ ក្រៅពីនេះ អំពើហិង្សា និងបញ្ហាគ្រោះថ្នាក់ចរាចរណ៍តែងតែបង្កជាសោកនាកម្មជារៀងរាល់ឆ្នាំផងដែរ[45]។ កាលពីមុននៅពេលដែលពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរឈានចូលមកដល់ម្តងៗ គេសង្កេតឃើញប្រជាពលរដ្ឋទាំងក្មេងទាំងចាស់ មូលមីនាំគ្នាទីវត្តអារាមជិតឆ្ងាយ និងបានរៀបចំពិធីកំសាន្តបែបប្រពៃណីនៅតាមស្រុកភូមិរបស់ពួកគេ យ៉ាងច្រើនផុលផុស។ តែនៅពេលបច្ចុប្បន្ននេះ ពលរដ្ឋមួយចំនួនប្រើពេលស្ទើពេញមួយរដូវចូលឆ្នាំជួបជុំគ្នាផឹកស៊ី នៅតាមលំនៅដ្ឋានរបស់ពួកគេទៅវិញ។ បើនិយាយពីពិធីបុណ្យសពវិញ យើងក៏ឃើញថាគ្រឿងស្រវឹងក៏ត្រូវបានប្រើប្រាស់ក្នុងកម្មវិធីសោកសង្រេក កាន់ទុក្ខនេះផងដែរ។ ដើម្បីឲ្យមានមនុស្សអង្គុយកំដគ្រួសារសព សមាជិកនៃគ្រួសារសពតែងតែទិញនូវគ្រឿងស្រវឹងផ្សេងៗ ផ្តល់ដល់អ្នកចូលរួមបានទទួលទានធ្វើឲ្យមានភាពអ៊ូអរនៅក្នុងកម្មវិធីបុណ្យសព។ នេះក្លាយទៅជាទម្លាប់អាក្រក់មួយនៅក្នុងសង្គមខ្មែរនាពេលសព្វថ្ងៃ ដែលបានធ្វើឲ្យបាត់បង់នូវតម្លៃនៃជាតិសាសន៍ខ្មែរ និងប្រពៃណីជាតិផងដែរ[46]។

### ២.២.៥ សេដ្ឋកិច្ច

ចំណូលសេដ្ឋកិច្ចរបស់កម្ពុជាដែលមួយផ្នែក គឺទទួលបានពីពន្ធនៃការនាំចូល និងលក់គ្រឿងស្រវឹងនេះ។ ស្រាបៀរ ស្រាទំពាំងបាយជូ ស្រាម៉ាកល្បីៗ ជាច្រើនប្រភេទបានត្រូវនាំចូលមកលក់នៅកម្ពុជា ស្ទើគ្រប់ខេត្ត-រាជធានីនាពេលសព្វថ្ងៃនេះ។ ផលិតផលគ្រឿងស្រវឹងក្នុងស្រុក ដូចជាស្រាបៀរជាដើម ត្រូវបានដាក់លក់ និងចរាចរពាសពេញប្រទេស ហើយមានការគាំទ្រពីសំណាក់អ្នកទទួលទានជាច្រើនគួរឲ្យកត់សម្គាល់។ តែបើក្រលេកមកមើលពីការខាតបង់ប្រាក់របស់រដ្ឋក្នុងការចំណាយលើការជួសជុលលើសម្បត្តិសាធារណៈ ដូចជា បង្គោលភ្លើង របងពុះចែកទ្រូងផ្លូវ ក្បាលនាគចែកទ្រូងផ្លូវ។ល។ ដែលតែងតែខូចខាតដោយសារតែការបុក ឬគ្រោះថ្នាក់ចរាចរណ៍ដោយសារអ្នកបើកបរក្នុងស្ថានភាពស្រវឹង។ ស្ទើរគ្រប់គ្រោះថ្នាក់ចរាចរណ៍ ដែលបង្កឡើងនាពេលយប់ ភាគច្រើនគឺបង្កឡើងដោយសារអ្នកបើកបរស្ថិតក្នុងស្ថានភាពស្រវឹងជោគជាំ ហើយលែងមានម្ចាស់ការក្នុងខ្លួន។ ករណីគ្រោះថ្នាក់មួយចំនួនធំ បានធ្វើឲ្យខូចខាតដល់សម្បិត្តសាធារណៈរបស់រដ្ឋក៏ដូចជាសម្បត្តិឯកជនផ្សេងៗទៀត ព្រមទាំងបានឆក់យកអាយុជីវិតមនុស្សជាច្រើនផងដែរ។ បើតាមការស្រាវជ្រាវរបស់អង្គការចលនាសុខភាពដើម្បីកម្ពុជា បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា

[45] ភិរុណ ឧត្តម, *ទម្លាប់ទទួលទានគ្រឿងស្រវឹងនៅថ្ងៃចូលឆ្នាំ ធ្វើវប្បធម៌ប្រពៃណីប្រឈមនឹងការបាត់បង់* (ភ្នំពេញៈ ថ្មីៗ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៤) (សូមមើលឧបសម្ព័ន្ធ២)។
[46] ប៉ែន បូណា, *នៅពេលដែលសង្គមស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង* (ភ្នំពេញៈ RFI ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

បានខាតបង់ថវិកា ប្រមាណ ៩៥លានដុល្លារ ក្នុងឆ្នាំ២០១១ ដោយសារតែគ្រោះថ្នាក់ចរាចរណ៍ដែលមកពីការប្រើប្រាស់គ្រឿងស្រវឹង[47]។

និយាយពីបញ្ហាសេដ្ឋកិច្ចក្នុងគ្រួសារវិញ យើងសង្កេតឃើញថាប្រាក់ចំណូលរបស់គ្រួសារមួយចំនួន បានចំណាយខ្ជះខ្ជាយជាច្រើន ក្នុងការទិញគ្រឿងស្រវឹងនេះយកមកទទួលទានលើសលុប។ ជាទូទៅក្នុងគ្រួសារមួយ ដែលមានអ្នកចេះទទួលទានគ្រឿងស្រវឹង តែងតែចំណាយប្រាក់ចំនួនពី២០០០រៀល (ស្រាបៀមួយកំប៉ុង)ទៅ៨០០០រៀល(ស្រាបៀរបួនកំប៉ុង)ដើម្បីទទួលទានស្រាបៀរ។ ដោយសារតែមានការជួបជុំគ្នាច្រើនពេក បុរសៗតែងតែចំណាយថវិការបស់ខ្លួនទៅលើការទិញស្រាទាំងអស់នោះយកមកទទួលទាន ជួបជុំមិត្តភក្តិ ឬក្រុមគ្រួសារ។ ការចំណាយថវិកាទៅលើគ្រឿងស្រវឹងនេះ បានប៉ះពាល់ដល់ចំណូលរបស់គ្រួសារជាខ្លាំង។ ប្រសិនបើ អ្នកទទួលទានគ្រឿងស្រវឹងនេះជួបឧប្បត្តិហេតុគ្រោះថ្នាក់ចរាចរណ៍វិញ នោះគ្រួសាររបស់គាត់នឹងត្រូវចំណាយថវិកាជាច្រើនដើម្បីព្យាបាលគាត់ តែប្រសិនបើគាត់ក្លាយជាជនពិការ ឬបាត់បង់ជីវិត នោះគ្រួសាររបស់គាត់នឹងបាត់បង់ប្រាក់ចំណូល និងបាត់បង់សមាជិកគ្រួសារមួយរូបផងដែរ ដែលធ្វើឲ្យគ្រួសាររបស់គាត់ជួបការលំបាក ព្រមទាំងជួបបញ្ហាផ្សេងៗទៀត។

សរុបសេចក្តីមក យើងអាចនិយាបានថា គ្រឿងស្រវឹងនេះ ពិតជាជះឥទ្ធិពលជាខ្លាំងមកលើសង្គមខ្មែរពេលបច្ចុប្បន្ននេះ តាមរយៈរូបភាពជាច្រើន ដូចជា គ្រោះថ្នាក់ចរាចរណ៍ ខ្លះពិការ ខ្លះបាត់បង់ជីវិត បែកបាក់គ្រួសារ ខូចសីលធម៌ ប្រពៃណី និងខូចសណ្តាប់ធ្នាប់សង្គម អសន្តិសុខ។ មិនត្រឹមតែប៉ុណ្ណោះ គ្រឿងស្រវឹងគ្រប់ប្រភេទទាំងអស់នេះ បានធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់អ្នកទទួលទានជាខ្លាំងផងដែរ នេះបើតាមការស្រាវជ្រាវ និងសង្កេតរបស់ក្រុមយើងខ្ញុំ ក៏ដូចជាអង្គការសុខភាពនានា។ គ្រឿងស្រវឹងនេះផងដែរ បានធ្វើឲ្យសង្គមខ្មែរជួបប្រទះនឹងបញ្ហាផ្សេងៗ ធ្វើឲ្យពលរដ្ឋខ្មែរឈ្លក់វង្វេងនឹងវា បាត់បង់ម្ចាស់ការ លែងស្គាល់ខុសត្រូវ ខាតបងទ្រព្យសម្បត្តិជាច្រើន និងខ្លះទៀតអាចឈានដល់បែកបាក់គ្រួសារ ឬបាត់បង់ជីវិតផងដែរ។

[47] អង្គការចលនាសុខភាពដើម្បីកម្ពុជា, *លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង* (ភ្នំពេញ៖ អង្គការចលនាសុខភាពដើម្បីកម្ពុជា២០១៤ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

# ជំពូកទី៣

# ដំណោះស្រាយ និង ទិសដៅអនាគត

## ៣.១ វិធានការទប់ស្កាត់ និងដំណោះស្រាយ

ដើម្បីទប់ស្កាត់នូវឥទ្ធិពលនៃគ្រឿងស្រវឹងនេះ នៅក្នុងសង្គមខ្មែរ ទាំងប្រជាជនខ្លួនឯង ទាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អង្គការសង្គមស៊ីវិលនានា បាននិងកំពុងតែចូលរួមយ៉ាងសកម្មក្នុងការស្វែងរកដំណោះស្រាយវិធានការនានាដើម្បីទប់ស្កាត់ និងបង្កើនការអនុវត្តនូវច្បាប់ដែលជាប់ពាក់ព័ន្ធជាមួយនឹងគ្រឿងស្រវឹងនេះឲ្យបានច្បាស់លាស់ និងប្រសិទ្ធភាពខ្ពស់។ ដើម្បីចូលរួមទប់ស្កាត់នូវឥទ្ធិពលគ្រឿងស្រវឹងនេះ ក្រុមយើងខ្ញុំសូមលើកយកនូវកត្តាជាក់ស្តែងចំនួនប្រាំ ដូចខាងក្រោមនេះដែលជាកត្តាដ៏ចាំបាច់ក្នុងការចូលរួមទប់ស្កាត់ និងកាត់បន្ថយនូវការប្រើប្រាស់គ្រឿងស្រវឹងរួមមាន៖

### ៣.១.១ កត្តាគោលនយោបាយសាធារណៈ

ដើម្បីធ្វើឲ្យសង្គមខ្មែរយើង មានសណ្តាប់ធ្នាប់ ប្រជាពលរដ្ឋរស់នៅក្នុងសន្តិសុខ សុវត្ថិភាពប្រកបដោយសេចក្តីថ្លៃថ្នូ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចេញនូវគោលនយោបាយសាធារណៈមួយចំនួន ដើម្បីចូលរួមធ្វើឲ្យសង្គមនេះមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។ ជាក់ស្តែងគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដែលបង្កើតឡើងដើម្បីទប់ស្កាត់នូវភាពមិនប្រក្រតីមួយចំនួន ដែលអាចនឹងបង្កឲ្យមានជាបទល្មើស និងអំពើហិង្សានៅក្នុងភូមិ-ឃុំ។ល។ បើតាមប្រសាសន៍របស់ឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ បានគូសបញ្ជាក់ថា៖ បញ្ហាគ្រឿងស្រវឹងនេះគឺជាប់ពាក់ព័ន្ធយ៉ាងសំខាន់នឹងបញ្ហាសន្តិសុខសហគមន៍ ព្រោះថាអ្នកស្រវឹងឬអ្នកធ្វើស្រវឹងនេះបានបង្កការភ័យខ្លាចដល់ប្រជាពលរដ្ឋក្នុងភូមិដែលពួកគេរស់នៅ។ ពិតណាស់អ្នកស្រវឹង ឬអ្នកធ្វើស្រវឹងនេះ បានបង្កនូវបញ្ហាជាច្រើនដល់ភូមិ-ឃុំខ្លួន ដូចជាករណីអំពើហិង្សាក្នុងគ្រួសារ ហិង្សាក្នុងរង់ផឹកស៊ី គ្រោះចរាចរណ៍។ល។ ដែលបង្កនូវភាពអសន្តិសុខដល់មូលដ្ឋានរបស់ខ្លួន។ ដូច្នេះគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិតជាសំខាន់ក្នុងការទប់ស្កាត់បញ្ហាទាំងនេះ។ អាជ្ញាធរគ្រប់រូបមានកាតព្វកិច្ចចូលរួមអនុវត្តគោលនយោបាយនេះគ្រប់ៗគ្នា ដើម្បីធ្វើឲ្យមូលដ្ឋានខ្លួនមានសណ្តាប់ធ្នាប់ និងសន្តិសុខហើយប្រជាពលរដ្ឋរស់នៅមានសុភមង្គល គ្មានអំពើហិង្សា។ មិនត្រឹមតែគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនេះប៉ុណ្ណោះទេ ដែលធ្វើការទាក់ទងទៅនឹងគ្រឿងស្រវឹង នោះគឺគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង ដែលនឹងត្រូវបានបង្កើតឡើងនាពេលខាងមុខស្រប

ជាមួយនឹងច្បាប់ត្រួតពិនិត្យគ្រឿងស្រវឹងក៏មានសារៈសំខានផងដែរ។ លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានមានប្រសាសន៍ក្នុងឱកាសបើកកិច្ចពិគ្រោះយោបល់ស្តីអំពី "យន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង" នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ នៅវិមានព្រឹទ្ធសភា បានឲ្យដឹងថា ដើម្បីទប់ស្កាត់ និងកាត់បន្ថយខាងយន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹងគួរត្រូវបានបង្កើតឡើង[48]។ ក្នុងគោលបំណងរួមចំណែកដោះស្រាយបញ្ហាដែលបង្កឡើងដោយឥទ្ធិពលគ្រឿង លោកជំទាវ បានផ្តល់អនុសាសន៍ចំនួន៤ចំនុច ដែលរាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នពាក់ព័ន្ធគួរគប្បីយកមកធ្វើការត្រិះរិះពិចារណាសម្រាប់ជាមាគ៌ាឆ្ពោះទៅរកវិធានការ ឬបទដ្ឋាននានាសំដៅគ្រប់គ្រងគ្រឿងស្រវឹងដូចតទៅ៖

១. ត្រូវតម្លើងពន្ធគ្រឿងស្រវឹង

២. ត្រូវកំហិត ឬហាមការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង

៣. ត្រូវកម្រិតភាពងាយរកបាននៃគ្រឿងស្រវឹង

៤. ត្រូវកម្រិតអាយុអ្នកប្រើប្រាស់គ្រឿងស្រវឹង

អនុសាសន៍ទាំង៤ខាងលើនេះ ត្រូវបានលោកជំទាវឧបនាយករដ្ឋមន្ត្រី សង្ឃឹមយ៉ាងមុតមាំថានឹងអាចដាក់បញ្ចូលក្នុងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង ហើយនឹងត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពដើម្បីទប់ស្កាត់ឥទ្ធិពលគ្រឿងស្រវឹងនៅក្នុងសង្គមកម្ពុជា។

គោលនយោបាយទាំងពីរខាងលើនេះ ពិតជាអាចចូលរួមជួយកក្នុងការកាត់បន្ថយ និងទប់ស្កាត់នូវបញ្ហាទាំងឡាយណាដែលបង្កឡើងដោយជនស្ថិតក្នុងស្ថានភាពស្រវឹង និងអាចជួយធ្វើឲ្យសង្គមកម្ពុជាមានសណ្តាប់ធ្នាប់ និងសន្តិសុខល្អ គ្មានអំពើអបាយមុខផ្សេងៗល។ សង្គមមួយដែលកំពុងធ្លាក់ចូលក្នុងឥទ្ធិពលនៃគ្រឿងស្រវឹង នឹងអាចចាកផុតពីឥទ្ធិពលនេះនាពេលខាងមុខឆាប់ៗតាមរយៈយន្តការនៃការចូលរួមពិភាក្សាពីគ្រប់ភាគីពាក់ព័ន្ធ។

### ៣.១.២ កត្តាច្បាប់

កត្តាច្បាប់ គឺជាកត្តាដ៏ចាំបាច់មួយក្នុងចំណោមកត្តាដទៃទៀត ដែលចូលរួមក្នុងសកម្មភាពកាត់បន្ថយ ក៏ដូចជាទប់ស្កាត់នូវផលប៉ះពាល់ដែលកើតឡើងដោយសារបញ្ហានៃគ្រឿងស្រវឹង។ យើងសង្កេតឃើញថា ពីមួយថ្ងៃទៅមួយថ្ងៃ ការកើនឡើងនៃចំនួនអ្នកសេពគ្រឿងស្រវឹង កំណើននៃក្លឹបកំសាន្ត កន្លែងផឹកស៊ី និងការយកគ្រឿងស្រវឹងមកធ្វើអាជីវកម្មផ្សេងៗ បាននិងកំពុងបង្កនូវក្តី

[48] សុន្ទរកថារបស់លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន, *យន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង* (ភ្នំពេញ៖ ព្រឹទ្ធសភា ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤) (សូមមើលឧបសម្ព័ន្ធ១)។

បារម្ភយ៉ាងខ្លាំងដល់សង្គម ជាមួយនឹងអត្រានៃគ្រោះថ្នាក់មួយចំនួន ដែលបង្ករឡើងមកពីការសេពគ្រឿងស្រវឹងនេះ ដូចជាគ្រោះថ្នាក់ចរាចរណ៍ អំពើហិង្សា អសន្តិសុខសង្គម។ល។ ដូច្នេះវាចាំបាច់ទាមទារឲ្យមាននូវការគ្រប់គ្រងជាក់លាក់ណាមួយទៅលើបញ្ហានេះ ដើម្បីប្រាកដថាយើងអាចមានវិធានការទប់ស្កាត់នូវបញ្ហានេះតាមរយៈយន្តការផ្សេងៗជាពិសេសគឺច្បាប់ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើគ្រឿងស្រវឹង ព្រមទាំងច្បាប់ពាក់ព័ន្ធដទៃទៀតដែលមានស្ថានទម្ងន់ទោសលើជនបង្កដែលស្ថិតក្នុងស្ថានភាពស្រវឹង។

បច្ចុប្បន្ននេះ យើងអាចដឹងបានថា ច្បាប់ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យគ្រឿងស្រវឹងនៅកម្ពុជានៅមិនទាន់បានបង្កើតឡើងនូវឡើយទេ។ ប៉ុន្តែយើងសង្កេតឃើញថា ច្បាប់ដែលពាក់ព័ន្ធនឹងគ្រឿងស្រវឹងនេះត្រូវបានគេយកមកប្រើប្រាស់នៅក្នុងការទប់ស្កាត់ និងបង្ការទៅលើបញ្ហានេះផងដែរ។ តួយ៉ាង ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មីជាដើម។

ច្បាប់ទាំងនេះ មានគោលដៅគ្រប់គ្រង និងទប់ស្កាត់មិនឲ្យមានបទល្មើសដែលទាក់ទងនឹងគ្រឿងស្រវឹងនេះ។ ម្យ៉ាងវិញទៀតច្បាប់ទាំងនេះក៏បានរួមចំណែកយ៉ាងសំខាន់នៅក្នុងសង្គមកម្ពុជាពោលគឺថែរក្សាសណ្តាប់ធ្នាប់សង្គម សុវត្ថិភាពចរាចរណ៍ ការធ្វើដំណើរ ព្រមទាំងលើកកម្ពស់សេចក្តីថ្លៃថ្នូរបស់ប្រជាពលរដ្ឋជារៀងរាល់ថ្ងៃ។ ហើយអ្វីដែលរឹតតែសំខាន់ទៀតនោះ នៅពេលដែលមានបទល្មើសកើតឡើង ជាក់ស្តែងទាក់ទងនឹងបញ្ហាខាងលើគឺមានការកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់រួចទៅហើយ[49]។ ឧទាហរណ៍ បទល្មើសបង្ករគ្រោះថ្នាក់ ចរាចរណ៍ នៅពេលដែលជនល្មើសសេពគ្រឿងស្រវឹងហួសការកំណត់ពីច្បាប់ នោះនឹងត្រូវផ្តន្ទាទោសជារួមៈ

- ផ្តន្ទាទោសដាក់ពន្ធនាគារ
- ការពិន័យជាប្រាក់
- ការព្យួរលិខិតបើកបរ
- ការហាមឃាត់មិនឲ្យបើកបររថយន្ត ទោះជាប្រភេទណាក៏ដោយ

ប៉ុន្តែប្រសិនបើមានតែច្បាប់តែមួយមុខ ពិតជាមិនគ្រប់គ្រាន់ឡើយ សំរាប់ការចូលរួមទប់ស្កាត់និងបង្ការទៅលើគ្រោះថ្នាក់ ដែលបង្ករឡើងពីការសេពគ្រឿងស្រវឹង។ ផ្ទុយទៅវិញ ការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងឡាយជាពិសេសប្រជាពលរដ្ឋ និងអាជ្ញាធរមានសមត្ថកិច្ច ទើបជាកត្តាដែលមានប្រសិទ្ធភាពបំផុត ក្នុងការចូលរួមការអនុវត្តច្បាប់ទាំងនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងថែមទៀត។

---

[49] លោក ប៉ែន យុន. *ការផ្សព្វផ្សាយ ច្បាប់ចរាចរណ៍ដល់និស្សិត RUPP ជាង១០០នាក់.* (ភ្នំពេញ: CKCC. ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

### ៣.១.៣ កត្តារាជរដ្ឋាភិបាល

ពិតណាស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់ក្នុងបញ្ហាគ្រឿងស្រវឹងនេះជាខ្លាំងនាពេលបច្ចុប្បន្ននេះ។ សព្វថ្ងៃនេះ រាជរដ្ឋាភិបាលបានសហការជាមួយអង្គការដៃគូទាំងជាតិ និងអន្តរជាតិជាច្រើនដើម្បីចូលរួមទប់ស្កាត់នូវឥទ្ធិពលគ្រឿងស្រវឹងនេះនៅក្នុងសង្គមខ្មែរ។ យើងសង្កេតឃើញថា ការចេញបញ្ជាពីសំណាក់រាជរដ្ឋាភិបាល ឲ្យក្រសួងពាក់ពន្ធទាំងឡាយណាដែលធ្វើការទាក់ទងនឹងគ្រឿងស្រវឹងនេះឲ្យចូលរួមទប់ស្កាត់ ពិតជាមានភាពសកម្ម ដែលវាជាសញ្ញាបង្ហាញថាកិច្ចការនេះ គឺកំពុងលេចចេញជារូបរាងឡើងហើយ។ ឧទាហរណ៍ជាក់ស្តែង ដូចជាក្រសួងព័ត៌មានបានចេញនូវសារាចរណែនាំ និងសេចក្តីជូនដំណឹងដែលទាក់ទងនឹងការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនៅតាមកញ្ចក់ទូរទស្សន៍ និងវិទ្យុ។ ចំណែកក្រសួងអប់រំ យុវជន និងកីឡាក៏បានចេញនូវសេចក្តីណែនាំស្តីអំពី ការហាមឃាត់ការប្រើប្រាស់គ្រឿងស្រវឹង នៅក្នុងបរិវេណគ្រឹះស្ថានសាធារណៈ និងឯកជន។ ដូចគ្នាផងដែរ ជារៀងរាល់ពេលឈប់សម្រាកចូលឆ្នាំប្រពៃណីជាតិ និងបុណ្យភ្ជុំបិណ្ឌម្តងៗ រាជរដ្ឋាភិបាលតែងតែបានធ្វើការផ្សព្វផ្សាយណែនាំអំពីផលប៉ះពាល់ដែលបណ្តាលមកពីការទទួលគ្រឿងស្រវឹងហួសកម្រិត នៅតាមកញ្ចក់ទូរទស្សន៍ វិទ្យុ សារព័ត៌មាននានា ក៏ដូចជាតាមបដាផ្សព្វផ្សាយតាមផ្លូវសាធារណៈជាដើម ដើម្បីដាស់តឿន និងក្រើនរំលឹកដល់ប្រជាពលរដ្ឋគ្រប់រូប។ នាពេលសព្វថ្ងៃនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកំពុងតែយកចិត្តទុកដាក់តាក់តែងនូវសេចក្តីព្រៀងច្បាប់ស្តី *ការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង*។ នៅក្នុងពិធីប្រគល់រង្វាន់ដល់ជ័យលាភី ការប្រកួតតែងកំណាព្យ គូរគំនូរ ស្តីពីផលប៉ះពាល់នៃគ្រឿងស្រវឹង នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ នៃព្រឹទ្ធសភា បានជំរុញឲ្យស្ថាប័នពាក់ពន្លឿនការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី **ការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង**[50] នេះឲ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ហានិភ័យ និងការពារសុខុមាលភាពជូនប្រជាពលរដ្ឋ។ លោកជំទាវបានបញ្ជាក់ឲ្យដឹងផងដែរថា លោកជំទាវនឹងទទួលយកនូវការផ្តល់យោបល់របស់ក្រុមអ្នកឯកទេសជាន់ខ្ពស់ អ្នកច្បាប់ ប្រជាពលរដ្ឋ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិលដើម្បីធ្វើឲ្យច្បាប់ថ្មីនេះមានប្រសិទ្ធភាពខ្ពស់។ លោកជំទាវបានទទួលស្គាល់ថា វាជាការពិតណាស់ខ្លឹមសារនៃច្បាប់ថ្មីនេះ គឺជាសារព្រមានមួយសម្រាប់ជួយដាស់ស្មារតីដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីហានិភ័យ នៃការប្រើប្រាស់គ្រឿងស្រវឹង និងជាជំនួយស្មារតីដល់អង្គការនីតិប្រតិបត្តិ នីតិប្បញ្ញត្តិ ក្នុងការដាក់ចេញនូវវិធានការសមស្រប និងប្រកបដោយប្រសិទ្ធភាព ដើម្បីកែ

[50]របាយការណ៍ស្តីអំពី *ការវិវឌ្ឍ និងកិច្ចខិតខំប្រឹងប្រែងជារួមឲ្យមានច្បាប់ស្តីអំពី ការគ្រប់គ្រងគ្រឿងស្រវឹង* ដោយលោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទីផ នៃព្រឹទ្ធសភា (ភ្នំពេញ៖ ព្រឹទ្ធសភា ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ១)។

លម្អគុណភាពនៃសេចក្តីព្រាងច្បាប់នេះ ដែលនឹងត្រូវបញ្ជូនទៅរដ្ឋសភាជាតិនាពេលឆាប់ៗខាងមុខនេះ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពិតជាសង្ឃឹមថា ច្បាប់ថ្មីមួយនេះដែលនឹងចេញជារូបរាងនាពេលខាងមុខនេះ ដែលអាចជួយទៅដល់ការទប់ស្កាត់ និងកាត់បន្ថយនូវឥទ្ធិពលរឿងស្រវឹងនេះ។

### ៣.១.៤ ការចូលរួមពីសង្គមស៊ីវិល

ជាការពិតណាស់ មិនត្រឹមតែរាជរដ្ឋាភិបាល និង ប្រជាពលរដ្ឋប៉ុណ្ណោះទេ ដែលចូលរួមក្នុងការទប់ស្កាត់ និងបង្ការទៅលើបញ្ហាដែលបង្ករឡើងពីការប្រើប្រាស់គ្រឿងស្រវឹង ក៏ដូចជាបទល្មើសផ្សេងៗដែលកើតចេញពីការសេពគ្រឿងស្រវឹង អង្គការសង្គមស៊ីវិល ក៏បានរួមចំណែកយ៉ាងសកម្មផងដែរនៅក្នុងការបង្ការទប់ស្កាត់ ព្រមជាមួយនឹងការផ្សព្វផ្សាយអំពីផលប៉ះពាល់ដែលបណ្តាលមកពីសេពគ្រឿងស្រវឹងក្នុងសង្គម។

បច្ចុប្បន្នគ្រឿងស្រវឹងកំពុងក្លាយទៅជាបញ្ហាចោទដ៏ធ្ងន់ធ្ងរមួយសំរាប់ប្រទេសកម្ពុជា ដែលទាមទារឲ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ ក្នុងនោះអង្គការសង្គមស៊ីវិល និងសមាគមយុវជនមួយចំនួន បាន និងកំពុងខិតខំរ៉ៈរកប្រមូលផ្តុំនូវព័ត៌មាន ក៏ដូចជាទិន្នន័យផ្សេងៗ ដើម្បីធ្វើការសុំឲ្យព្រឹទ្ធសភា រដ្ឋសភា និងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមក្នុងវេទិកាផ្តល់យោបល់ស្តីពីវិធានការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង ក៏ដូចជាការសុំបង្កើតច្បាប់គ្រប់គ្រងគ្រឿងស្រវឹង[51]។

ជាក់ស្តែង យើងសង្កេតឃើញថាមានអង្គការសង្គមស៊ីវិលជាច្រើនដែលជាដៃគូរ ជាមួយរាជរដ្ឋាភិបាល ក៏បានចូលរួមចំណែកកាត់បន្ថយនូវអត្រានៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមនេះ។ បើតាមសុន្ទរកថារបស់ លោកជំទាវ ម៉ែន សំអន ក្នុងឱកាសបើកកិច្ចពិគ្រោះយោបល់ ស្តីអំពី "យន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង" បានឲ្យដឹងថា មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP) និងអង្គការអាយអូជីធីអន្តរជាតិ (IOGT International) នៃប្រទេសស៊ុយអែត អង្គការចលនាដើម្បីសុខភាពកម្ពុជា (CMH) និងដៃគូសុវត្ថិភាពចរាចរណ៍សកល (GRSP) ដែលបានរួមសហការជាមួយស្ថាប័នជាដៃគូជាតិ និងអន្តរជាតិ ក្នុងចក្ខុវិស័យដ៏ជាក់លាក់ គឺកាត់បន្ថយការចំណាយរបស់សង្គម និងសង្គ្រោះអាយុជីវិតមនុស្ស ដែលរងផលប៉ះពាល់ដោយសារតែការសេពគ្រឿងស្រវឹង និងប្រើប្រាស់ទំនិញដែលមានសារធាតុញៀន ដូចជា

[51] អ៊ុក សារបូរី, *សង្គមស៊ីវិលលើកអនុសាសន៍សុំបង្កើតច្បាប់គ្រប់គ្រងគ្រឿងស្រវឹង* (ភ្នំពេញ: វិទ្យុអាស៊ីសេរី ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤) (សូមមើលឧបសម្ព័ន្ធ២)។

គ្រឿងស្រវឹងនេះ[52]។ អង្គការសង្គមស៊ីវិល ទាំងអស់នេះហើយ ដែលបានចូលរួមជួយទប់ស្កាត់ និងផ្សព្វផ្សាយពីផលប៉ះពាល់នៃការសេពគ្រឿងស្រវឹងនេះ ទៅកាន់ប្រជាពលរដ្ឋកម្ពុជា។ជាក់ស្តែងអង្គការចលនា ដើម្បីសុខភាពកម្ពុជា (CMH) ដែលមានលោក មុំ គង់ ជាប្រធានប្រតិបត្តិបានប្រសាសន៍ក្នុងសិក្ខាសាលាស្តីពី "គ្រឿងស្រវឹង និងវិធានការកាត់បន្ថយការប្រើប្រាស់" បានឲ្យដឹងយ៉ាងដូច្នេះថា គ្រឿងស្រវឹងជាផ្នែកមួយ ដែលសម្លាប់ជីវិតមនុស្សយ៉ាងសាហាវឃោឃៅ ជាទីបំផុត។ ហើយជាពិសេស ភាគច្រើននៃគ្រោះថ្នាក់ចរាចរណ៍ អំពើហិង្សាក្នុងគ្រួសារ និងអ្នកដទៃ ខាតបង់ថវិកា រួមទាំងជំងឺផ្សេងៗជាច្រើនទៀត ដែលទាំងអស់នេះសុទ្ធសឹងតែបណ្តាលមកពីការទទួលទានគ្រឿងស្រវឹងតែម្តង ដែលធ្វើឲ្យមនុស្សមិនអាចគ្រប់គ្រងស្មារតីរបស់ខ្លួនលែងបានស្ទើរតែ១០០ភាគរយ[53]។ ដូច្នេះការចូលរួមពីសំណាក់សង្គមស៊ីវិល ពិតជាបានរួមចំណែកសំខាន់ផងដែរក្នុងដំណើរនៃការកាត់បន្ថយនៃប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គម ព្រមទាំងការរៀបចំឲ្យមាននូវច្បាប់ទប់ស្កាត់ និងត្រួតពិនិត្យលើគ្រឿងស្រវឹងក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានឆាប់រហ័សក្នុងគោលដៅកាត់បន្ថយបង្ការទប់ស្កាត់ទៅលើហានិភ័យ និងការពារសុខុមាលភាពជូនប្រជាពលរដ្ឋ។

### ៣.១.៥ កត្តាប្រជាជន

ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូប គឺមានកាតព្វកិច្ចចូលរួមកិច្ចការងារសង្គម ដើម្បីជួយឲ្យសង្គមជាតិមានសន្តិសុខ សុខដុមរមនា និងរីកចម្រើនទៅមុខ ។ ដូច្នេះដើម្បីទប់ស្កាត់នូវឥទ្ធិពលគ្រឿងស្រវឹងនេះនៅក្នុងសង្គមខ្មែរ ពលរដ្ឋគ្រប់រូបត្រូវចូលរួមដូចតទៅ៖

- តាមដានពត៌មាន ឬកម្មវិធីអប់រំសុខភាពផ្សេងៗ ដែលទាក់ទងទៅនឹងផលប្រយោជន៍ និងផលប៉ះពាល់នៃគ្រឿងស្រវឹងនេះ ដើម្បីយល់ដឹង និងផ្សព្វផ្សាយបន្តទៅកាន់អ្នកដទៃ។
- ចូលរួមរាល់សិក្ខាសិលា ព្រមទាំងកម្មវិធីមួយចំនួនផ្សេងៗដែលទាក់ទងនឹងគ្រឿងស្រវឹងនៅតាមសហគមន៍ខ្លួនដើម្បីយល់ពីអត្ថប្រយោជន៍ និងគុណវិបត្តិរបស់វា។
- តាមដាន និងយល់ដឹងពីច្បាប់ គោលនយោបាយ សារាចរ ។ល។ ដែលទាក់ទងនឹងការប្រើប្រាស់គ្រឿងស្រវឹង។
- ផ្សព្វផ្សាយណែនាំទៅកាន់អ្នកដទៃដូចជា ក្រុមគ្រួសារ អ្នកជិតខាង មិត្តភក្តិ ឲ្យពួកគាត់យល់ដឹងពីផលប៉ះពាល់នៃការទទួលទានគ្រឿងស្រវឹងលើសកំណត់។

---

[52] សុន្ទរកថារបស់លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន, *យន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង* (ភ្នំពេញ៖ ព្រឹទ្ធសភា ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤) (សូមមើលឧបសម្ព័ន្ធ១)។

[53] ដើមអម្ពិល ID-011, *គ្រឿងស្រវឹង សម្លាប់ជីវិតមនុស្ស យ៉ាងសាហាវបំផុត* (ភ្នំពេញ៖ ដើមអម្ពិល ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥) (សូមមើលឧបសម្ព័ន្ធ២)។

- ណែនាំកូនៗដែលមិនទាន់គ្រប់អាយុ កុំឲ្យចង់សាក និងទទួលទានគ្រឿងស្រវឹងដូចជា ស្រាផ្លែឈើ ស្រា ស ស្រាក្រឡុក ជាដើម។ ប្រសិនបើអាណាព្យាបាល មិនយកចិត្តទុកទៅលើកូនៗទេនោះកូនៗរបស់ពួកគាត់នឹងធ្លាក់ក្នុងឥទ្ធិពលគ្រឿងស្រវឹងតាំងពីវ័យក្មេង ហើយអាចបណ្តាលឲ្យមានហានិភ័យខ្ពស់ផងដែរ ទៅដល់សុខភាពរបស់ពួកគេទាំងពេលបច្ចុប្បន្ន និងអនាគត។
- ជាពុទ្ធសាសនិកជន ប្រជាពលរដ្ឋគ្រប់រូប គប្បីតែប្រកាន់ភ្ជាប់នូវការ ***រក្សាសីលប្រាំ ចាំសីលប្រាំបី*** ដែលជាមាគ៌ាឆ្ពោះទៅរកសេចក្តីចម្រើន សុភមង្គល ក្នុងគ្រួសារ និងសង្គមជាតិរបស់យើង។
- មិនគួរលក់ ឬទទួលទានគ្រឿងស្រវឹង រាល់ថ្ងៃសីល ថ្ងៃបុណ្យមាឃបូជា វិសាខបូជា និងថ្ងៃកាន់មរណៈទុក្ខជាតិ និងមុនថ្ងៃបោះឆ្នោតជាតិផ្សេងៗ។

មិនត្រឹមតែប៉ុណ្ណឹងទេ ប្រជាជនខ្លួនឯងផ្ទាល់ ក៏មិនគួរផ្សព្វផ្សាយពីគ្រឿងស្រវឹងនេះ តទៅអ្នកដទៃជុំវិញខ្លួនឡើយជៀសវាងពួកគេ ចង់សាក ចង់ភ្លក់ ចង់ដឹងពីគ្រឿងស្រវឹងនេះ។ បើតាមទស្សនៈយល់ឃើញផ្ទាល់ខ្លួនរបស់ កញ្ញា **ស៊ន សៀវម៉ី** ម្ចាស់មេដាយមាស តេក្វាន់ដូ កីឡាអាស៊ីឆ្នាំ ២០១៤ បានប្តេជ្ញាថា រូបនាងនឹងមិនចូលរួមក្នុងការផ្សព្វផ្សាយផលិតគ្រឿងស្រវឹង ឲ្យក្រុមហ៊ុនគ្រឿងស្រវឹងណាមួយឡើយ។ កញ្ញាបានគូសបញ្ជាក់ថា ប្រសិនបើកញ្ញាចូលរួមផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង ហាក់បីដូចកញ្ញាលើកទឹកចិត្តឲ្យយុវជនកម្ពុជាក្រេបគ្រឿងស្រវឹងអញ្ចឹង។ កញ្ញាបានឲ្យដឹងថា កញ្ញាចង់ក្លាយជាយុវជនគំរូមួយរូបដែលមិនប៉ះពាល់ និងសេពគ្រឿងស្រវឹងនេះដល់យុវជនខ្មែរគ្រប់ឲ្យយកគំរូបតាមនាង[54]។ លើសពីនេះទៅទៀត នៅតាមសហគមន៍នានា ដូចជាសហគមន៍ប្រជាជនខ្មែរ-ឥស្លាម ក៏បានចូលរួមមិនប្រើប្រាស់គ្រឿងស្រវឹងនេះផងដែរ ដោយផ្អែកលើជំនឿសាសនារបស់ខ្លួន ដែលធ្វើឲ្យសហគមន៍ខ្លួន គ្មានការលក់ និងការទទួលទានគ្រឿងស្រវឹងនេះ។

ប្រសិនបើប្រជាពលរដ្ឋកម្ពុជាគ្រប់រូបពិតជា អាចអនុវត្តតាមចំណុចដូចដែលបានរៀបរាប់ខាងលើនេះបាន នោះសង្គមខ្មែរទាំងមូលពិតជាអាចកាត់បន្ថយនូវឥទ្ធិពលគ្រឿងស្រវឹងបានមួយភាគធំផងដែរ ហើយសង្គមខ្មែរនឹងជួបតែសេចក្តីសុខ សុភមង្គល រីកចម្រើនទៅមុខជានិច្ចជាក់ជាពុំខាន។

[54] ស៊ន សៀវម៉ី, វីដេអូស្តីពី *ការមិនផ្សព្វផ្សាយគ្រឿងស្រវឹង របស់កញ្ញា ស៊ន សៀវម៉ី* (ភ្នំពេញ៖ អង្គការចលនាដើម្បីសុខភាពកម្ពុជា ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥)អាចរកទស្សនាបាននៅ https://www.youtube.com/watch?v=QvO9qv8-Jl4។

## ៣.២ ទិសដៅអនាគត

ដូចដែលយើងបានដឹងហើយថា ឥទ្ធិពលគ្រឿងស្រវឹង កំពុងតែកើនឡើងជាលំដាប់ ហើយវាបានធ្វើឲ្យប៉ះពាល់ដល់ប្រជាជន សេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។ សុខភាព និងជីវិតប្រជាជនខ្មែរជាច្រើនពាន់នាក់បានត្រូវប៉ះពាល់ដោយសារគ្រឿងស្រវឹងនេះ។ គ្រោះថ្នាក់ចរាចរណ៍ជាច្រើនដែលភាគច្រើនបង្កឡើងដោយអ្នកបើកបរក្នុងស្ថានភាពស្រវឹង ដែលបានឆក់យកជីវិតមនុស្សជាច្រើនរយនាក់ជារៀងរាល់ឆ្នាំ និងធ្វើឲ្យខាតបង់ថវិកាជាច្រើនរយលានដុល្លារ ក្នុងការជួសជុលហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាសម្បត្តិសាធារណៈ និងឯកជនផងដែរ។ ដើម្បីទប់ស្កាត់នូវឥទ្ធិពលនេះ អង្គការសង្គមស៊ីវិលនានា ជាពិសេសអង្គការចលនាដើម្បីសុខភាពកម្ពុជាបានលើកឡើងថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គួរកំណត់ទីតាំងលក់គ្រឿងស្រវឹងឲ្យបានសមស្រប ដើម្បីកាត់បន្ថយលទ្ធភាពងាយរកទិញគ្រឿងស្រវឹងនេះ។ កន្លែងលក់គ្រឿងស្រវឹងគួរតែមានអាជ្ញាប័ណ្ណ អនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងការស្ទង់មតិរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជាបានឲ្យដឹងថា ប្រជាពលរដ្ឋកម្ពុជាប្រមាណ៩៣ភាគរយ ចង់ឲ្យរាជរដ្ឋាភិបាលហាមឃាត់ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនេះគ្រប់រូបភាព។ ក្រសួងព័ត៌មាន ក៏បានផ្លាប់ចេញនូវសារាចរណែនាំស្ថាននីយ៍ទូរទស្សន៍ និងវិទ្យុ ឲ្យកំណត់ពេលវេលានៃការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនេះ។ ក៏ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាមើលឃើញថា សារាចរនេះមើលទៅហាក់បីដូចជានូវមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់នៅឡើយ ព្រោះស្ទើរតែគ្រប់ស្ថានីយ៍ទូរទស្សន៍ (លើកលែងតែស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា "ទទក") តែស្ថានីយ៍វិទ្យុមួយចំនួនផ្សេងទៀត នៅតែបន្តការផ្សាយពាណិជ្ជកម្មគ្រឿង ស្រវឹងនេះ។ ប្រជាពលរដ្ឋជាង៩២ភាគរយបានយល់ថា ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនេះជាកត្តាចម្បងនាំឲ្យកុមារ និងយុវជនចាប់ផ្តើមប្រើប្រាស់ និងលើកទឹកចិត្តដល់ពួកគេឲ្យបន្តប្រើប្រាស់គ្រឿងស្រវឹងនេះ។ ដូច្នេះហើយទើបប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងបញ្ហានេះទទូចសុំឲ្យក្រសួងព័ត៌មាន ស្ថាប័នពាក់ព័ន្ធនានាមេត្តាយកចិត្តទុកដាក់ និងអនុវត្តសារាចរនេះ ឬគួរតែបញ្ឈប់ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងនេះតែម្តង។ ដូចគ្នានេះផងដែរ បើតាមអង្គការសុខភាពពិភពលោក(WHO) បានឲ្យដឹងថា ការតំឡើងពន្ធលើផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទគឺជាមធ្យោបាយមួយដ៏ល្អបំផុត ក្នុងការទប់ស្កាត់នូវឥទ្ធិពលនៃគ្រឿងស្រវឹងនេះ។ ការតំឡើងពន្ធ គឺជាយុទ្ធសាស្ត្រសកលមួយ ដែលមានប្រសិទ្ធភាពបំផុតដើម្បីកាត់បន្ថយនូវការប្រើប្រាស់គ្រឿងស្រវឹងនេះ។ នៅពេលដែលពន្ធនៃផលិតផលគ្រឿងស្រវឹងឡើង នោះចំណូលពន្ធរបស់រដ្ឋក៏កើនឡើងដែរ ហើយការប្រើប្រាស់គ្រឿងស្រវឹងក៏ធ្លាក់ចុះផងដែរ។ ឧទាហរណ៍ជាក់ស្តែង នៅបណ្តាប្រទេសសមាជិកអាស៊ានមួយចំនួន ដូចជាប្រទេសម៉ាឡេស៊ី និងព្រុយណេ ផលិតផលគ្រឿងស្រវឹង

គ្រប់ប្រភេទ គឺមានតម្លៃថ្លៃជាងបណ្តាសមាជិកអាស៊ាននានា។ ការដាក់តំឡើងពន្ធលើផលិតផលគ្រឿងស្រវឹងនេះ បានធ្វើឲ្យប្រទេសទាំងពីរនេះមិនសូវមានបញ្ហា ឬគ្រោះថ្នាក់ផ្សេងៗដែលកើតឡើងដោយសារគ្រឿងស្រវឹងនេះ។ ជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋកម្ពុជាប្រមាណ៩៥ភាគរយបានស្នើសុំឲ្យរាជរដ្ឋាភិបាលហាមឃាត់ការលក់គ្រឿងស្រវឹងដល់កុមារ និងយុវវ័យដែលមិនទាន់គ្រប់អាយុ ព្រោះដោយសារតែប្រជាពលរដ្ឋកម្ពុជានាពេលសព្វថ្ងៃនេះបាននិងកំពុងឃើញកុមារ និងយុវវ័យដែលមិនទាន់គ្រប់អាយុមួយចំនួនធំ បាននឹងកំពុងតែធ្លាក់ចូលក្នុងការប្រើប្រាស់គ្រឿងស្រវឹងនេះ។ ជាងនេះទៅទៀត ប្រជាពលរដ្ឋកម្ពុជាជាង៩៦ភាគរយ រួមជាមួយអង្គការសង្គមស៊ីវិលនានាបានស្នើសុំយ៉ាងទទូចដល់រាជរដ្ឋាភិបាលឲ្យចាត់វិធានការដែលមានប្រសិទ្ធភាពបន្ថែមទៀត ដើម្បីកាត់បន្ថយនូវការប្រើប្រាស់គ្រឿងស្រវឹង។ ក្នុងន័យនេះ ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងផលិតផលគ្រឿងស្រវឹងគឺជាវិធានការដ៏មានប្រសិទ្ធភាពបំផុត។ នៅពេលដែលច្បាប់ស្តីពីការគ្រប់គ្រងផលិតផលគ្រឿងស្រវឹងនេះត្រូវបានអនុម័ត និងមានការអនុវត្តជាក់ច្បាស់ នោះការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសង្គមខ្មែរ នឹងត្រូវកាត់បន្ថយមួយចំនួនផងដែរ។

សរុបមកក្នុងចំនុចខាងលើនេះ យើងអាចនិយាយបានថា កត្តាដែលបានរៀបរាប់ទាំងអស់រួមផ្សំជាមួយការចូលរួមពីសំណាក់អង្គការសង្គមស៊ីវិល អាចធ្វើឲ្យឥទ្ធិពលនៃគ្រឿងស្រវឹង នៅក្នុងសង្គមខ្មែរអាចកាត់បន្ថយមួយចំនួនធំផងដែរ។ ទាំងរាជរដ្ឋាភិបាល ទាំងសង្គមស៊ីវិល បាននិងកំពុងតែខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការទប់ស្កាត់ និងស្វែងរកនូវដំណោះស្រាយជាច្រើន ដើម្បីកាត់បន្ថយនូវឥទ្ធិពលនៃគ្រឿងស្រវឹងនេះ ដែលកំពុងតែបំពុលសង្គម និងប្រជាជនកម្ពុជា។ មិនត្រឹមតែមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាល និងអង្គការ សង្គមស៊ីវិលប៉ុណ្ណោះទេ ក៏ទាមទារឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋខ្លួនឯងផងដែរ។ ប្រជាពលរដ្ឋគ្រប់រូប ត្រូវចេះយល់ដឹងពីបញ្ហាដែលបង្កឡើងដោយសារការទទួលទានគ្រឿងស្រវឹងនេះ និងចូលរួមផ្សព្វផ្សាយបន្តទៅកាន់អ្នកនៅជុំវិញឲ្យបានយល់ដឹង និងការពារខ្លួន។ ដើម្បីកាត់បន្ថយនូវការប្រើប្រាស់គ្រឿងស្រវឹងនេះ ប្រជាពលរដ្ឋក៏ដូចជាអង្គការនានាមួយចំនួន បានសំណូមពរឲ្យរាជរដ្ឋាភិបាលកម្ពុជា ធ្វើការកាត់បន្ថយ ឬបញ្ឈប់រាល់ការផ្សាយពាណិជ្ជកម្មពីផលិតផលគ្រឿងស្រវឹង ធ្វើការកំណត់ និងផ្តល់អាជ្ញាប័ណ្ណដល់កន្លែងលក់គ្រឿងស្រវឹង ហាមប្រាមការលក់គ្រឿងស្រវឹងដល់កុមារ ឬយុវវ័យមិនទាន់គ្រប់អាយុ តំឡើងពន្ធលើផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ។ ជាពិសេសសំណូមពរដល់រាជរដ្ឋាភិបាលពន្លឿនលើការអនុម័តច្បាប់ស្តី "ការគ្រប់គ្រងផលិតផលគ្រឿងស្រវឹង" ឲ្យបានឆាប់រហ័ស ព្រោះថាច្បាប់នេះអាចជួយទប់ស្កាត់ និងកាត់បន្ថយនូវការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ។

# សេចក្តីសន្និដ្ឋាន

យោងទៅតាមការបកស្រាយខាងលើនេះ យើងអាចសន្និដ្ឋានបានថា គ្រឿងស្រវឹងពិតជាមានច្រើនប្រភេទណាស់ ហើយវាបានជះឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងសង្គមខ្មែរយើងនាពេលបច្ចុប្បន្ននេះ។ ជាពិសេស វាបានបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់សីលធម៌ ប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់សង្គមជាតិ។

ការប្រើប្រាស់គ្រឿងស្រវឹង គ្មានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវស្របតាមច្បាប់ ពិតជាធ្វើឲ្យសង្គមជាតិមានភាពឥតសណ្តាប់ធ្នាប់ គ្រោះថ្នាក់ អំពើហិង្សា បទល្មើសផ្សេងៗជាច្រើនទៀត។ យ៉ាងណាមិញ បើទោះបីជាមានលក្ខណៈបែបនេះពិតមែន ប៉ុន្តែយើងសង្កេតឃើញថា ការចូលរួមពីសំណាក់គ្រប់ភាគីដែលពាក់ព័ន្ធ ដែលធ្វើការទាក់ទងនឹងគ្រឿងស្រវឹង គឺជាកត្តាយ៉ាងសំខាន់បំផុតនៅក្នុងការកាត់បន្ថយ ក៏ដូចជាស្វែងរកនូវវិធានការក្នុងការទប់ស្កាត់នៃការកើនឡើងចំពោះការប្រើប្រាស់គ្រឿងស្រវឹង ការផ្សព្វផ្សាយពង្វក់ពីសំណាក់ក្រុមហ៊ុនផលិតស្រាបៀរ ទៅដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវជន។ ការពន្លឿនការអនុម័តច្បាប់ ក៏ដូចជាតាក់តែសេចក្តីព្រាងគោលនយោបាយស្តីពីការត្រួតពិនិត្យ និងគ្រប់គ្រងគ្រឿងស្រវឹង ពិតជាមានភាពចាំបាច់បំផុតសំរាប់ប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ន ព្រោះបច្ចុប្បន្នការធ្វើអាជីវកម្ម ការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងក៏ដូចជាការទទួលទានគ្រឿងស្រវឹងក្នុងសង្គមរបស់យើង ពិតជាមានភាពអណាធិបតេយ្យ ពោលគឺមិនអាចគ្រប់គ្រងបានច្បាស់លាស់។ ជាពិសេស គឺការកើនឡើងនៃក្លឹបកំសាន្ត កន្លែងផឹកស៊ីពិតជាបានស្រូបទាក់ទាញយកនូវអ្នកទទួលទាននូវគ្រឿស្រវឹងយ៉ាងច្រើនពីមួយថ្ងៃទៅមួយថ្ងៃ គួរឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងពីសុវត្ថិភាពក្នុងការបើកបរ សុខភាពអ្នកប្រើប្រាស់ នឹងការខាតបង់ផ្សេងៗទៀតដែលទាំងអស់នេះហើយសុទ្ធសឹងតែបណ្តាលមកពីការសេពគ្រឿងស្រវឹង ពុំគិតផលប៉ះពាល់និងគ្រោះថ្នាក់មុនពេលដែលយើងទទួលវា។

តាមរយៈការសិក្សាស្រាវជ្រាវនេះដដែល ក៏បានបង្ហាញឲ្យឃើញផងដែរថាបញ្ហានៃការប្រើប្រាស់គ្រឿងស្រវឹង នៅក្នុងសង្គមខ្មែរចេះតែមានការវិវត្តន៍ឈានឡើងពីមួយថ្ងៃទៅមួយថ្ងៃអាស្រ័យដោយជីវភាពរបស់ពួកគេ មានភាពកាន់តែល្អប្រសើរឡើង ដែលវាជាហេតុធ្វើអោយពួកគេចំណាយថវិកាផ្ទាល់ខ្លួនមួយផ្នែកទៅលើគ្រឿងស្រវឹង។ ហើយបច្ចុប្បន្ន អ្វីដែលជាក្តីបារម្ភបំផុតនោះ គឺយុវជនដែលជាទំពាំងស្នងឬស្សីទៅថ្ងៃមុខ បាននឹងកំពុងតែឈ្លក់វង្វេងទៅ នឹងការប្រើប្រាស់គ្រឿងស្រវឹងដោយគ្មានការពិចារណាពីអណាគតរបស់ខ្លួនឡើយ។ លទ្ធផលទាំងអស់នេះហើយទើបធ្វើអោយយុវជន និងយុវនារីរបស់យើងធ្លាក់ចូលទៅក្នុងភាពអវិជ្ជា អសមត្ថភាពក្នុងការសិក្សារៀនសូត្រ និងការបំពេញការងារនៅពេលដែលពួកក្លាយជាសសរទ្រូងរបស់ប្រទេសជាតិនាពេលអនាគត។

ដូច្នេះផលប៉ះពាល់ ព្រមទាំងមូលហេតុផ្សេងៗ ដែលបណ្តាលឲ្យមានការទទួលទានគ្រឿងស្រវឹងជាចម្បងនៅក្នុងសង្គមខ្មែរយើង គឺគ្មានអ្វីក្រៅពីបុគ្គលខ្លួនឯងផ្ទាល់ ក៏ដូចជាការផ្សព្វផ្សាយដែលបង្ហាញពីលក្ខណៈពិសេសរបស់គ្រឿងស្រវឹង ដែលជាកត្តាជម្រុញធ្វើឲ្យចិត្តរបស់មនុស្សផ្ទាល់យល់ខុសទាំងស្រុងថាវាជាគ្រឿងម្យ៉ាងដែលធ្វើឲ្យខ្លួនទទួលបាននូវក្តីសុខ អារម្មណ៍ស្រស់ថ្លា និងមានមោទនភាពលើខ្លួនឯង។ ដែលមានភាពផ្ទុយស្រឡះពីការសិក្សាស្រាវជ្រាវ ក៏ដូចជាការបង្ហាញពីអង្គការសុខភាពពិភពលោក ដែលបានលើកឡើងថា ការទទួលទានគ្រឿងស្រវឹងច្រើនខ្លាំងហួសប្រឈមនឹងជម្ងឺជាច្រើនមុខ ហើយដែលអាចធ្វើឲ្យប្រព័ន្ធសរីរាង្គនៅក្នុងខ្លួនចុះខ្សោយបន្តិចម្តងៗ។

សរុបមកការចូលរួមទាំងអស់គ្នា ទាំងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋគួរគប្បីធ្វើការសិក្សាអំពីផលអវិជ្ជមាន ដែលបណ្តាលមកពីបញ្ហានៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងការបញ្ចៀសបញ្ហានេះអោយបានឆាប់រហ័ស ដើម្បីជាយន្តការសំរាប់ការដោះស្រាយ និងឆ្លើយតបភ្លាមៗទៅនឹងការកើនឡើងនៃអត្រាអ្នកប្រើប្រាស់ ព្រមជាមួយនឹងការធ្វើអាជីវកម្មទៅលើគ្រឿងស្រវឹងដែលមានលក្ខណៈផុលផុសយ៉ាងសម្បើមដូចនាពេលបច្ចុប្បន្ននេះ។ តាមរយៈការបង្កើតឲ្យមានក្រុមការងារពិសេសធ្វើការសិក្សារកមូលហេតុដើមនៃបញ្ហា ហើយធ្វើការវិភាគប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ឈានទៅដល់ការស្វែងរកគន្លឹះដ៏ល្អប្រសើរនៅក្នុងការដោះស្រាយដែលជាទិសដៅអណាគត សំរាប់ការកាត់បន្ថយនៃចំនួនអ្នកប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសង្គមខ្មែរយើង។ ជាពិសេសអត្រានៃគ្រោះថ្នាក់ផ្សេងៗ ដែលបណ្តាលមកពីការទទួលទានគ្រឿងស្រវឹងចាប់ពីពេលនេះនឹងទៅថ្ងៃមុខ។

តាមរយៈការសិក្សាស្រាវជ្រាវជុំវិញប្រធានបទដែលស្តីអំពី "**ឥទ្ធិពលនៃគ្រឿងស្រវឹងក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន**"ខាងលើនេះ ពិតជាបានទទួលនូវលទ្ធផលមួយចំនួន ដែលវាជាបញ្ហានៃការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសង្គមខ្មែរយើង ហើយបញ្ហាទាំងនោះរួមមានៈ កង្វះខាតផ្នែកផ្លូវច្បាប់នៅក្នុងការត្រួតពិនិត្យលើគុណភាព និងការចរាចរគ្រឿងស្រវឹងនៅឡើយ បញ្ហាលំបាកចំពោះការកំណត់អាយុរបស់អ្នកប្រើប្រាស់គ្រឿងស្រវឹងមិនទាន់អាចកំណត់បាននៅក្នុងច្បាប់ ព្រមជាមួយការកំណត់ទីតាំងក្នុងការលក់ ចែកចាយ ក៏ដូចជាកន្លែងសំរាប់ការទទួលទានគ្រឿងស្រវឹងពុំអាចបែងចែកទៅតាមទីតាំងមួយពិតប្រាកដ។

ម្យ៉ាងវិញទៀត ការយល់ដឹងអំពីផលប៉ះពាល់ចំពោះការប្រើប្រាស់គ្រឿងស្រវឹងរបស់ប្រជាពលរដ្ឋខ្មែរក៏នូវមានកម្រិតផងដែរ។ ដូច្នេះបញ្ហាទាំងអស់នេះហើយ ដែលជាការប្រឈមខ្ពស់សំរាប់សង្គមជាតិរបស់យើងត្រូវធ្វើការដោះស្រាយរួមគ្នាដោយមិនអាចខ្វះនូវភាគីណាមួយបានឡើយ។

ដូច្នេះដើម្បីធ្វើការដោះស្រាយនូវបញ្ហាខាងលើនេះ យើងគប្បីធ្វើការសិក្សាឲ្យបានច្បាស់នូវទិដ្ឋភាពនានា ដែលជាដើមហេតុចម្បង បង្កឲ្យការប្រើប្រាស់គ្រឿងស្រវឹង ព្រមទាំងផលវិបាកដែលបណ្តាលមកពីសេពគ្រឿងស្រវឹង ដែលចេះតែមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ការចូលរួមពីសំណាក់រាជរដ្ឋាភិបាល គឺជាការចាំបាច់បំផុតក្នុងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តន៍ច្បាប់ ក៏ដូចជាកំណត់គោលនយោបាយច្បាស់លាស់ស្តីពីការត្រួតពិនិត្យលើគុណភាព និងការចរាចរគ្រឿងស្រវឹងនៅក្នុងសង្គម។ ជាពិសេសការរៀបចំឲ្យមានកន្លែងសំរាប់ចែកចាយ លក់ដូរ និងទទួលទានគ្រឿងស្រវឹងអោយមានភាពល្អប្រសើរ និងមានសណ្តាប់ធ្នាប់ ហើយត្រូវស្ថិតនៅក្រោមការពិនិត្យមើលពីអាជ្ញាធរមានសមត្ថកិច្ច។ លើសពីនេះទៅទៀត ការកម្រិតអាយុសំរាប់អ្នកប្រើប្រាស់គ្រឿងស្រវឹងក្នុងសង្គមខ្មែរ ក៏គួរតែមានចែងក្នុងច្បាប់ផងដែរ។ ព្រោះយើងសង្កេតឃើញថាបច្ចុប្បន្ននេះមិនថាតែមនុស្សមានវ័យគ្រប់ក្នុងការប្រើប្រាស់គ្រឿងស្រវឹងទេ ប៉ុន្តែសម្បីតែអនីតិជនដែលមានវ័យចាប់ពី ១៣ ទៅ ១៨ឆ្នាំ ជាពិសេសយុវវ័យផ្ទាល់តែម្តង គឺកំពុងតែមានការប្រើប្រាស់គ្រឿងស្រវឹងយ៉ាងច្រើនគួរឲ្យព្រួយបារម្ភ។ ចំណុចគន្លឹះទាំងអស់នេះហើយ ដែលទាមទារនូវសកម្មភាពមិនអាចខ្វះបានរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការដោះស្រាយចំពោះបញ្ហាខាងលើនេះ។

យ៉ាងណាមិញ ដំណោះស្រាយដែលរិតតែមានភាពល្អប្រសើរជាងនេះទៅទៀតគឺការចូលរួមផ្ទាល់ពីប្រជាពលរដ្ឋ។ ព្រោះប្រជាពលរដ្ឋជាអ្នកដែលទទួលរងពីការជះឥទ្ធិពលនៃគ្រឿងស្រវឹងខ្លាំងបំផុត ប្រសិនបើពួកគាត់បានយល់ដឹងពីផលប៉ះពាល់របស់គ្រឿងស្រវឹងនេះ ក៏ដូចជាចិត្តរបស់ពួកគាត់ផ្ទាល់ប្តេជ្ញាថាមិនទទួលគ្រឿងស្រវឹងនោះទេ ច្បាស់ណាស់បញ្ហាទាំងឡាយក៏មិនអាចកើតមានឡើងបានផងដែរ។ នៅក្នុងចំណុចនេះ វាពិតជារឿងដ៏លំបាកមួយ ដែលចង់ឲ្យពួកគាត់ឈប់ទទួលទានគ្រឿងស្រវឹងភ្លាមៗនោះ។ ប៉ុន្តែតាមរយៈការផ្សព្វផ្សាយ ការពន្យល់ ពីសំណាក់មន្ត្រីជំនាញ ក៏ដូចជាអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធបញ្ហានេះ អាចរួមចំណែកផងដែរក្នុងការកាត់បន្ថយនូវចំនួននៃអ្នកប្រើប្រាស់គ្រឿងស្រវឹងនេះបានមួយកម្រិត។

យើងពិតជាសង្ឃឹម និងជឿជាក់ថា លទ្ធផលដែលទទួលបានពីកិច្ចការស្រាវជ្រាវខាងលើព្រមជាមួយនឹងដំណោះស្រាយជាបន្តបន្ទាប់នេះ ពិតជាបានបន្ថែមអត្ថន័យកាន់តែច្បាស់ថែមទៀតទៅលើប្រធានបទដែលបានរៀបរាប់ពីខាងដើម។ តាមរយៈលទ្ធផលនេះផងដែរ ទោះបីជាមានឥទ្ធិពលនៃគ្រឿងស្រវឹងនេះ មានការកើនឡើងខ្លាំងក៏ពិតមែន ប៉ុន្តែយើងអាចធ្វើការដោះស្រាយវាបានដោយផ្អែកទៅតាមឆន្ទៈនៃការចូលរួមពី រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិលធ្វើការលើគ្រឿងស្រវឹង និងប្រជាពលរដ្ឋផ្ទាល់ ដែលជាដំណោះស្រាយមួយដ៏ល្អពិតប្រាកដ។

# អនុសាសន៍

ដើម្បីរួមចំណែកជួយដល់សង្គមខ្មែរ ក្នុងការទប់ស្កាត់ និងកាត់បន្ថយឥទ្ធិពលគ្រឿងស្រវឹងនេះ និងផលប៉ះពាល់ពីការប្រើប្រាស់វា ក្នុងនាមជានិស្សិត យើងខ្ញុំទាំងពីរនាក់សូមផ្តល់នូវអនុសាសន៍មួយចំនួនដូចតទៅៈ

១. រាជរដ្ឋាភិបាលត្រូវតែដាក់កំហិតកំណត់អាយុអ្នកទិញ និងប្រើប្រាស់គ្រឿងស្រវឹង នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងស្រវឹង ដើម្បីទប់ស្កាត់កុំឲ្យកុមារ និងយុវវ័យមិនទាន់គ្រប់អាយុអាចប្រើប្រាស់គ្រឿងស្រវឹងនេះ។

២. រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ត្រូវតែរកវិធានលុបបំបាត់រាល់ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង គ្រប់រូបភាព។ ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងគ្រប់រូបភាព បានជះឥទ្ធិពលជាខ្លាំងទៅលើប្រជានជនកម្ពុជា។

៣. រាជរដ្ឋាភិបាល គួរតែពន្លឿនលើការអនុម័ត ច្បាប់ស្តីអំពីការគ្រប់គ្រងគ្រឿងស្រវឹង។ កាលណាដែលច្បាប់នេះត្រូវបានអនុម័ត នោះឥទ្ធិពលគ្រឿងស្រវឹងនេះនឹងត្រូវកាត់បន្ថយបានមួយកម្រិតធំ។

៤. អាជ្ញាធរ មន្ត្រី មានសមត្ថកិច្ច ត្រូវអនុវត្តច្បាប់ និងដាក់ទោសដល់ជនទាំងឡាយណាដែលបង្កបញ្ហា ឬគ្រោះថ្នាក់ផ្សេងៗដែលបង្កឡើងក្រោមស្ថានភាពស្រវឹង។

៥. រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងសង្គមស៊ីវិលនានា គួរតែបង្កើត និងបន្តឲ្យមានការចុះផ្សព្វផ្សាយពីផលប៉ះពាល់ពីការប្រើប្រាស់គ្រឿងស្រវឹងនេះ នៅតាមសហគមន៍ និងមូលដ្ឋាននានា។

៦. ស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងសារព័ត៌មាននានាគួរតែដាក់បញ្ចូលនូវកម្មវិធីអប់រំសុខភាពស្តីផលប៉ះពាល់ពីគ្រឿងស្រវឹងនេះឲ្យបានច្រើនជាងមុន។

ក្រុមយើងខ្ញុំសង្ឃឹមថា អនុសាសន៍ដែលបានផ្តល់នៅខាងលើនេះនឹងត្រូវបានរាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋអាចអនុវត្តបាន នោះឥទ្ធិពលនៃគ្រឿងស្រវឹងនៅក្នុងសង្គមខ្មែរនឹងកាត់បន្ថយធ្វើឲ្យសង្គមខ្មែរមានសេចក្តីសុខ សុភមង្គល និងមានសណ្តាប់ធ្នាប់៕

# ឯកសារយោង

## ក. ឯកសារច្បាប់

១. ច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក ប្រកាសឲ្យប្រើនា ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤

## ខ. ឯកសារលិខិតបទដ្ឋាន

១. សារាចរស្តីពី ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង, លេខ៤៩២ ពម.សរ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤។

២. សេចក្តីជូនដំណឹងស្តីពី ការហាមប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិវេនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន, លេខ១៨ សណន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១។

៣. សេចក្តីជូនដំណឹងរបស់ក្រសួងព័ត៌មាន លេខ០០៣០ ព.ម ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៥

## គ. ឯកសារទ្រឹស្តី

១. ឯកឧត្តមនាយឧត្តមសេនីយ៍ ឯម សំអាន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សុន្ទរកថាស្តី ពី "គ្រឿងស្រវឹង និងសុវត្ថិភាពភូមិ-ឃុំ" នៅក្រសួងមហាផ្ទៃ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២

២. លោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សុន្ទរកថាស្តីពី "យន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង" នៅវិមានព្រឹទ្ធសភា ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

៣. លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ នៃព្រឹទ្ធសភា "របាយការណ៍ស្តីអំពី ការវិវឌ្ឍ និងកិច្ចខិតខំប្រឹងប្រែងជារួមឲ្យមានច្បាប់ស្តីអំពីការគ្រប់គ្រងគ្រឿងស្រវឹង" នៅវិមានព្រឹទ្ធសភា ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៤

៤. លោកព្រឹទ្ធាចារ្យ មៀច ប៉ុណ្ណ "កម្រងឯកសារស្តីពី ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ភាគ២" ចេញផ្សាយដោយ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ២០០៨

៥. លោក ឆឹង ចាន់សុផុន "សៀវភៅបុណ្យទំនៀមខ្មែរ ក្រាំបុណ្យទាំង១២ខែ" បោះពុម្ពលើកទី១ ចេញផ្សាយដោយសាកលវិទ្យាល័យបញ្ញាសាស្ត្រ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០០

## ឃ. ឯកសារផ្សេងៗ

១.	ទស្សនាវដ្ដីសុខភាពយើង, "អំពើហិង្សាក្នុងគ្រួសារ បំផ្លាញសុភមង្គលគ្រួសារ"	លេខ០០៣ ចេញផ្សាយ ខែមេសា ឆ្នាំ២០០៦

២.	ទស្សនាវដ្ដីសុខភាពយើង, "គ្រឿងស្រវឹងបង្កផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយ" លេខ០៤៧ ចេញផ្សាយ ខែធ្នូ ឆ្នាំ២០០៩

៣.	ទស្សនាវដ្ដីសុខភាពយើង, "អ្នកទទួលគ្រឿងស្រវឹងច្រើនហួសហេតុ" លេខ០៦៨ ចេញផ្សាយ ខែកញ្ញា ឆ្នាំ២០១១

## គ. ឯកសារពីអ៊ីនធឺណែត

១.	http://www.tripadvisor.com

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖**

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី អនុម័តនាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤
- គោលនយោបាយភូមិ-សង្កាត់មានសុវត្ថិភាព (រាជធានីភ្នំពេញ)
- សារាចរ ស្តីពីការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង ក្រសួងពត៌មាន លេខ៥៩២ ពម .សរ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤
- សេចក្តីជូនដំណឹងលេខ១៨ សណន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការហាមប្រើប្រាស់គ្រឿងស្រវឹងក្នុងបរិវេនគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- សេចក្តីជូនដំណឹងរបស់ក្រសួងពត៌មាន លេខ០០៣០ ព.ម ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៥
- សុន្ទរកថារបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ឯម សំអាន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ក្នុងឪកាសបើសិក្ខាសាលាស្តីពីគ្រឿងស្រវឹង និង សុវត្ថិភាពភូមិ/ឃុំ ថ្ងៃទីព្រហស្បត្តិ៍ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២
- សុន្ទរកថា លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុឪកាសបើកកិច្ចពិគ្រោះយោបល់ ស្តីអំពីយន្តការឆ្ពោះទៅការកសាងគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹង នៅវិមានព្រឹទ្ធសភា ថ្ងៃទី២៧ ខែមករាឆ្នាំ២០១៤
- របាយការណ៍ ស្តីអំពី ការវិវឌ្ឍ និងកិច្ចខិតខំប្រឹប្រែងជារួមឲ្យមានច្បាប់ស្តីអំពីការគ្រប់គ្រងគ្រឿងស្រវឹង ដោយ លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ នៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០១៤
- សេចក្តីថ្លែងការណ៍ទីក្រុង សេអ៊ូល ស្តីពី គោលនយោបាយគ្រឿងស្រវឹង ថ្ងៃទី៧-៩ ខែតុលា ឆ្នាំ២០១៣

**ឧបសម្ព័ន្ធទី២៖**

- លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង របស់អង្គការចលនាដើម្បីសុខភាពកម្ពុជា (CMH) ឆ្នាំ២០១៤
- ក្លីបកម្សាន្តពេលថ្ងៃកំពុងតែពង្វក់សិស្សវិទ្យាល័យមួយចំនួនឲ្យភ្លេចការសិក្សា

- ហេតុអ្វីបុរសខ្មែរចូលចិត្តគ្រឿងស្រវឹង?
- ទម្លាប់ទទួលទានគ្រឿងស្រវឹងនៅថ្ងៃចូលឆ្នាំ ធ្វើឲ្យវប្បធម៌ប្រពៃណីប្រឈមនឹងការបាត់បង់
- អ្នកនិពន្ធមួយចំនួនកំពុងវក់នឹងការតែងតចម្រៀងបែបជំរុញឲ្យយុវជនជំនាន់ក្រោយមានជំនាញខាងផឹកស្រា
- យុវជនចង់ឲ្យមានទីលម្ហែច្រើនសម្រាប់លម្ហែកាយ
- សង្គមស៊ីវិលលើកអនុសាសន៍សុំបង្កើតច្បាប់គ្រប់គ្រងគ្រឿងស្រវឹង
- បញ្ហាគ្រឿងស្រវឹងបានលក្លាយជាប្រធានបទសំខាន់នៅកិច្ចប្រជុំពិភាក្សាតុមូលស្តីពីសុវត្ថិភាពចរាចរណ៍ក្នុងប្រទេសកម្ពុជា
- ហេតុអ្វីយុវជនរួមភេទ និងសេពគ្រឿងស្រវឹងនៅវ័យក្មេង?
- នៅពេលដែលសង្គមស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង
- លោក ប៉ែន យុន ការផ្សព្វផ្សាយច្បាប់ចរាចរណ៍ដល់និស្សិតRUPP ជាង១០០នាក់
- គ្រឿងស្រវឹងសម្លាប់ជីវិតមនុស្សយ៉ាងសាហាវបំផុត
- នាយករដ្ឋមន្ត្រី ជំរុញឲ្យក្រុមហ៊ុនផលិតស្រាបៀរក្នុងស្រុក បង្កើនការនាំចេញទៅបរទេស

**ឧបសម្ព័ន្ធ៣៖**

- ស្រវឹងខ្លាំងពេកបើកបររថយន្តបុកបង្គោលភ្លើង ពេលសមត្ថកិច្ចសួរប្រាប់ថាបង្គោលភ្លើងបុករថយន្តទៅវិញ
- នារីម្នាក់បើករថយន្តទាំងស្រវឹងបុកអង្គរក្សយាមភូមិគ្រឹះសម្តេចរងរបួសធ្ងន់២នាក់
- ផឹកស៊ីឆ្លងឆ្នាំត្រឡប់ទៅផ្ទះវិលងអព្រាត បុកគូទរថយន្តឈប់ស្ងៀមស្លាប់៣នាក់
- តូចចិត្តនឹងប្តីប្រមឹកវាយដំរាល់ថ្ងៃ នាងផឹកថ្នាំពុលបញ្ចប់ជីវិត
- ក្នុងរង់ផឹកស៊ី ញ៉ែប្រពន្ធគេ ត្រូវ៣ផ្លែដែកឆាបបណ្តាលឲ្យរបួសធ្ងន់
- កូនអកតញ្ញូផឹកស្រាស្រវឹងបំផ្លាញទ្រព្យសម្បត្តិដេញកាប់ម្តាយផ្អើលពេញភូមិ
- ស្រវឹងស្រាជេរ និងវាយអ្នកជិតខាងរបួសត្រូវនគរបាលចាប់ខ្លួន